សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# ភាពខុសគ្នារវាង តួនាទីមេធាវី និង តួនាទីតុលាការ

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **អ៊ឹម តួបម៉ារ៉ុឌី**

**ក. ស៊ាង លីនដា**

សាស្ត្រាចារ្យណែនាំ

លោកជំទាវ **ខួន មករា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# <u>សេចក្តីថ្លែងអំណរគុណ</u>

ខ្ញុំបាទ **អ៊ឹម គួចម៉ារីឌី** និង **កញ្ញា ស៊ាង លីនដា** ជានិស្សិតបរិញ្ញាប័ត្រនីតិសាស្ត្រ ជំនាន់ទី១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

យើងខ្ញុំទាំងពីរ សូមធ្វើការថ្លែងអំណរគុណ និងសូមសម្តែងនូវកតញ្ញូតាធម៌ចំពោះ៖

**លោកឪពុក អ៊ឹម សុគន្ធ** និង **អ្នកម្តាយ ថេរ ឧទ្ធី**

**លោកឪពុក សុខ សឿន** និង **អ្នកម្តាយ ហុខ ចន្ធូ** ដែលលោកទាំងពីរបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាកូនៗប្រកបដោយព្រហ្មវិហារធម៌ ជាពិសេសបានទំនុកបំរុងគ្រប់បែបយ៉ាងទាំងផ្នែកសម្ភារៈថវិកា ស្មារតីកម្លាំងចិត្ត និងដំបូន្មានល្អៗ តាំងពីថ្នាក់បឋមសិក្សាមកដល់បច្ចុប្បន្ននេះ ដែលអនុញ្ញាតឱ្យកូនៗមានឱកាសក្នុងការទទួលបាននូវចំណេះដឹងដែលជាប្រទីប និងជាទ្រព្យធនដែលមិនចេះបាត់បង់ជារៀងរហូត។

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** និងសមាជិក-សមាជិកាទាំងអស់នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលលោកបានខិតខំក្នុងការដឹកនាំនិងអភិវឌ្ឍមាតុភូមិកម្ពុជាប្រកបដោយកត្តិបណ្ឌិត ការអភិវឌ្ឍន៍ និងសន្តិភាពពេញលេញស្មើមុខស្មើមាត់ក្នុងឆាកអន្តរជាតិ។

**ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច និង **លោកជំទាវ ខួន មករា** សាស្ត្រាចារ្យដឹកនាំ ក៏ដូចជាលោក-លោកស្រីទាំងអស់ជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលលោកទាំងអស់បានចំណាយពេលវេលា កម្លាំងកាយ និងចំណេះដឹងក្នុងការដឹកនាំសារណា និងបង្រៀនពួកខ្ញុំក្នុងរយៈពេលកន្លងមក។

**ឯកឧត្តម សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និង **លោកមេធាវី យុខ ផានិត** សមាជិកក្រុមប្រឹក្សាគណៈមេធាវី និងជាអនុប្រធាននាយកដ្ឋានការពារក្តីជូនជនក្រីក្រនៃគណៈមេធាវី ដែលលោកបានផ្តល់ឱកាសនិងចំណាយពេលវេលាអនុញ្ញាតឱ្យយើងខ្ញុំបានចូលសម្ភាសន៍សាកសួរអំពីប្រធានបទនេះនៅស្ថាប័នរបស់លោក ក៏ដូចជាបានផ្តល់នូវសំណៅឯកសារពាក់ព័ន្ធដល់យើងខ្ញុំផងដែរ។

**លោក សុខ កល្យាណ** ប្រធានសាលាដំបូងខេត្តព្រះសីហនុដែលបានផ្តល់ឱកាស និងចំណាយពេលវេលាអនុញ្ញាតឱ្យយើងខ្ញុំបានចូលសម្ភាសន៍សាកសួរ និងផ្តល់ជាឯកសារពាក់ព័ន្ធនឹងប្រធានបទនេះនៅស្ថាប័នរបស់លោកផងដែរ។

ជាចុងក្រោយ យើងខ្ញុំសូមបួងសួងដល់បារមីនៃវត្ថុសក្តិសិទ្ធិទាំងពួង សូមលោកជួយតាមថែរក្សាលោកអ្នកមានគុណទាំងឡាយឱ្យប្រកបតែសេចក្តីសុខ សេចក្តីចម្រើនគ្រប់ពេលវេលា កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

ក្នុងរយៈពេលបួនឆ្នាំ នៃការសិក្សាមុខជំនាញបរិញ្ញាប័ត្រនីតិសាស្រ្ត នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចកន្លងមកនេះ យើងខ្ញុំជានិស្សិតបានទទួលនូវចំណេះដឹង និងបទពិសោធន៍ជាច្រើនពាក់ព័ន្ធនឹងវិស័យច្បាប់ ដែលក្នុងនោះក៏មានរួមបញ្ចូលនូវការសិក្សាទ្រឹស្តីផ្សេងៗ ការចុះកម្មសិក្សា និង ការចុះស្រាវជ្រាវឯកសារ ក៏ដូចជាការចូលរួមក្នុងសកម្មភាពសង្គមផងដែរ។

ចំពោះការជ្រើសយកប្រធានបទ "**ភាពខុសគ្នានៃតួនាទីមេធាវី និង តួនាទីតុលាការ**" សម្រាប់យកមកស្រាវជ្រាវក្នុងសារណាបញ្ចប់ការសិក្សានេះ គឺដោយមានការចង្អុលបង្ហាញ និងណែនាំអំពី**លោកជំទាវ ខួន មករា** ដែលជាសាស្រ្តាចារ្យណែនាំ និងដោយយើងខ្ញុំទាំងពីររូបបានមើលឃើញនូវការវិវត្តន៍នៃវិស័យច្បាប់នៅកម្ពុជា ក៏ដូចជានៃការកើនឡើងនូវតម្រូវការបុគ្គលដែលមានចំណេះជំនាញផ្នែកច្បាប់នេះ ដែលមានដូចជា ចៅក្រម ព្រះរាជអាជ្ញា មេធាវី ជាដើម។ បន្ថែមពីលើនេះការស្រាវជ្រាវនេះ ក៏ជាការស្រាយនូវចម្ងល់មួយក្នុងសង្គមដែលប្រជាពលរដ្ឋមួយចំនួនគិតថា មេធាវី គឺជាវិជ្ជាជីវៈមួយដែលស្ថិតនៅជាមួយតុលាការដូចគ្នា។

យើងខ្ញុំទាំងពីរ ពិតជាមានសេចក្តីសមោនស្សរីករាយជាអនេកដែលបានទទួលនូវឱកាសក្នុងការធ្វើសារណាបញ្ចប់ការសិក្សានេះ ដោយយើងខ្ញុំសន្យាថានឹងខិតខំធ្វើអស់ពីកម្លាំងកាយចិត្តនិងប្រើប្រាស់ចំណេះដឹងដែលយើងខ្ញុំមានដើម្បីស្រាវជ្រាវនិងចងក្រងនូវសារណានេះឱ្យស្របតាមគោលការណ៍នៃប្រធានបទខាងលើ។

ជាកិច្ចបញ្ចប់ យើងខ្ញុំសង្ឃឹមថា ឯកសារស្រាវជ្រាវមួយនេះនឹងក្លាយជាពុទ្ធិ និងជាមូលដ្ឋានសិក្សាមួយសម្រាប់ប្រជាពលរដ្ឋគ្រប់ស្រទាប់ ពិសេសយុវជន-យុវនារី ដែលជានិស្សិតផ្នែកនីតិសាស្រ្ត ឬជានិស្សិត បញ្ញាវ័ន្តគ្រប់ជំនាញទាំងអស់ក្នុងប្រទេស ដើម្បីយកមកធ្វើជាមូលដ្ឋានចំណេះដឹង ឬគំនិតនានាពីប្រព័ន្ធយុត្តិធម៌ដែលបង្កើតបាននូវផលប្រយោជន៍ជូនសង្គមជាតិ។ យើងខ្ញុំក៏សូមអភ័យទោសចំពោះកំហុសខុសឆ្គងដោយអចេតនាណាមួយដែលកើតមានក្នុងសារណាបញ្ចប់ការសិក្សានេះ ហើយពួកយើងរីករាយនឹងទទួលនូវរាល់ការរិះគន់ដើម្បីស្ថាបនា កំណែ និងឯកសារថ្មីបន្ថែមៗដើម្បីកែលម្អឯកសារនេះឡើងវិញ និងកាន់តែមានអត្ថន័យផងដែរ។

យើងខ្ញុំសូមឧទ្ទិសស្នាដៃនេះដល់អស់លោកដែលមានគុណូបការៈក្នុងការតាក់តែងកម្រងឯកសារគតិយុត្តខ្មែរនានាដែលចូលរួមចំណែកក្នុងការអភិវឌ្ឍវិស័យយុត្តិធម៌របស់ព្រះរាជាណាចក្រកម្ពុជាយើងជារៀងរហូតតទៅ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម**

**ជំពូកទី១៖ ដំណើរនៃការប្រព្រឹត្តទៅនៃប្រព័ន្ធយុត្តិធម៌នៅកម្ពុជា** ........ ១

**ផ្នែកទី១៖ ប្រវត្តិនៃការប្រព្រឹត្តទៅនៃប្រព័ន្ធយុត្តិធម៌នៅកម្ពុជា** ........

១. យុត្តិធម៌ និងការកាត់ក្តីក្នុងបុរេសម័យ ........ ៦

២. យុត្តិធម៌ និងការកាត់ក្តីក្នុងសម័យអាណានិគមបារាំង ........ ៧

៣. យុត្តិធម៌ និងការកាត់ក្តីក្នុងសម័យក្រោយអាណានិគម ........ ៨

**ផ្នែកទី២៖ ការប្រព្រឹត្តទៅឡើងវិញ និងកំណែទម្រង់នៃប្រព័ន្ធយុត្តិធម៌នៅកម្ពុជា** ........

១. ការប្រព្រឹត្តទៅឡើងវិញនៃប្រព័ន្ធយុត្តិធម៌ ........ ៩

១.១ ការបង្កើតឱ្យមានតុលាការ និងអយ្យការឡើងវិញ ........ ៩

២. កំណែទម្រង់នៃប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ........ ១០

**ជំពូកទី២៖ តួនាទី និងភារកិច្ចមេធាវី**

**ផ្នែកទី១៖ សញ្ញាណនៃវិជ្ជាជីវៈមេធាវីនៅកម្ពុជា** ........ ១២

**ផ្នែកទី២៖ វិជ្ជាជីវៈមេធាវី និងលក្ខខណ្ឌនៃការប្រកបវិជ្ជាជីវៈ** ........ ១៤

១. អានុភាពនៃវិជ្ជាជីវៈមេធាវី ........ ១៤

១.១ លិខិតបទដ្ឋានទាក់ទងនឹងវិជ្ជាជីវៈមេធាវី ........ ១៤

១.១.១ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ........ ១៤

១.១.២ ក្រមសីលធម៌មេធាវី ........ ១៤

១.១.៣ បទបញ្ជាផ្ទៃក្នុងរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ........ ១៥

១.២ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ........ ១៥

១.៣ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ........ ១៧

២. លក្ខខណ្ឌ និងនីតិវិធីនៃការចូលប្រកបវិជ្ជាជីវៈមេធាវី ........ ១៧

២.១ នីតិវិធីនៃការចូលប្រកបវិជ្ជាជីវៈមេធាវី ........ ១៧

២.២ ការសិក្សាវគ្គបណ្តុះបណ្តាល និងការចុះកម្មសិក្សា ........ ១៩

២.២.១ ការសិក្សាវគ្គបណ្តុះបណ្តាល ........ ១៩

២.២.២ ការចុះកម្មសិក្សា ......................................................................................................... ២០
**ផ្នែកទី៣៖ ការចូលប្រកបវិជ្ជាជីវៈរបស់មេធាវីបរទេស** .........................................................................
១. នីតិវិធីនៃការចូលប្រកបវិជ្ជាជីវៈ ឬបើកការិយាល័យមេធាវីបរទេស ..............................................២១
២. សមត្ថកិច្ចរបស់គណៈមេធាវីក្នុងការអធិការកិច្ចលើមេធាវីបរទេសខុសច្បាប់................................២២
**ផ្នែកទី៤៖ តួនាទីរបស់មេធាវីក្នុងសង្គម** .................................................................................................
១. ការការពារក្តីជូនអតិថិជន នៅក្នុងតុលាការ ..........................................................................២២
១.១ ការប្រឹក្សាយោបល់ផ្នែកច្បាប់ .............................................................................................២២
១.២ ការការពារក្តីជូនកូនក្តីក្នុងតុលាការ ........................................................................................ ២៣
១.២.១ ការការពារជូនកូនក្តីក្នុងសំណុំរឿងរដ្ឋប្បវេណី..................................................... ២៣
១.២.២ ការការពារជូនកូនក្តីក្នុងសំណុំរឿងព្រហ្មទណ្ឌ.........................................................២៤
២. ការឈរជាតំណាងក្នុងកិច្ចសន្យានានា ...........................................................................................២៥
២.១ ការប្រថាប់ត្រារបស់មេធាវីក្នុងកិច្ចសន្យា...........................................................................................២៥
២.២ ការឈរឈ្មោះជាតំណាងរបស់ក្រុមហ៊ុន ឬស្ថាប័ននានា ......................................................២៥
**ផ្នែកទី៥៖ ការចូលរួមរបស់មេធាវីក្នុងការពង្រឹងវិស័យយុត្តិធម៌**.............................................................
១. ការការពារក្តីជូនជនក្រីក្រ.................................................................................................... ២៦
២. ការប្រឹក្សា និងពិគ្រោះយោបល់ផ្នែកច្បាប់ជូនប្រជាពលរដ្ឋក្រីក្រ ..................................................២៨
៣. ការចូលរួមរបស់មេធាវីនៅក្នុងការការពារផ្លូវច្បាប់ដល់ស្ត្រី និងកុមារ...........................................២៨
៣.១ យន្តការនៃការប្រឹក្សាយោបល់ផ្នែកច្បាប់និងការការពារស្ត្រីក្នុងតុលាការ ...................... ២៨
៣.២ ការការពារកុមារតាមយន្តការកុមារមេត្រី ............................................................ ២៩

## ជំពូកទី៣៖ តួនាទីតុលាការ

**ផ្នែកទី១៖ តុលាការ និងអយ្យការ**
១. លិខិតបទដ្ឋានដែលពាក់ព័ន្ធនឹងវិស័យតុលាការ និងអយ្យការ ...................................................... ៣២
១.១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា.................................................................................... ៣២
១.២ លិខិតតុបករណ៍អន្តរជាតិ..................................................................................................... ៣៣
១.៣ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ...................................................................................... ៣៤
១.៤ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម .......................... ៣៤
១.៥ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ......................................................... ៣៥

២. តួនាទីរបស់ចៅក្រម និងព្រះរាជអាជ្ញា ..................................................... ៣៥
៣. ប្រភេទនៃតុលាការជំនាញ និងសភាជំនាញ ..................................................... ៣៥
៣.១ តុលាការជំនាញនៃតុលាការជាន់ទាប ..................................................... ៣៩
៣.១.១ តុលាការព្រហ្មទណ្ឌ និងតុលាការរដ្ឋប្បវេណីនៃសាលាដំបូង ..................... ៣៩
៣.១.៣ តុលាការពាណិជ្ជកម្ម និងតុលាការការងារនៃសាលាដំបូង ..................... ៣៩
៣.២ សភាជំនាញនៃតុលាការជាន់ខ្ពស់ ..................................................... ៤០
៣.២.១ សភាជំនាញនៃសាលាឧទ្ធរណ៍ ..................................................... ៤០
៣.២.២ សភាជំនាញនៃតុលាការកំពូល ..................................................... ៤០
**ផ្នែកទី២៖ នីតិវិធីនៃការទទួលបណ្តឹង និងការលើកយកបណ្តឹងមកកាត់សេចក្តី** ....................
១. សិទ្ធិជាមូលដ្ឋានក្នុងការដាក់ពាក្យបណ្តឹង និង ទទួលបានការការពារតាមផ្លូវតុលាការ ..................... ៤១
២. ការប្រព្រឹត្តទៅនៃសំណុំរឿងព្រហ្មទណ្ឌ ..................................................... ៤២
២.១ ការទទួលពាក្យបណ្តឹង និងការធ្វើបណ្តឹងអាជ្ញា ..................................................... ៤២
២.២ នីតិវិធីនៃការសួរចម្លើយជនត្រូវចោទ នៅដំណាក់កាលអយ្យការ ..................... ៤៣
២.៣ ដំណាក់កាលស៊ើបសួរ ឬដំណាក់កាលចៅក្រមស៊ើបសួរ ..................................................... ៤៤
២.៤ ដំណាក់កាលជំនុំជម្រះ ..................................................... ៤៥
៣. ការប្រព្រឹត្តទៅនៃសំណុំរឿងរដ្ឋប្បវេណី ..................................................... ៤៦
៣.១ ការទទួលពាក្យបណ្តឹង ..................................................... ៤៦
៣.២ ដំណាក់កាលផ្សះផ្សា ..................................................... ៤៦
៣.៣ នីតិវិធីត្រៀមទាញហេតុផលផ្ទាល់មាត់ ..................................................... ៤៦
៣.៤ ការទាញហេតុផលផ្ទាល់មាត់ និងការបញ្ចប់នីតិវិធី ..................................................... ៤៧
**ផ្នែកទី៣៖ សវនាការ ការជំនុំជម្រះ និងការចេញសេចក្តីសម្រេច** ..................................................... ៤៩
១. តួអង្គនៃសវនាការ ..................................................... ៤៩
១.១ ចៅក្រមជំនុំជម្រះ ..................................................... ៤៩
១.២ ព្រះរាជអាជ្ញា ..................................................... ៤៩
១.៣ ក្រឡាបញ្ជី ..................................................... ៥០
១.៤ មេធាវី ..................................................... ៥០
១.៥ គូភាគីនៃបណ្តឹង ..................................................... ៥១

១.៦ សាក្សី .......... ៥១
២. ការជំនុំជម្រះ ឬវិនិច្ឆ័យអង្គសេចក្តី.......... ៥១
២.១ កិច្ចដែលត្រូវប្រព្រឹត្តក្នុងពេលសវនាការ .......... ៥៤
២.២ ការប្រជុំសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ .......... ៥៧
៣. ការចេញសេចក្តីសម្រេចរបស់តុលាការ .......... ៥៧
៣.១ ការចេញសាលក្រមរបស់តុលាការជាន់ទាប .......... ៥៧
៣.២ ការជំទាស់ចំពោះសេចក្តីសម្រេចរបស់តុលាការជាន់ទាប .......... ៥៨
៣.៣ ការចេញសាលដីការបស់តុលាការជាន់ខ្ពស់ .......... ៦០
៣.៤ ការជំទាស់ចំពោះសេចក្តីសម្រេចរបស់តុលាការជាន់ខ្ពស់.......... ៦១

**ជំពូកទី៤៖ ភាពខុសគ្នារវាងតួនាទីមេធាវី និងតួនាទីតុលាការ**

**ផ្នែកទី១៖ ឯករាជ្យភាពនៃវិជ្ជាជីវៈមេធាវី** .......... ៦៧
១. ឯករាជ្យភាពនៃវិជ្ជាជីវៈមេធាវី.......... ៦៧
២. ការធានាលើការអនុវត្តវិជ្ជាជីវៈមេធាវី .......... ៦៨
៣. ការដាក់វិន័យចំពោះមេធាវីដែលប្រព្រឹត្តខុសពីក្រមសីលធម៌ និងវិជ្ជាជីវៈមេធាវី .......... ៦៨
៣.១ គណៈកម្មការវិន័យនៃគណៈមេធាវី.......... ៦៩
៣.២ ការដាក់វិន័យចំពោះមេធាវីដែលប្រព្រឹត្តខុសពីវិន័យ និងក្រមសីលធម៌ .......... ៦៩

**ផ្នែកទី២៖ ឯករាជ្យភាពនៃអំណាចតុលាការ និងការអនុវត្តតួនាទីរបស់តុលាការ**.......... ៧០
១. ឯករាជ្យភាពនៃអំណាចតុលាការ និងការអនុវត្តតួនាទីរបស់តុលាការ.......... ៧០
២. ការធានាលើការអនុវត្តវិជ្ជាជីវៈតុលាការ.......... ៧១
២.១ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម .......... ៧១
២.២ ក្រសួងយុត្តិធម៌ .......... ៧១
៣. ការកំណត់ទណ្ឌកម្ម ចំពោះចៅក្រម ឬព្រះរាជអាជ្ញាដែលប្រព្រឹត្តខុសវិជ្ជាជីវៈ .......... ៧២

**សេចក្តីសន្និដ្ឋាន** .......... ៧៤
**អនុសាសន៍** .......... ៧៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសដែលប្រកាន់យករបបប្រជាធិបតេយ្យនិយម សេរីពហុបក្ស អាស្រ័យរដ្ឋធម្មនុញ្ញចាប់តាំងពីឆ្នាំ ១៩៩៣ មក ដែលធ្វើឲ្យមានការបែងចែកនូវអំណាចជាបីធំៗរួមមាន អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ឬអំណាចយុត្តាធិការ។ ការបែងចែកអំណាចនេះ ពិតជាមានសារៈសំខាន់សម្រាប់ប្រទេសដែលប្រកាន់នូវរបបប្រជាធិបតេយ្យ ព្រោះការបែងចែកនេះធានាលើតុល្យភាពនៃអំណាចដែលជួយឲ្យដំណើរការប្រព្រឹត្តទៅនៃការអនុវត្តច្បាប់នៅប្រទេសកម្ពុជាមានយុត្តិធម៌ និងតម្លាភាព។ បើយើងសម្លឹងមើលទៅលើប្រព័ន្ធយុត្តិធម៌នៃប្រទេសកម្ពុជាវិញ ការធានាលើយុត្តិធម៌ ត្រូវប្រព្រឹត្តដោយអំណាចតុលាការដែលជាអំណាចឯករាជ្យមិនស្ថិតក្រោមឬមិនចំណុះឲ្យអំណាចណាមួយឡើយពោលគឺអំណាចនេះមានអំណាចគ្រប់គ្រាន់ក្នុងការសម្រេចក្តីស្របតាមបញ្ញត្តិច្បាប់ជាធរមាន ដើម្បីបម្រើ និងការពារផលប្រយោជន៍រួមដល់ប្រជាពលរដ្ឋនៅក្នុងសង្គម។ អំណាចឯករាជ្យរបស់តុលាការ គឺជាអំណាចឯករាជ្យក្នុងសម្រេចសេចក្តីរបស់ចៅក្រមដែលស្ថិតក្រោមច្បាប់ជាធរមាន និងការត្រួតពិនិត្យរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលមានព្រះមហាក្សត្រជា **ព្រះប្រធានកិត្តិយស**។ ចៅក្រម ត្រូវបានគេកំណត់ថាជាអ្នកដែលមានគតិ និងចំណេះគ្រប់គ្រាន់ក្នុងធ្វើកិច្ចវិនិច្ឆ័យក្នុងអង្គជំនុំជម្រះលើបុគ្គលទាំងឡាយណាដែលហ៊ានប្រព្រឹត្តខុសពីច្បាប់ជាធរមានរបស់កម្ពុជា។

ទោះយ៉ាងណាក៏ដោយ ការប្រព្រឹត្តទៅនៃអំណាចតុលាការ ពុំត្រូវបានអនុញ្ញាតសម្រេចតែលើចៅក្រមឡើយ។ នាសង្គមបច្ចុប្បន្ន មុននឹងឈានដល់ការសម្រេចសេចក្តី នីតិវិធីជាច្រើនត្រូវបានលើកយកមកអនុវត្តដែលនីតិវិធីទាំងនេះតម្រូវឱ្យមានអ្នកដែលមានវិជ្ជាជីវៈផ្សេងតែក្នុងចក្ខុវិស័យតែមួយបានធ្វើការដូចជា ព្រះរាជ-អាជ្ញា ក្រឡាបញ្ជី និងមេធាវីជាដើមដែលពួកគេបានធ្វើការងារជាមួយគ្នា ដើម្បីត្រិះរិះពិចារណារកនូវហេតុផលដើម្បីឆ្លើយតបនឹងប្រយោជន៍ និងការប្រព្រឹត្តទៅដោយយុត្តិធម៌ ពោលគឺ បើឈ្នះ គឺឈ្នះទាំងពេញចិត្ត បើចាញ់គឺចាញ់ទាំងអស់ចិត្ត ដោយសារហេតុផលនេះហើយ ទើបវិជ្ជាជីវៈដទៃទៀតក្នុងវិស័យច្បាប់ត្រូវបានបង្កើតឡើង។ ក្នុងនោះដែរ ក្រៅពីវិជ្ជាជីវៈចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជីដែលជាវិជ្ជាជីវៈមានកំណត់ក្របខណ្ឌ យើងសង្កេតឃើញថាមានវិជ្ជាជីវៈច្បាប់មួយដែលមានលក្ខណៈពិសេសពីគេគឺ វិជ្ជាជីវៈមេធាវី ដែលជាវិជ្ជាជីវៈមួយដែលសេរី និងឯករាជ្យ និងមានតួនាទីរក្សាការពារប្រយោជន៍ភាគីឯកជន និងធានាលើប្រសិទ្ធភាពនៃការអនុវត្តច្បាប់ ហើយក៏ជាអ្នកដែលចូលរួមក្នុងការពង្រឹងលើវិស័យយុត្តិធម៌ផងដែរ។

ការចូលរួមក្នុងការពង្រឹងលើផ្នែកយុត្តិធម៌ គឺជាធាតុមួយដ៏សំខាន់ក្នុងការអភិវឌ្ឍន៍សង្គមខ្មែរឱ្យឈានទៅរកនីតិរដ្ឋ។ ការណ៍នេះតម្រូវឲ្យស្ថាប័នបង្កើតច្បាប់ និងអ្នកអនុវត្តច្បាប់ត្រូវយល់ដឹងពីតួនាទីរបស់ខ្លួន និងប្រកាន់

នូវតួនាទីឲ្យបានត្រឹមត្រូវ និងខ្ជាប់ខ្ជួន មានន័យថា រាល់ការអនុវត្តទាំងអស់ត្រូវគោរពតាមច្បាប់ដែលបានចែងក៏ដូចជាលក្ខន្តិកៈនានា ដើម្បីពង្រឹងនូវគុណភាពនៃការអនុវត្តប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា។

ដោយផ្អែកលើគោលការណ៍ទាំងនេះហើយ ទើបក្រុមរបស់យើងខ្ញុំនឹងធ្វើការស្រាវជ្រាវទៅលើប្រធានបទ '**ភាពខុសគ្នារវាងតួនាទីមេធាវី និង តួនាទីតុលាការ**' ដើម្បីបង្ហាញពីភាពខុសគ្នានៃការអនុវត្តការងារវិជ្ជាជីវៈ ទំនួលខុសត្រូវ និងតួនាទីភារកិច្ច របស់ស្ថាប័នតុលាការ និងមេធាវី តាមរយៈការប្រៀបធៀបក្នុងការស្វែងរកភាពដូចគ្នា និងភាពខុសគ្នា អំពីដំណើរនៃការអនុវត្តន៍នៅក្នុងការស្វែងរកភាពយុត្តិធម៌ ក៏ដូចជាធ្វើការបែងចែកឱ្យដាច់ពីវិជ្ជាជីវៈទាំងពីរ។ ជាពិសេសទៅទៀតនោះ គឺដើម្បីចូលរួមលើកស្ទួយនូវការយល់ដឹងអំពីប្រព័ន្ធយុត្តិធម៌នៅប្រទេសកម្ពុជា ឲ្យកាន់តែច្បាស់តាមរយៈការរំលេចចេញពីសមត្ថកិច្ចនៃអ្នកអនុវត្តវិជ្ជាជីវៈនីមួយៗ ដោយផ្អែកលើឯកសារគតិយុត្ត អត្ថបទសិក្សា និងការអនុវត្តផ្ទាល់របស់អ្នកដែលកំពុងអនុវត្តវិជ្ជាជីវៈនេះសព្វថ្ងៃ។

## ១. លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ

យុត្តិធម៌ ត្រូវបានធានាដោយច្បាប់ ចំណែកឯច្បាប់ត្រូវបានធានាដោយអ្នកអនុវត្តវា ហេតុនេះការយល់ដឹងពីតួនាទី ភារកិច្ច និងការងាររបស់អ្នកអនុវត្តវិជ្ជាជីវៈក្នុងវិស័យទាំងនេះ គឺជាមូលដ្ឋានដំបូងរបស់ប្រជាពលរដ្ឋក្នុងការស្វែងយល់ពីច្បាប់ជាតិ ចូលរួមក្នុងវិស័យយុត្តិធម៌ និងពង្រឹងវិស័យនីតិរដ្ឋ។ អ្នកអនុវត្តវិជ្ជាជីវៈច្បាប់ដូចជាចៅក្រម ព្រះរាជអាជ្ញា មេធាវីជាដើម សុទ្ធតែជាបុគ្គល និងវិជ្ជាជីវៈដែលអំណាចតុលាការពុំអាចខ្វះបាន ព្រោះពួកគាត់ជាអ្នកដែលអាចវាស់វែងនូវយុត្តិធម៌ពិតប្រាកដតាមរយៈការកាត់សេចក្តី ពួកគេក៏ជាបុគ្គលដែលមានប្រសិទ្ធភាពបំផុតក្នុងការផ្សព្វផ្សាយពីច្បាប់ពាក់ព័ន្ធ និងលើកតម្កើងឬរំលេចចេញនូវវិជ្ជាជីវៈខ្លួនដល់ប្រជាពលរដ្ឋគ្រប់រូប។ តាមរយៈការសង្កេតសព្វថ្ងៃ កម្រិតនៃការចេះដឹងរបស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងវិស័យច្បាប់មានកម្រិតទាបដោយសារអតីតកាលនៃរបបនយោបាយក្នុងប្រទេស និងការមិនទុកចិត្តចំពោះការតតាំងចំពោះមុខច្បាប់។

## ២. ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ

ដើម្បីផ្តល់ភាពងាយស្រួលដល់ដំណើរការស្រាវជ្រាវ យើងខ្ញុំបានបង្កើតនូវសំណួរដែលទាក់ទងទៅនឹងកិច្ចការស្រាវជ្រាវនេះ៖

១. តើប្រព័ន្ធយុត្តិធម៌មានដំណើរវិវត្តយ៉ាងដូចម្តេចខ្លះ?

២. តើស្ថាប័នតុលាការ និងមេធាវីមានតួនាទីយ៉ាងដូចម្តេចក្នុងការចូលរួមនូវការពង្រឹងនូវប្រព័ន្ធយុត្តិធម៌?

៣. តើឯករាជ្យភាព វិជ្ជាជីវៈរបស់តុលាការ និងមេធាវី មានភាពដូចគ្នា និងខុសគ្នាយ៉ាងដូចម្តេច?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណង៖

- បង្ហាញអំពីការវិវត្តនៃប្រព័ន្ធយុត្តិធម៌ក្នុងប្រទេសកម្ពុជា។
- បង្កើនការយល់ដឹងទៅលើស្ថាប័នតុលាការ និងវិជ្ជាជីវៈមេធាវី។
- បង្ហាញពីសារៈសំខាន់របស់វិជ្ជាជីវៈ និងឯករាជ្យភាពរបស់ចៅក្រម និងមេធាវីក្នុងដែននៃការអនុវត្តក្នុងការពង្រឹងប្រព័ន្ធយុត្តិធម៌ក្នុងប្រទេសកម្ពុជា។
- បង្ហាញពីនីតិវិធីក្នុងការអនុវត្តការងាររបស់វិជ្ជាជីវៈនីមួយៗ នៅដំណាក់កាលផ្សេងៗគ្នា
- ការសិក្សាទៅលើភាពខ្វះខាត ដើម្បីជាប្រយោជន៍ក្នុងការធ្វើកំណែទម្រង់នាពេលអនាគត។

## ៤. ដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ដើម្បីធ្វើឲ្យកិច្ចការស្រាវជ្រាវសម្រេចគោលដៅ និងជោគជ័យ នៅក្នុងវេលាដ៏ខ្លីនេះក្រុមសិក្សាស្រាវជ្រាវរបស់យើងខ្ញុំបានកំណត់នូវដែនកំណត់ និងទំហំនៃការស្រាវជ្រាវរបស់ខ្លួន។ ការស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើការប្រព្រឹត្តទៅនៃប្រព័ន្ធយុត្តិធម៌នៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ដោយលើកយកនូវករណីសិក្សាមកបន្ថែមលើការស្រាវជ្រាវ។ នៅក្នុងទំហំនៃការស្រាវជ្រាវឯកសារនេះ ជាគោលចម្បងគឺតាមរយៈអត្ថបទច្បាប់មានដូចជា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីលក្ខន្តិកៈនៃមេធាវី ក៏ដូចជាក្រមសីលធម៌ ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា និង អត្ថបទច្បាប់ បទប្បញ្ញត្តិ និងទ្រឹស្តីសំខាន់ៗដែលទាក់ទងនឹងវិស័យយុត្តិធម៌។ កិច្ចការស្រាវជ្រាវនេះ ការស្វែងរកទិន្នន័យគឺតាមរយៈគុណវិស័យ ដោយស្រាវជ្រាវតាមឯកសារតាមបណ្ណាល័យ និង អេឡិចត្រូនិចផ្សេងៗ។ លើសពីនេះទៅទៀតការស្រាវជ្រាវនេះគឺត្រូវបានរៀបចំនូវកម្រងបញ្ជីសំណួរមួយចំនួនដើម្បីធ្វើការសម្ភាសន៍ជាមួយនឹងមេធាវីដែលកំពុងបំពេញការងារនៅគណៈមេធាវី ក៏ដូចជាការចុះសួរផ្ទាល់ជាមួយនឹងចៅក្រម ក្រឡាបញ្ជី និងមន្ត្រីនានានៅឯសាលាដំបូងខេត្តព្រះសីហនុ។

ទន្ទឹមនឹងនេះ តាមរយៈការប្រមូលទិន្នន័យតាមរយៈការសួរផ្ទាល់មាត់ជាមួយមេធាវីជំនាញនិងចៅក្រមដែលប្រកបវិជ្ជាជីវៈនេះជាយូរមកហើយដើម្បីឲ្យយើងខ្ញុំវិភាគនូវគោលគំនិតទាំងនោះបន្ថែម។ ម្យ៉ាងទៀតតាមរយៈការចុះទៅតាមតុលាការខេត្តនោះដើម្បីធ្វើការផ្ទៀងផ្ទាត់នូវការអនុវត្តន៍ផ្ទាល់ ក៏ដូចជាការអង្កេតនូវទិដ្ឋភាពក្នុងអង្គសវនាការពិតផងដែរ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះគឺផ្តោតសំខាន់ទៅលើទិន្នន័យបែបគុណវិស័យ មានឯកសារច្បាប់ ទ្រឹស្តីគោលគំនិតរបស់មេធាវី និងចៅក្រម បូកផ្សំទាំងការចុះអង្កេត និងការអនុវត្តផ្ទាល់នៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងនៅសាលាដំបូងខេត្តព្រះសីហនុ។ ផ្អែកលើការសួរផ្ទាល់មាត់នេះ ក្រុមយើងខ្ញុំក៏បានរៀបចំជាកម្រងសំណួរដែលមានខ្លឹមសារផ្តោតសំខាន់អំពីវិជ្ជាជីវៈ និងឯករាជ្យភាពរបស់តុលាការ និងវិជ្ជាជីវៈមេធាវី ក៏ដូចជាទាក់ទិននឹងស្ថានភាពបច្ចុប្បន្នផងដែរ។ បន្ទាប់មក ក្រុមយើងខ្ញុំនិងធ្វើការសិក្សានៅអត្ថបទច្បាប់ពាក់ព័ន្ធទាំងនោះ និងទ្រឹស្តីមួយចំនួន ជាមួយនិងការអនុវត្តន៍ផ្ទាល់ ដើម្បីជាយានឈានដល់ការធ្វើសំយោគប្រកបដោយគតិយុត្តិ និងសមធម៌។

## ៦. សារប្រយោជន៍នៃការស្រាវជ្រាវ

ការសិក្សាអំពីវិជ្ជាជីវៈ និងការងាររបស់តុលាការ និងវិជ្ជាជីវៈរបស់មេធាវីពិតជាមានសារៈសំខាន់ណាស់ក្នុងការយល់ដឹងអំពីប្រព័ន្ធយុត្តិធម៌នៅព្រះរាជាណាចក្រកម្ពុជា ដោយសារស្ថានភាពបច្ចុប្បន្នការយល់ដឹងផ្នែកយុត្តាធិការនៅមានកម្រិត ជាពិសេសការស្រាវជ្រាវនេះនឹងក្លាយជាយុត្តិសាស្ត្រមួយក្នុងការស្រាយបំភ្លឺរាល់ការយល់ដឹងវិជ្ជាជីវៈរបស់តុលាការ និងវិជ្ជាជីវៈរបស់មេធាវី។

លទ្ធផលនៃការស្រាវជ្រាវនេះ នឹងផ្តល់សារៈប្រយោជន៍ដល់និស្សិតដែលកំពុងសិក្សាផ្នែកនីតិសាស្ត្រដែលមានគោលបំណងចង់សិក្សាស្រាវជ្រាវដើម្បីបន្តអភិវឌ្ឍសមត្ថភាពក៏ដូចជាស្វែងយល់អំពីវិជ្ជាជីវៈក្នុងជំនាញនេះផងដែរ។ ជាពិសេសជាគោលដៅមួយដើម្បីបំពេញនូវសិស្ស-និស្សិតដែលមានបំណងក្នុងការប្រកបការងារក្នុងស្ថាប័នយុត្តិធម៌នេះ។

ស្របពេលដែលប្រទេសជាតិកំពុងធ្វើដំណើរវិវត្តទៅរកនីតិរដ្ឋ លទ្ធផលនៃការស្រាវជ្រាវនេះអាចក្លាយជាមូលដ្ឋានចំណេះដឹងមួយដែលបង្ហាញឱ្យឃើញនូវកង្វះខាតនៃប្រព័ន្ធយុត្តិធម៌ ក៏ដូចជាកំណែទម្រង់នៃប្រព័ន្ធយុត្តិធម៌ទៅថ្ងៃអនាគត។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវនេះ រាប់ទាំងសេចក្តីផ្តើមនៃការស្រាវជ្រាវ អត្ថបទឬឯកសារច្បាប់ ជំនួបផ្ទាល់តាមរយៈការសម្ភាសន៍ផ្ទាល់មាត់ ការអង្កេតសវនាការផ្ទាល់ លទ្ធផលនៃការស្រាវជ្រាវ សេចក្តីសន្និដ្ឋាន និងអនុសាសន៍។ អត្ថបទកិច្ចការស្រាវជ្រាវនេះត្រូវបានបែងចែកជា ៤ (បួន) ជំពូកដូចខាងក្រោមៈ

**ជំពូក១** ដំណើរប្រព្រឹត្តទៅនៃប្រព័ន្ធយុត្តិធម៌នៅប្រទេសកម្ពុជា ដែលក្នុងចំណុចនេះយើងនឹងធ្វើការរៀបរាប់តាំងអំពីប្រព័ន្ធយុត្តាធិការខ្មែរពីសម័យបុរេប្រវត្តិមករហូតដល់បច្ចុប្បន្ននិងកំណែទម្រង់សំខាន់ៗនៃប្រព័ន្ធយុត្តិធម៌ផងដែរ។

**ជំពូក ២** រៀបរាប់អំពីគោលការណ៍ទូទៅ ក្រមសីលធម៌វិជ្ជាជីវៈ និងតួនាទីរបស់មេធាវី ព្រមទាំងការចូលរួមរបស់មេធាវីក្នុងការពង្រឹងវិស័យយុត្តិធម៌។

**ជំពូក ៣** រៀបរាប់អំពីតួនាទីតុលាការ រួមទាំងនីតិវិធីដាក់ពាក្យបណ្តឹងទៅតុលាការ និងនីតិវិធីជំនុំជំម្រះ។

**ជំពូក ៤** ប្រៀបធៀបភាពខុសគ្នារវាងឯករាជ្យភាព និងវិជ្ជាជីវៈរបស់តុលាការ និងឯករាជ្យភាពនៃវិជ្ជាជីវៈរបស់មេធាវី។

ជាចុងក្រោយក្រុមយើងខ្ញុំនឹងធ្វើការវិភាគ និងសំយោគឡើងវិញនូវលទ្ធផលនៃការស្រាវជ្រាវដើម្បីជាការឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវ (ឬ ប្រធានបទស្រាវជ្រាវ) និងគោលបំណងនៃការស្រាវជ្រាវ ព្រមទាំងរំលេចនូវអនុសាសន៍មួយចំនួនដែលផ្អែកទៅលើលទ្ធផលនៃការស្រាវជ្រាវនេះផងដែរ។

អាស្រ័យដូចបានជម្រាបជូនខាងលើ យើងខ្ញុំសូមធ្វើការបកស្រាយទៅលើចំណុចនីមួយៗនៃប្រធានបទនេះដូចតទៅ៖

# ជំពូកទី១

# ដំណើរនៃការប្រព្រឹត្តទៅនៃប្រព័ន្ធយុត្តិធម៌នៅកម្ពុជា

## ផ្នែកទី១៖ ប្រវត្តិនៃការប្រព្រឹត្តទៅនៃប្រព័ន្ធយុត្តិធម៌នៅកម្ពុជា

កម្ពុជា គឺជារដ្ឋមួយដែលគេទទួលស្គាល់ជាអរិយប្រទេសមួយដែលមានវ័យចំណាស់ជាងគេលើពិភពលោក ដោយសារការបន្សល់ទុកនូវតឹកតាងជាប្រាង្គប្រាសាទដ៏ធំស្កឹមស្កៃ មានអាយុកាលវែង ពិសេសពោរពេញទៅដោយចម្លាក់ និងសិលាចារឹកដែលបង្ហាញអំពីឥស្សរភាពនៃបុព្វបុរសខ្មែរដែលមានគំនិតពូកែ អង់អាច និងគំនិតច្នៃប្រឌិតដ៏ប្រណីត។ តាមរយៈចម្លាក់ និងសិលាចារឹកនេះ យើងអាចស្វែងយល់ពីទិដ្ឋភាពនៃសង្គមខ្មែរសម័យនោះដោយរាប់តាំងពីការគ្រប់គ្រងនគរ រហូតដល់ជីវភាពរបស់ប្រជាជន។ ដោយផ្អែកលើការសិក្សានូវឯកសារ និងការពន្យល់នានាទាក់ទងនឹងបញ្ហាទាំងនេះទើប ក្រុមយើងខ្ញុំសុំធ្វើការលើកឡើង និងបកស្រាយអំពីវិស័យយុត្តិធម៌នាសម័យកាលនោះដើម្បីជាការចាប់ផ្តើម និងជាមូលដ្ឋានផ្សារភ្ជាប់ចូលមកក្នុងប្រធានបទសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ។

### ១. យុត្តិធម៌ និងការកាត់ក្តី ក្នុងបុរេសម័យ

**យុត្តិធម៌** ពុំត្រូវបានគេកំណត់ថាមានដើមកំណើតពីណាឱ្យប្រាកដនោះទេ តែបើយោងទៅតាមការយល់ឃើញរបស់មនុស្សដោយផ្អែកលើទស្សនៈសាសនា គេតែងនិយមគិតថា អាទិទេពដែលពួកគេគោរព គឺជាតំណាងនៃអ្វីទាំងអស់ដោយបូករួមទាំងយុត្តិធម៌និងការកាត់ក្តីផង ជាក់ស្តែងបើយោងទេវកថា និងឯកសារប្រវត្តិសាស្ត្រខ្មែរបុរាណយើង របៀបនៃការស្វែងរកយុត្តិធម៌ជូនប្រជារាស្ត្រត្រូវធ្វើឡើងតាមលទ្ធិព្រហ្មញ្ញសាសនាដូចតទៅ៖

បុរេសម័យនៃកម្ពុជា គឺចាប់រាប់ពីការកកើតនគរគោកធ្លោក ឬនគរភ្នំ (ហ្វូណន) រហូតដល់សតវត្សទី១៩ សម័យនគរភ្នំនេះត្រូវបានប្រវត្តិវិទូចាត់ទុកជាសម័យចាប់ផ្តើមនៃការកកើតទឹកដីមហាអាណាចក្រខ្មែរដោយសារនៅសម័យនគរភ្នំ ក្សត្រខ្មែរជាច្រើនអង្គបានដើរវាយយកកុលសម្ព័ន្ធតូចៗក្នុងព្រៃជាច្រើនមកដាក់ក្រោមចំណុះនគរខ្លួនរហូតបង្កើតបានជារដ្ឋមួយដ៏ធំនៅដើមសតវត្សទី១។[១]

លទ្ធិជំនឿ នាសម័យនោះផ្សារភ្ជាប់យ៉ាងខ្លាំងជាមួយនឹង ព្រាហ្មណ៍សាសនា ដោយសារពេលនោះខ្មែរទទួលបានឥទ្ធិពលពីឥណ្ឌាខ្លាំងទាំងលើការដឹកនាំ និងការគោរពប្រតិបត្តិនានា។ ដោយឡែកចំពោះយុត្តិធម៌នាសម័យនគរភ្នំវិញរបៀបនៃការស្វែងរកពិរុទ្ធភាព ចែកចេញទៅតាមសម័យកាល នៅសម័យនគរភ្នំដើម្បីស្វែងរកពិរុទ្ធភាពលើជនណានោះគេចាប់ផ្តើមដោយយកបាយទៅដាក់ពីមុខទេព្តា រួចស្អែកយកទៅឱ្យជននោះហូប ប្រសិនបើជននោះពិតជាបានប្រព្រឹត្តជននោះនឹងហៀរឈាមតាមមាត់ នាសម័យបន្តបន្ទាប់ទៀតមកការស្វែងរកពិរុទ្ធភាព គឺតាមរយៈការថ្លែងសុំដល់អាទិទេពជាសាក្សី ពោលគឺដោយវិធីឱ្យអ្នកដែលជាជនត្រូវចោទនោះទៅផឹកទឹកសម្បថ រួច

ឱ្យដើរកាត់រងើកភ្លើង បើជននោះក្ដៅក្រហល់ក្រហាយមានន័យថាជននោះជាអ្នកប្រព្រឹត្ត ផ្ទុយទៅវិញបើជននោះគ្មានប្រតិកម្មអ្វីទេនោះមានន័យថាជននោះជាមនុស្សស្អាតស្អំ និងសន្មតថាគ្មានពិរុទ្ធភាព[២]។ វិធីនេះក៏មានរំលេចនៅក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរបែបព្រាហ្មណ៍និយម **រឿងរាមកេរ្តិ៍** ផងដែរ គឺនៅចំណុចដែលព្រះរាមឱ្យនាងសីតាដើរកាត់ភ្លើង ដើម្បីបញ្ជាក់ភាពស្មោះត្រង់ ក្រោយពីបាននាំពីក្រុងលង្កាវិញ។ ចំពោះការកាត់ក្ដីវិញ បើយោងតាមសិលាចារឹកសម័យអង្គរ (ស.វទី១១) បានបង្ហាញអំពីឈ្មោះ **វ្រះកំស្ដេចអញ** ដែលជាឋានន្តរនាមសម្រាប់មន្ត្រីជាន់ខ្ពស់ដូចជា មន្ត្រីសង្ឃជាន់ខ្ពស់ សេនាធិបតី ប្រធានតុលាការ ជាដើម។ យោងតាមសិលាចារឹកដដែលបានបង្ហាញថា **ប្រធានតុលាការ** សម័យនោះហៅថា **សភាបតី** ចំណែកសាលាជម្រះក្ដី ឬ តុលាការវិញហៅថា **សភា** តាមពិតពាក្យសភាពុំមែនសម្ដៅលើស្ថាប័នតុលាការទេប៉ុន្តែពាក្យនេះសម្ដៅទៅលើក្រុមបុគ្គលដែលគេហៅថា **អ្នកកាត់ក្ដី**[២]។ ក្រៅពីនេះយើងក៏ដឹងដែរថានាសម័យនោះ ព្រះមហាក្សត្រទ្រង់ជាចៅក្រមកំពូលដែលខ្ពស់ជាងគេបង្អស់ ព្រះអង្គទ្រង់កាត់សេចក្ដីលើរឿងដែលចៅក្រមថ្នាក់ក្រោមពុំអាចដោះបាននិងសម្រេចក្ដីដោយព្រះរាជតម្រិះព្រះអង្គផ្ទាល់ ឬដោយការជំនុំជាមួយមន្ត្រីជាន់ខ្ពស់ក្នុងរាជវាំង។ ចំពោះទោសទណ្ឌបែងចែកជា ៣ ប្រភេទ[៣] គឺ **ទោសស្រាល ទោសមធ្យម** និង **ទោសធ្ងន់**៖ ចំពោះ **ទោសស្រាល** គឺដោយការធ្វើទារុណកម្មលើរាងកាយ **ទោសមធ្យម** គឺដោយការកាត់ច្រមុះ ស្លឹកត្រចៀក ម្រាមដៃជាដើម ចំណែកឯ **ទោសធ្ងន់** វិញគឺកប់ទាំងរស់ និងដាក់ក្នុងព្រៃឱ្យសត្វសាហាវស៊ីតែម្ដង។

បុព្វបុរសខ្មែរ នៅតែដើរបន្តលើវិធានទាំងនេះក្នុងការស្វែងរកយុត្តិធម៌ជូនប្រជារាស្ត្រ រហូតមកដល់សម័យចុងសតវត្សទី១៩ នាពេលដែលមានវត្តមាននៃពួកបញ្ចឹមប្រទេស និងវប្បធម៌ដទៃជ្រាបមកចូលវប្បធម៌ខ្មែរទើបមានការផ្លាស់ប្ដូរពីការកាត់ក្ដីបែបសាសនានិយម មកបែបទំនើបកម្មវិញពោលគឺដោយមានការតាក់តែងកម្រងច្បាប់ ឬការកំណត់នានាដូចកាលសម័យបារាំងចាប់ផ្ដើមមកកម្ពុជាជាដើមនេះ។

### ២. យុត្តិធម៌ និងការកាត់ក្ដី ក្នុងសម័យអាណានិគមបារាំង

សម័យអាណានិគមបារាំង មានរយៈពេលជាង ៩០ឆ្នាំ ដោយគិតពីឆ្នាំ១៨៦៣ ដល់១៩៥៣ នាសម័យនោះកម្ពុជា ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់បារាំងស្ទើរតែទាំងស្រុង ពោលគឺកម្ពុជាខ្លួនឯងពុំមានសិទ្ធិក្នុងការធ្វើអ្វីក្នុងនាមខ្លួនឡើយ ដោយចាំបាច់ត្រូវមានបារាំងជាអ្នកសម្រេចទើបអាចធ្វើបាន។

---

[១] ប្រវត្តិសាស្ត្រប្រទេសកម្ពុជា, អាដេម៉ារ ឡឺក្លែរ, ប៉ារីស,១៩១៣, ទំព័រ៣១-៣៣

[២] **ហ៊ែល ចំរើន**, មរតកយុត្តិធម៌ខ្មែរ, ភ្នំពេញ, ឆ្នាំ២០០៩,ទំព័រ ២៧០-២៨៣

[៣] **ឥន្ទ ឱមសាម៉េង**, វប្បធម៌ទូទៅ, ភ្នំពេញ, ឆ្នាំ២០១២-២០១៣,ទំព័រ ៣៨

សម័យអាណានិគមបារាំងមានព្រះមហាក្សត្រខ្មែរគ្រងរាជ្យគឺ **ព្រះបាទនរោត្តម** ដែលត្រូវបានពួកអាណានិគមបារាំងបង្ខំឱ្យចុះព្រះហស្ថលេខាទទួលស្គាល់ពេញលេញបារាំងជាអាណាព្យាបាលរបស់កម្ពុជានៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣។

ក្រោយពីការសម្រេចដាក់អាណាព្យាបាលពេញលេញលើកម្ពុជាហើយ បារាំងបានធ្វើកំណែទម្រង់យ៉ាងធំលើការផ្លាស់ប្តូរសង្គមខ្មែរជាសង្គមមួយបែបខ្លួន។ នាសម័យនោះ តុលាការខ្មែរ ពុំមានយុត្តិធម៌ពេញលេញទេដោយហេតុតែមានអំពើពុករលួយ កូនក្តីសូកលុយចៅក្រម ប៉ុន្តែក្រោយមានកំណែទម្រង់នេះក៏ត្រូវបានធ្វើទំនើបកម្មដោយបង្កើតឱ្យមានច្បាប់នានាដើម្បីអនុវត្តបូករួមជាមួយនឹងការបង្កើតរចនាសម្ព័ន្ធក្នុងសវនាការបែបបារាំង ចៅក្រមដែលទទួលសំណូកត្រូវទណ្ឌកម្ម ហើយមន្ត្រីតុលាការទទួលបានប្រាក់បៀវត្សត្រឹមត្រូវ ក្រោយមកតុលាការខ្មែរក៏មានចូលរួមពីចៅក្រមកាត់ក្តីជាខ្មែរផង និងចៅក្រមបារាំងផង។ល។[៤] ទោះជាមានការបង្កើតច្បាប់ និង ស្ថាប័នតុលាការត្រឹមត្រូវក៏ដោយក៏យុត្តិធម៌សម័យនោះ ពុំមានតម្លាភាពត្រឹមត្រូវនោះដែរ ជាក់ស្តែងប្រជាពលរដ្ឋខ្មែរទាំងអស់មានកាតព្វកិច្ចជាប់ពន្ធ ហើយបើជននោះគ្មានលុយបង់ឱ្យពួកគេទេ ពួករេស៊ីដង់នឹងធ្វើបាបពួកគាត់ដែលរូបភាពនេះបង្កឱ្យមានភាពអយុត្តិធម៌យ៉ាងខ្លាំង។ អំពើអយុត្តិធម៌នេះហើយទើបធ្វើឱ្យប្រជាជនខ្មែរងើបឈរបោះបោរប្រឆាំងនឹងអំពើនេះរហូតដល់ដណ្តើមបានឯករាជ្យជាតិពេញលេញមកវិញនៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣។

## ៣. យុត្តិធម៌ និងការកាត់ក្តីក្នុងសម័យក្រោយអាណានិគម

ក្រោយពីបានរួចផុតពីអាណានិគមបារាំង កម្ពុជា បានក្លាយជារដ្ឋឯករាជ្យមានសិទ្ធិស្វ័យសម្រេចលើអ្វីគ្រប់យ៉ាង តែទោះជាបារាំងបានដកអាណានិគមរបស់ខ្លួនពីកម្ពុជាក៏ឥទ្ធិពលបារាំងនៅតែមានក្នុងទឹកដីនេះ ជាក់ស្តែងប្រព័ន្ធច្បាប់ និងតុលាការកម្ពុជាមានបរិបទបែបបារាំងស្ទើរទាំងស្រុង។ នាសម័យសង្គមរាស្ត្រនិយម ក្រោមការដឹកនាំរបស់សម្តេចតា បានបង្កើតឱ្យមានអំណាចជាបីគឺ អំណាចនីតិប្បញ្ញត្តិ (រដ្ឋសភា) អំណាចនីតិប្រតិបត្តិ (រដ្ឋាភិបាល) និងអំណាចតុលាការ (ខេមរយុត្តិធម្មាធិការ) ។ នាសម័យនោះ កម្ពុជាមានច្បាប់ព្រហ្មទណ្ឌ និងច្បាប់រដ្ឋប្បវេណី ចំណែកតួអង្គនៅក្នុងតុលាការមាន ដូចជា៖ **ចៅក្រម** (កាលនោះហៅថា **ចាងហ្វាងសាលា**) **ព្រះរាជអាជ្ញា សុភាចារបុរស** (តាមអត្ថន័យគឺស្រដៀងនឹងចៅក្រមស៊ើបសួរ) **ក្រឡាបញ្ជី សមុហបញ្ជី** និង **មេធាវី** ។[៥] យោងតាមសៀវភៅសង្គមវិជ្ជាដដែលនេះ បានលើកឡើងថា ស្ថាប័នតុលាការ មានបែងចែកច្រើនដែលក្នុងនោះមានចែកជាថ្នាក់ទាប និងថ្នាក់ខ្ពស់។ ថ្នាក់ទាបមានដូចជាសាលាលហុ សាលាដំបូង និងសាលាឧក្រិដ្ឋ និងថ្នាក់ខ្ពស់មានសាលាឧទ្ធរណ៍ និងសាលាវិនិច្ឆ័យ។ បទល្មើសដែលមានចែងក្នុងច្បាប់ថាជាកម្រិតទោសអ្វីត្រូវយកទៅឱ្យសាលានោះធ្វើការវិនិច្ឆ័យ សាលាឧទ្ធរណ៍ជាស្ថាប័នទទួលបណ្តឹងឧទ្ធរណ៍ ចំណែកសាលាវិនិច្ឆ័យជាសាលាទទួលរឿងក្តីសារទុក្ខ។ ច្បាប់ខ្មែរសម័យនោះក៏បង្កើតឱ្យមានទោសធំជាងគេដែរគឺ ប្រហារជីវិត ដោយសម័យនោះទោសដែលត្រូវ

សន្មតថាត្រូវកាត់ទោសប្រហារជីវិតគឺបទឧក្រិដ្ឋថ្នាក់៣។ ចំពោះទិដ្ឋភាពនៃយុត្តិធម៌សម័យនោះវិញ គឺមានយុត្តិធម៌ល្អដោយសម័យនោះមន្ត្រីទទួលបានប្រាក់បៀវត្សល្អ ច្បាប់តឹងរឹង និងបណ្ដាមន្ត្រីតុលាការទាំងអស់សុទ្ធតែមានភក្ដីភាពចំពោះយុត្តិធម៌សង្គមជាតិ ប្រជាពលរដ្ឋ រដ្ឋាភិបាល និងព្រះមហាក្សត្រ។

ចំណេរកាលក្រោយមក ទោះជារបបនេះបានប្រព្រឹត្តទៅដោយបរិបូណ៌ក៏ត្រូវបានដួលរលំដោយរដ្ឋប្រហារលន់ នល់ ដែលធ្វើឱ្យស្ថេរភាពប្រទេសធ្លាក់ចុះយ៉ាងខ្លាំង។ ប្រទេសកម្ពុជា បានធ្លាក់ចូលទៅក្នុងភ្លើងសង្គ្រាមស៊ីវិល ហើយរាល់ដំណើរនៃយុត្តិធម៌ត្រូវបាត់បង់ ច្បាប់ដែលមានពីមុនត្រូវបានគេឈប់អនុវត្តហើយច្បាប់ព្រៃត្រូវបានអនុវត្តជាក់ស្ដែងនៅសម័យខ្មែរក្រហម ការសម្លាប់មនុស្សត្រូវបានធ្វើឡើងស្រេចតែចិត្តពពួកឈ្លបក្រោមពាក្យថា **អង្គការ** សម័យនោះ មានរដ្ឋធម្មនុញ្ញដែលចែងពីតុលាការ ប៉ុន្តែយើងពុំដែលមានឃើញវត្តមានមន្ត្រីតុលាការអ្វីទេ។ របបដែលមានលក្ខណៈព្រៃផ្សៃនេះពុំអាចដំណើរការបានយូរទេ នៅថ្ងៃទី៧-មករា-១៩៧៩ របបនេះបានដួលរលំទាំងស្រុងហើយប្រជាជនទាំងអស់បានផុតពីសោជនកម្មដ៏អាក្រក់នេះ។ ការដួលរលំនៃរបបខ្មែរក្រហម ជាការចាប់ផ្ដើមឡើងវិញរបស់កម្ពុជា បន្ទាប់ពីសង្គ្រាមស៊ីវិលដ៏យូរនេះ ក្រោយពីដួលរលំទាំងថ្នាក់ដឹកនាំ និងប្រជាជនសុទ្ធតែមានសុទិដ្ឋិនិយមចង់ឱ្យជាតិមានសន្តិភាព ការអភិវឌ្ឍ និងកែប្រែមុខមាត់ឡើងវិញ។ ក្រោយពីបានបង្រួបបង្រួមជាតិពេញលេញកាលពីឆ្នាំ១៩៩៣ ក្រោមសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីស កម្ពុជាបានបង្រួបបង្រួមគ្នាវិញពេញលេញ ហើយប្រព័ន្ធដឹកនាំនានាត្រូវបានដាក់បន្តឱ្យអនុវត្តវិញ ដូចជាការបង្កើតក្រសួង ស្ថាប័នដឹកនាំនានា ព្រមទាំងលិខិតបទដ្ឋានគតិយុត្តនានាត្រូវបានសភាអនុម័តឱ្យបង្កើតជាបន្តបន្ទាប់ដែលក្នុងនោះយើងឃើញថា រដ្ឋធម្មនុញ្ញថ្មីនៃព្រះរាជាណាចក្រកម្ពុជាទី២ បានកំណត់ពីប្រព័ន្ធតុលាការ ហើយច្បាប់ស្ដីពីការរៀបចំអង្គការតុលាការត្រូវបានបង្កើត ស្ថាប័នតុលាការត្រូវបានបង្កើតជាបន្តបន្ទាប់។ ប្រព័ន្ធតុលាការកម្ពុជា បានផ្លាស់ប្ដូរ និងវិវត្តន៍បន្តិចម្ដងៗរហូតមកដល់សព្វថ្ងៃនេះ។

## ផ្នែកទី២៖ ការប្រព្រឹត្តទៅឡើងវិញ និងកំណែទម្រង់នៃប្រព័ន្ធយុត្តិធម៌នៅកម្ពុជា

### ១. ការប្រព្រឹត្តទៅឡើងវិញនៃប្រព័ន្ធយុត្តិធម៌

### ១.១ ការបង្កើតឱ្យមានតុលាការ និងអយ្យការឡើងវិញ

ការប្រព្រឹត្តទៅឡើងវិញនៃប្រព័ន្ធយុត្តិធម៌ សម្ដៅទៅលើការអនុវត្តឡើងវិញនៃប្រព័ន្ធយុត្តិធម៌ និងស្ថាប័នយុត្តិធម៌កម្ពុជាក្រោយពីបានធ្វើការកែប្រែឡើងវិញរួចមក។ យោងតាមផ្នែកមុនដែលនិយាយអំពីប្រព័ន្ធយុត្តិធម៌របស់ខ្មែរកាលពីបុរេសម័យ រហូតមកដល់ព្រះរាជាណាចក្រកម្ពុជាទី២ បានបង្ហាញថាបុព្វបុរសខ្មែរយើងមានការចាត់តាំងនូវរចនាសម្ព័ន្ធតុលាការដោយខ្លួនឯងតាំងពីដើម និង ចំណេរកាលក្រោយមកបានវិវត្តន៍មកតាមស្តង់ដា

[៤] គេហទំព័រ Wikipedia : ប្រទេសខ្មែរក្រោមអាណានិគមបារាំង

[៥] គីម សែត, សង្គមវិជ្ជា, ភ្នំពេញ, ១៩៦០, ទំព័រ៦៧-៧២

បរទេសដោយសារឥទ្ធិពលនៃអាណានិគមពួកបញ្ចឹមប្រទេស។ នៅក្នុងចំណុចនេះ ក្រុមយើងខ្ញុំមានសុទិដ្ឋិនិយម ក្នុងការបង្ហាញអំពីការបង្កើត និងការវិវត្តន៍ឡើងវិញនៃប្រព័ន្ធតុលាការកម្ពុជាក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ ដែលរបបនេះបានបំផ្លិចបំផ្លាញនូវរចនាសម្ព័ន្ធនៃប្រព័ន្ធយុត្តិធម៌ក្នុងប្រទេសស្ទើរទាំងស្រុង។

ប្រទេសកម្ពុជាយើង ក្រោយថ្ងៃ០៧ ខែមករា ឆ្នាំ១៩៧៩ បានរួចផុតអំពីរបបប្រល័យពូជសាសន៍ដែលជាសោជនកម្មដ៏ធំសម្រាប់ជាតិនិងបង្កើតបានជារបបថ្មីមួយហៅថា **សាធារណរដ្ឋប្រជាមានិតកម្ពុជា** ទឹកដីដ៏អភ័ព្វរបស់យើងបានក្លាយជាទឹកដីដែលមានបែងចែកជាតំបន់កាន់កាប់ដោយបុគ្គលខុសៗគ្នា មានការចល័តកងទ័ពបរទេសក្នុងស្រុក ប្រជាពលរដ្ឋខ្លះបាត់បង់សមាជិកគ្រួសារ ខ្លះបែកគ្នារហូតដល់ឆ្នាំ១៩៩៣ ទើបបានកែប្រែបានមកដូចសព្វថ្ងៃ។ ដោយឡែកបើយើងនិយាយពីប្រព័ន្ធយុត្តាធិការនិងការអនុវត្តច្បាប់វិញ គឺសឹងតែគ្មានដោយសារពេលនោះប្រទេសអស្ថេរភាព គ្មានការប្រកាសច្បាប់គ្រប់គ្រាន់ និងអនុវត្តតែច្បាប់ព្រៃ ហើយតុលាការក៏ពុំទាន់ក្លាយជាកន្លែងដើម្បីដោះស្រាយបញ្ហាជូនប្រជាជនដែរ នាសម័យនោះយើងមានរដ្ឋធម្មនុញ្ញនិងមានក្រុមប្រឹក្សាជាតិដើម្បីសម្រេចលើច្បាប់នានា ចំណែកឯអំណាចតុលាការត្រូវបានបែងចែកទៅកាន់តុលាការបដិវត្តន៍ប្រជាជនដែលបង្កើតឡើងដោយច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងការបង្កើតការិយាល័យរដ្ឋអាជ្ញាយ៉ាងរួសរាន់នៅកំឡុងខែកុម្ភៈ ឆ្នាំ១៩៨៩ ដោយមានតុលាការតាំងនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តក្រុងធំៗមួយចំនួននៅទូទាំងប្រទេស។ រដ្ឋធានីភ្នំពេញជាទីកន្លែងដែលមានតាំងតុលាការគ្រប់ជាន់ថ្នាក់ រួមទាំងតុលាការបដិវត្តន៍ប្រជាជនភ្នំពេញ តុលាការយោធា និងតុលាការជាន់ខ្ពស់នាសម័យនោះដែលគេហៅថា តុលាការជាន់ខ្ពស់ប្រជាជន។ ចៅក្រម និង រដ្ឋអាជ្ញាត្រូវបានចេញលិខិតតែងតាំងដោយគណៈកម្មាធិការបដិវត្តន៍ប្រជាជន។[៦]

## ២. កំណែទម្រង់នៃប្រព័ន្ធយុត្តិធម៌នៅកម្ពុជា

កំណែទម្រង់នៃប្រព័ន្ធយុត្តិធម៌ ត្រូវបានលើកឡើងជាបញ្ហាចោទក្នុងការអភិវឌ្ឍន៍នៃប្រទេសកម្ពុជាពីមួយឆ្នាំទៅមួយឆ្នាំ កំណែទម្រង់នេះគ្របដណ្តប់ទៅលើការប្រព្រឹត្តទៅទាំងអស់នៃដំណើរការយុត្តិធម៌កម្ពុជាដែលបូករួមទាំងការអនុវត្តច្បាប់ ដំណើរការងារក្នុងប្រព័ន្ធតុលាការ និងការផ្តល់សេវាយុត្តិធម៌ដល់ប្រជាពលរដ្ឋ។ ទោះបីជាអំណាចតុលាការជាអំណាចឯករាជ្យដាច់ដោយឡែកពីអំណាចដទៃក៏ដោយ ក៏កំណែទម្រង់នៃប្រព័ន្ធនេះត្រូវបានរាជរដ្ឋាភិបាលយកចិត្តទុកដាក់យ៉ាងខ្លាំងដើម្បីធានាលើតម្លាភាព និងការជឿទុកចិត្តពីមហាជន តាមរយៈការដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលគ្រប់ដំណាក់កាលពីមួយអាណត្តិទៅមួយអាណត្តិ។ គួបផ្សំនឹងនេះដែរ រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងយុត្តិធម៌ បានសម្រេចបង្កើតឱ្យមានគណៈកម្មាធិការដឹកនាំកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ (អនុក្រឹត្យលេខ៩៩១ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣)

[៦] គេហទំព័រ Wikipedia : សាធារណរដ្ឋប្រជាមានិតកម្ពុជា (អង្គចៅក្រម)

ដោយមានរដ្ឋមន្ត្រីជាប្រធាន និងសមាជិក១៦រូប) ដើម្បីដឹកនាំ និងពិនិត្យមើលពីដំណើរការការងារនានាតាមស្ថាប័នយុត្តាធិការនៅទូទាំងប្រទេស។ ជាលទ្ធផល ក្រោយពីបានបង្កើតគណៈកម្មាធិការនេះបានដាក់ចេញនូវគោលនយោបាយក្នុងការពិនិត្យមើល និងពង្រឹងឡើងវិញនូវការអនុវត្តច្បាប់ធំៗបីទាក់ទងនឹងប្រព័ន្ធយុត្តាធិការ ដូចជា៖ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តាមរយៈការផ្សព្វផ្សាយដល់សាធារណជន និងការចុះពិនិត្យផ្ទាល់ដល់ស្ថាប័ន។[៧] ស្របនឹងគ្នានេះដែរ តាមរយៈឯកឧត្តម **ជិន ម៉ាលីន** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាប្រធានលេខាធិការដ្ឋានគណៈកម្មាធិការនេះបានដាក់ចេញនូវគោលការណ៍ **យុទ្ធនាការណ៍១០០ថ្ងៃ** ដើម្បីពង្រឹងឡើងវិញនូវការអនុវត្តការងារក្នុងតុលាការដូចជា៖ ការបង្កើតឱ្យមាន អង្គភាពរដ្ឋបាលតុលាការ ដើម្បីទទួលបន្ទុកការងារ រដ្ឋបាលទាំងអស់របស់តុលាការ ការផ្តល់សេវាយុត្តិធម៌ដល់ប្រជាពលរដ្ឋជាអតិថិជន និងពិសេសអាកប្បកិរិយារបស់មន្ត្រីតុលាការ។ យុទ្ធនាការណ៍នេះសព្វថ្ងៃនៅកំពុងដំណើរការនៅឡើយ និងលទ្ធផលវិជ្ជមានជាច្រើន។

ក្រៅពីការបង្កើតឱ្យមានកំណែទម្រង់នេះ គណៈមេធាវី ដែលជាស្ថាប័នគ្រប់គ្រងវិជ្ជាៈមេធាវីដ៏សំខាន់ក្នុងដំណើរការយុត្តិធម៌បានបង្កើតឱ្យមាន **ក្រមសីលធម៌មេធាវី** និង **បទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបទដ្ឋានទាំងពីរនេះសុទ្ធតែជាបទដ្ឋានដែលកំណត់ពីក្រមសីលធម៌ និង វិន័យក្នុងការអនុវត្តវិជ្ជាជីវៈមេធាវី។ ចំពោះលិខិតបទដ្ឋានទាំងពីរនេះយើងខ្ញុំនឹងធ្វើការបកស្រាយលម្អិតនៅជំពូកបន្ទាប់។

[៧] គេហទំព័រគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌៖ http://www.pscljr.gov.kh/

# ជំពូកទី២

# តួនាទី និងភារកិច្ចមេធាវី

## ផ្នែកទី១៖ សញ្ញាណនៃវិជ្ជាជីវៈមេធាវីនៅកម្ពុជា

ក្នុងចំណោមវិជ្ជាជីវៈច្បាប់ទាំងអស់ វិជ្ជាជីវៈមេធាវីគឺជាវិជ្ជាជីវៈមួយដែលរួមចំណែកយ៉ាងធំធេងក្នុងវិស័យយុត្តិធម៌។ នៅក្នុងរចនាសម្ព័ន្ធតុលាការ ការបែងចែកអំណាចរបស់តួអង្គនៃអង្គសវនាការមានដូចជា៖ **ចៅក្រម** ដែលជាអ្នកសម្រេចសេចក្តី និង កំណត់នូវដំណោះស្រាយផ្លូវច្បាប់ជូនដល់ភាគីបណ្តឹង **ព្រះរាជអាជ្ញា** ដែលជាម្ចាស់នៃបណ្តឹងអាជ្ញា និងជាអ្នកតំណាងរបស់រដ្ឋក្នុងការចោទលើបុគ្គលដែលប្រព្រឹត្តទោសព្រហ្មទណ្ឌនានា និង **ក្រឡាបញ្ជី** ដែលជាអ្នកកត់ត្រាសាកសួរភាគីក្នុងសវនាការជាដើម ក្រៅពីនេះវិជ្ជាជីវៈច្បាប់ខាងលើ វិជ្ជាជីវៈមួយទៀតដែលមានសារៈសំខាន់បំផុតក្នុងការធានាលើយុត្តិធម៌ និងសិទ្ធិស្មើភាពរបស់បុគ្គលនានាគឺ **មេធាវី**។

**<u>និយមន័យ "មេធាវី" តាមវចនានុក្រម និងបទដ្ឋានគតិយុត្តនានា៖</u>**

- វចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ **ជួន ណាត** ចេញផ្សាយ ព.ស.២៥១១ គ.ស.១៩៦៧
  *មេធាវី (បា.សំ) អ្នកប្រាជ្ញ, អ្នកមានមេធា (អ្នកមានគំនិត, អ្នកប្រាជ្ញ)*
- ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ដែលប្រកាសតាមព្រះរាជក្រម នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥
  *មាត្រា២៖ មេធាវី អាចតំណាងក្នុងកូនក្តីតាមការយល់ព្រមពីកូនក្តី ឬជួយកូនក្តីនៅគ្រប់សាលាជម្រះក្តី និងគ្រប់ដំណាក់កាលនៃនីតិវិធី លើកលែងតែមានបទប្បញ្ញត្តិផ្ទុយពីច្បាប់នេះ ជាពិសេសក្នុងរឿងរដ្ឋប្បវេណី ពាណិជ្ជកម្ម ការងារ សង្គមកិច្ច។*
- សៀវភៅ **សង្គមវិជ្ជា** របស់លោកគឹម សែត បោះពុម្ពឆ្នាំ១៩៦០ បានឱ្យនិយមន័យថា ***មេធាវី*** *គឺជាបុគ្គលដែលជួយកូនក្តី កាន់ជើងកូនក្តី និងជួយឱ្យចាងហ្វាងសាលាឱ្យបន្ធូរបន្ថយទោសឱ្យកូនក្តី។*
- ព្រះរាជប្រកាសលេខ៣២ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៣២ បានឱ្យនិយមន័យ និងទទួលស្គាល់អ្នកការពារក្តីថាជា **ស្នាក្តី** ក្រោយមកព្រះរាជប្រកាសនេះ ត្រូវបានធ្វើវិសោធនកម្មដោយព្រះរាជក្រមលេខ៨៤៨ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៥១ ដោយទទួលស្គាល់អ្នកអនុវត្តវិជ្ជាជីវៈ និងហៅថា **អ្នកចះណាយក្តី** ។

**តើនរណាជា មេធាវី ?តើ មេធាវី មានសញ្ញាណមកពីណា ?**

ក្រោយពីបានឈ្វេងយល់អំពីនិយមន័យ និងនិយាមគតិយុត្តនៃពាក្យថា **មេធាវី** ពេលនេះយើងក្រឡេក

មើលអំពីប្រវត្តិ និងសញ្ញាណនៃវិជ្ជាជីវៈមេធាវីវិញម្តង។ យោងតាមប្រវត្តិសាស្ត្ររបស់ពិភពលោក សញ្ញាណនៃវិជ្ជាជីវៈមេធាវី បានលេចឡើងនៅក្នុងសតវត្សទី៥ នៃគ្រឹស្តសករាជនៅឯទីក្រុងអាតែន ប្រទេសក្រិក មេធាវី គឺជាអ្នកប្រកបរបរដោយសេរីក្នុងការជជែកពិភាក្សាដើម្បីឈ្នះ និងដើម្បីផលប្រយោជន៍ ប៉ុន្តែមិនមែនការពារសិទ្ធិដល់អតិថិជនណាមួយ ឬលើកកម្ពស់តម្លៃនៃសីលធម៌ ឬយុត្តិធម៌ឡើយ។[៨] វិជ្ជាជីវៈមេធាវី ត្រូវបានគេផ្សព្វផ្សាយពាសពេញពិភពលោក ហើយក្រោយមកចាប់បានទទួលស្គាល់ដំបូងនៅក្នុងប្រទេសកម្ពុជានាឆ្នាំ១៩៣២ ក្រោយមានការចេញនូវព្រះរាជប្រកាសលេខ៣២ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៣២ ដោយទទួលស្គាល់ **ស្នាក្តី** ជាអ្នកកាន់ក្តីច្បាប់ឆ្លងមកដល់ឆ្នាំ១៩៥១ ពាក្យ **ស្នាក្តី** នេះត្រូវបានវិសោធនកម្មដោយព្រះរាជក្រមលេខ៦៤៨ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៥១ ដោយហៅស្នាក្តី និងអ្នកអនុវត្តវិជ្ជាជីវៈនេះថា **អ្នកថៈណាយក្តី**។ ពាក្យ **ថៈណាយ** ជាពាក្យនាមផ្សំដែលមានន័យថា អ្នកទទួលរ៉ាប់រងជំនួស, អ្នកធានារ៉ាប់រងជំនួស ហេតុនេះពាក្យថា អ្នកថៈណាយក្តី មានន័យថាអ្នកដែលទទួលធ្វើរឿងក្តីក្តាំជំនួយឱ្យអ្នកដែលខ្លួនបានពឹង ដោយដោះដូរនឹងប្រយោជន៍វិញ។[៩]

វិជ្ជាជីវៈមេធាវី ត្រូវបានទទួលស្គាល់ដោយពិភពលោកជាយ៉ាងលង់ណាស់មកហើយ ចំណែកនៅកម្ពុជាទោះជាមានការទទួលស្គាល់នូវវិជ្ជាជីវៈនេះក៏ដោយ ក៏យើងពុំដែលឃើញមានការបង្កើតច្បាប់លក្ខន្តិកៈ ឬឯកសារពាក់ព័ន្ធអ្វីឡើយ ប៉ុន្តែទោះជាយ៉ាងណាវិជ្ជាជីវៈនេះត្រូវបានគេទទួលស្គាល់ថាជាវិជ្ជាជីវៈសេរី ដែលពុំស្ថិតក្រោមអំណាចណាមួយនោះទេ។ ក្នុងសម័យសង្គ្រាមស៊ីវិល អ្នកអនុវត្តវិជ្ជាជីវៈមួយចំនួនបានរត់ទៅនៅប្រទេសបារាំង ចំណែកខ្លះបានរត់ពួន និងលាក់មិនឱ្យដឹងឡើយ លុះមកដល់ឆ្នាំ១៩៩៥ នៅពេលដែលប្រទេសបានសុខសន្តិភាព និង ប្រកាសឱ្យប្រើនូវរដ្ឋធម្មនុញ្ញនាឆ្នាំ១៩៩៣ មក **ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី** ត្រូវបានបង្កើតដោយព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលតាមរយៈព្រះរាជក្រមនេះ ក៏បានបង្កើតឱ្យមាននូវ **គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា** ដែលជាស្ថាប័នឯករាជ្យមួយមានតួនាទីពិនិត្យ ធានា និងតាមដានការអនុវត្តវិជ្ជាជីវៈមេធាវីក្នុងប្រទេសកម្ពុជា។

ក្រោយពីបានបង្កើតនូវលិខិតបទដ្ឋានគតិយុត្ត និងស្ថាប័នគ្រប់ គ្រងមក អ្នកប្រកបវិជ្ជាជីវៈទាំងអស់ត្រូវបានតម្រូវឱ្យចុះឈ្មោះ និង ទទួលស្គាល់សមាជិកភាពពីគណៈមេធាវីទើបអាចអនុវត្តបាន។ គណៈមេធាវី ក្រៅពីការពិនិត្យមើលការអនុវត្តវិជ្ជាជីវៈ ក៏មានតួនាទីផងដែរក្នុងការជួយដល់ជនក្រីក្រនៅតាមតុលាការ តាមរយៈការផ្តល់មេធាវីដោយមិនយកកម្រៃដើម្បីការពារប្រយោជន៍របស់ប្រជាពលរដ្ឋ។

[៨] មេធាវី **ប៊ុន ហុន**, វិជ្ជាជីវៈមេធាវីក្នុងសង្គមកម្ពុជា, ភ្នំពេញ, ២០១៦

[៩] **គឹម សេត**, សង្គមវិជ្ជា, ភ្នំពេញ, ១៩៦០,ទំព័រ៧២

# ផ្នែកទី២៖ វិជ្ជាជីវៈមេធាវី និងលក្ខខណ្ឌនៃការប្រកបវិជ្ជាជីវៈ

## ១. អានុភាពនៃវិជ្ជាជីវៈមេធាវី

អានុភាពនៃវិជ្ជាជីវៈមេធាវី សម្តៅទៅលើការងារ និងការប្រកបវិជ្ជាជីវៈមេធាវី។ តើមេធាវី ស្ថិតក្រោមចំណុះតុលាការរបស់ដែរឬទេ? សំណួរនេះ គឺជាសំណួរដែលមហាជនតែងនិយមសួរ និងតែងគិតថា មេធាវី គឺជាវិជ្ជាជីវៈដែលនៅអមជាមួយតុលាការ ដូចអ្នកអនុវត្តវិជ្ជាជីវៈចៅក្រម ព្រះរាជអាជ្ញាដែរ។ ជាការពិត វិជ្ជាជីវៈមេធាវី ពុំមែនជាវិជ្ជាជីវៈដែលស្ថិតក្រោមក្របខណ្ឌ ឬអំណាចណាមួយឡើយ។ វិជ្ជាជីវៈមេធាវី ត្រូវបានគ្រប់គ្រងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ដែលមានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាជាអ្នកធានានិងឃ្លាំមើលការអនុវត្តវិជ្ជាជីវៈ។

### ១.១ លិខិតបទដ្ឋានទាក់ទងនឹងវិជ្ជាជីវៈមេធាវី

#### ១.១.១ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ត្រូវបានអនុម័តដោយរដ្ឋសភា កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥ និងប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ខែសីហា ឆ្នាំ១៩៩៥ ច្បាប់នេះជាច្បាប់គោល ដែលបានកំណត់យ៉ាងពេញលេញនូវតួនាទី និងកាតព្វកិច្ចរបស់អ្នកអនុវត្តវិជ្ជាជីវៈមេធាវី។ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី មានសរុប១០ជំពូក ស្មើនឹង៩០មាត្រា។

មាត្រា១ កថាខណ្ឌទី១ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បានចែងថា វិជ្ជាជីវៈមេធាវី គឺជាវិជ្ជាជីវៈសេរី និងឯករាជ្យ។ ពាក្យថា **សេរី និងឯករាជ្យ** ក្នុងមាត្រានេះ សម្តៅទៅលើឯករាជ្យភាពរបស់មេធាវី មានន័យថា វិជ្ជាជីវៈមេធាវី មិនស្ថិតក្រោមអំណាចស្ថាប័នរដ្ឋណាទាំងអស់ ហើយអ្នកអនុវត្តមានសេរីភាពគ្រប់គ្រាន់ក្នុងការអនុវត្តការងាររបស់ខ្លួន។ ចំពោះមាត្រាបន្តបន្ទាប់នៃច្បាប់នេះ បានកំណត់អំពីគោលការណ៍របស់ស្ថាប័នគ្រប់គ្រងវិជ្ជាជីវៈ នីតិវិធីនៃការចូលប្រកបវិជ្ជាជីវៈមេធាវី លក្ខខណ្ឌការចូលប្រកបវិជ្ជាជីវៈរបស់មេធាវីបរទេស ការការពារក្តីជូនជនក្រីក្រ ព្រមទាំងកាតព្វកិច្ចរបស់មេធាវី និងទណ្ឌកម្មរដ្ឋបាលជាដើម។ ច្បាប់នេះ មានអាយុជាង ២៥ឆ្នាំ ហើយនិងពុំទាន់បានត្រូវធ្វើវិសោធនកម្មទេ ប៉ុន្តែសព្វថ្ងៃច្បាប់នេះកំពុងស្ថិតក្រោមការពិនិត្យ និងធ្វើបច្ចុប្បន្នភាពដោយក្រុមការងារជំនាញ។

#### ១.១.២ ក្រមសីលធម៌មេធាវី

ក្រមសីលធម៌មេធាវី គឺជាលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងវិជ្ជាជីវៈមេធាវី បន្ទាប់ពីច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ ក្រមសីលធម៌មេធាវី ត្រូវបានអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវី កាលពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២ មានគោលដៅការពារ និងពង្រឹងឯករាជ្យភាព សេរីភាពនៃវិជ្ជាជីវៈមេធាវី និងធានាសេចក្តីថ្លៃថ្នូររបស់មេធាវី ទាំងក្នុង និងក្រៅការប្រកបវិជ្ជាជីវៈ ដើម្បីបង្កើនទំនុកចិត្តពីសាធារណជន[១០]។

ក្រមសីលធម៌មេធាវី មានសរុប ៨ជំពូក ស្មើនឹង៥៧មាត្រា ដែលបទប្បញ្ញត្តិទាំងមូលកំណត់អំពី៖

- សីលធម៌នៃការអនុវត្តវិជ្ជាជីវៈ និងនីតិវិធីនៃការបើកការិយាល័យមេធាវី
- ទំនាក់ទំនងរវាងមេធាវី និងអតិថិជនជាកូនក្តី
- ទំនាក់ទំនងរវាងមេធាវី និង ភាគីម្ខាងទៀត និងសាក្សី
- ទំនាក់ទំនងរវាងអ្នកអនុវត្តវិជ្ជាជីវៈដូចគ្នា (**សហភាតាមេធាវី**)
- ទំនាក់ទំនងរវាងសមាជិក-សមាជិកាជាមួយស្ថាប័នគណៈមេធាវី។

### ១.១.២ បទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

បទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក៏ជាលិខិតបទដ្ឋានមួយពាក់ព័ន្ធនឹងវិជ្ជាជីវៈមេធាវី បទបញ្ជាផ្ទៃក្នុងរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើងសម្រាប់រាល់សមាជិក-សមាជិកា គណៈមេធាវីទាំងអស់ដើម្បីគោរពច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ បទបញ្ជានេះកំណត់ពីៈ

- កាតព្វកិច្ចរបស់សមាជិក-សមាជិកាគណៈមេធាវី ក្នុងការបង់ភាគទាន ការចូលរួមមហាសន្និបាត និងការចូលរួមការបោះឆ្នោតជ្រើសរើសប្រធាន និងក្រុមប្រឹក្សាគណៈមេធាវីតាមអាណត្តិដែលកំណត់ដោយច្បាប់
- នីតិវិធីនៃការចូលប្រកបវិជ្ជាជីវៈមេធាវី និងកាតព្វកិច្ចរបស់មេធាវីកម្មសិក្សា
- គោលនយោបាយហិរញ្ញវត្ថុរបស់ស្ថាប័នគណៈមេធាវី

បទបញ្ជាផ្ទៃក្នុងនេះជាបទបញ្ជាថ្មីទី២របស់គណៈមេធាវី ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី៨ កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ក្រោមអធិបតីភាពលោកមេធាវី **ប៊ុន ហុន** ប្រធានគណៈមេធាវីអាណត្តិទី៩-១០ មានសរុប ១១ជំពូក ស្មើនឹង៤០ប្រការ។ បទបញ្ជាផ្ទៃក្នុងថ្មីនេះ បានធ្វើនិរាករណ៍លើបទបញ្ជាផ្ទៃក្នុងចាស់ដែលបានអនុម័តកាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ផងដែរ។

## ១.២ គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា គឺស្ថាប័នឯករាជ្យមួយដែលបានបង្កើតឡើងកាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៩៥ ដើម្បីដឹកនាំ និងត្រួតពិនិត្យលើការប្រកបរបរវិជ្ជាជីវៈមេធាវីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។[១០] គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា គឺជាស្ថាប័នតែមួយគត់ដែលមានវិសាលភាពអនុវត្តច្បាប់ជាធរមានលើសមាជិក-សមាជិកាដែលកំពុងអនុវត្តវិជ្ជាជីវៈមេធាវីទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយសារតែច្បាប់បានកំណត់គណៈមេធាវី ជាស្ថាប័នឯករាជ្យ ហេតុនេះទើបហិរញ្ញវត្ថុរបស់គណៈមេធាវី មានស្វ័យភាពរបស់ខ្លួនផងដែរ ដែលចំណូលមួយភាគធំ គឺបានមកពីភាគទានរបស់សមាជិក-សមាជិកាដែលបង់ប្រចាំខែ ឬប្រចាំឆ្នាំ និងតាមរយៈការបង់ប្រាក់ដើម្បីចូលរៀនវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។

[១០] មាត្រា១, ក្រមសីលធម៌មេធាវី,គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា,ភ្នំពេញ, ២០១២

គណៈមេធាវី ត្រូវបានដឹកនាំដោយប្រធានមួយរូប និងគ្រប់គ្រងដោយក្រុមប្រឹក្សាចំនួន ៣៣ រូប (ចំនួនក្រុមប្រឹក្សាត្រូវបានកម្រិតតាមចំនួននៃសមាជិកមេធាវី) មានតួនាទីសម្រេចការងារទាំងមូលរបស់គណៈមេធាវី ក៏ដូចជាសម្រេចឱ្យបុគ្គលណាចូលប្រកបវិជ្ជាជីវៈមេធាវី។ ប្រធានគណៈមេធាវី ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតរបស់សមាជិក-សមាជិកាទាំងអស់ក្នុងរយៈពេល០២ឆ្នាំម្តង ដែលការបោះឆ្នោតប្រព្រឹត្តទៅនៅក្នុងមហាសន្និបាតប្រចាំឆ្នាំរបស់គណៈមេធាវីដែលប្រព្រឹត្តទៅនៅ ថ្ងៃទី១៦ ខែតុលារាល់ឆ្នាំ។ ចំពោះក្រុមប្រឹក្សាគណៈមេធាវីវិញ ក៏ត្រូវបានជ្រើសរើសដោយការបោះឆ្នោតរបស់សមាជិកដែរ ដែលការបោះឆ្នោតប្រារព្ធឡើងក្នុងរយៈពេល ៣ឆ្នាំម្តង និងបោះនៅចំថ្ងៃទី១៦ ខែតុលា ដូចគ្នា។ មហាសន្និបាតគណៈមេធាវី គឺជាកម្មវិធីតែមួយគត់របស់គណៈមេធាវីក្នុងរយៈពេល ១ឆ្នាំម្តង។ ការចូលរួមមហាសន្និបាត ត្រូវបានកំណត់ជាកាតព្វកិច្ចសម្រាប់សមាជិកគ្រប់រូបដោយប្រការ៦ នៃបទបញ្ជាផ្ទៃក្នុងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។

ចំពោះកិច្ចការរដ្ឋបាល គណៈមេធាវី មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការសម្រាប់ដឹកនាំការងារទាំងមូលតាមផ្នែក បែងចែកជា ៦ នាយកដ្ឋាន និងមជ្ឈមណ្ឌល ១ ដូចតទៅះ

- នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
- នាយកដ្ឋានការពារក្តីជូនជនក្រីក្រ
- នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
- នាយកដ្ឋានអធិការកិច្ច
- នាយកដ្ឋានសហប្រតិបត្តិការសាធារណៈ និងទំនាក់ទំនងអន្តរជាតិ
- នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ
- មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី

អគ្គលេខាធិការដ្ឋានគណៈមេធាវី ត្រូវបានដឹកនាំដោយអគ្គលេខាធិការចំនួនមួយរូប និង អគ្គលេខាធិការរងចំនួនពីររូប។ នាយកដ្ឋានចំណុះរបស់អគ្គលេខាធិការដ្ឋានអនុវត្តកិច្ចការរបស់ខ្លួនទៅតាមជំនាញ ។

*ឧទាហរណ៍: នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក មានតួនាទីជាអ្នកចេញ-ចូលលិខិត និងសេចក្តីប្រកាសនានារបស់គណៈមេធាវី, ទទួលនិងលក់ពាក្យសុំនានា ដូចជា៖ ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី ពាក្យសុំបើកការិយាល័យមេធាវីចំណែកឯនាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុជាអគ្គហិរញ្ញិកសម្រាប់ទូទាត់ចំណូល និងចំណាយរបស់គណៈមេធាវីជាដើម។*

ក្រៅពីការដឹកនាំ និងត្រួតពិនិត្យការអនុវត្តវិជ្ជាជីវៈ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក៏មានបេសកម្មចម្បងមួយទៀតផងដែរគឺ ការការពារក្តីជូនជនក្រីក្រដោយមិនគិតកម្រៃ ដែលមាននាយកដ្ឋានការពារក្តីជូនជនក្រីក្រ

ជាអ្នកទទួលបន្ទុកការងារនេះ។ ការការពារក្ដីជូនជនក្រីក្រ ត្រូវបានកំណត់ជាកាតព្វកិច្ចរបស់មេធាវីដែលច្បាប់បានកំណត់ឱ្យមេធាវីកម្មសិក្សាគ្រប់រូប ត្រូវតែការពារក្ដីជូនជនក្រីក្រមុននឹងអាចចូលជាមេធាវីពេញសិទ្ធិ។

សរុបសេចក្ដីមកវិញ នាយកដ្ឋានទាំងអស់របស់គណៈមេធាវី គឺជាសេនាធិការនៃស្ថាប័នគណៈមេធាវីក្នុងការចូលរួមជួយការងាររបស់ស្ថាប័ន និងសមាជិក-សមាជិកាទាំងអស់ដែលអនុវត្តវិជ្ជាជីវៈមេធាវី។

## ១.៣ មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈមេធាវី

មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈមេធាវី គឺជាមជ្ឈមណ្ឌលតែមួយគត់នៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានសិទ្ធិក្នុងការបណ្ដុះបណ្ដាលវិជ្ជាជីវៈមេធាវីដល់សិក្ខាកាមដែលបានពេញគ្រប់លក្ខខណ្ឌនៃការចូលប្រកបវិជ្ជាជីវៈមេធាវី។ មជ្ឈមណ្ឌលនេះដើមឡើយមានឈ្មោះថា **មជ្ឈមណ្ឌលបណ្ដុះបណ្ដាល និងសុក្រឹត្យការមេធាវី** ហើយក្រោយមកត្រូវបានប្ដូរមកជា **មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈមេធាវី** ដោយអនុក្រឹត្យលេខ១៣០អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨។ មជ្ឈមណ្ឌលនេះ ស្ថិតក្រោមការគ្រប់គ្រងរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែមានការដឹកនាំរដ្ឋបាលដោយឡែក មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈមេធាវី មាននាយកសាលា និងអគ្គលេខាធិការសាលាសម្រាប់ដឹកនាំមជ្ឈមណ្ឌលទាំងមូល។

គិតមកដល់សព្វថ្ងៃ មជ្ឈមណ្ឌលនេះបានបណ្ដុះបណ្ដាលសិស្សមេធាវីតាមមាត្រា៣១ ចំនួន ១៦ ជំនាន់និងសិក្ខាកាមសុក្រឹត្យការមេធាវីតាមមាត្រា៣២ ចំនួន ០៧ វគ្គ។

# ២. លក្ខខណ្ឌ និងនីតិវិធីនៃការចូលប្រកបវិជ្ជាជីវៈមេធាវី

## ២.១ នីតិវិធីនៃការចូលប្រកបវិជ្ជាជីវៈមេធាវី

លក្ខខណ្ឌនៃការចូលប្រកបវិជ្ជាជីវៈមេធាវីត្រូវបានចែងក្នុងជំពូកទី៣ នៃច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី។ យោងតាមមាត្រា៣១ និងមាត្រា៣២ នៃច្បាប់លក្ខន្តិកៈមេធាវី បានកំណត់ថាបុគ្គលទាំងពីរភេទដែលមានបំណងចង់ចូលប្រកបវិជ្ជាជីវៈមេធាវីអាចដាក់ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី ចំនួន ០២លក្ខខណ្ឌ គឺ៖

**លក្ខខណ្ឌទី១** ការចូលប្រកបវិជ្ជាជីវៈមេធាវីតាមរយៈការប្រឡងជ្រើសរើសឱ្យចូលរៀនវគ្គបណ្ដុះបណ្ដាលវិជ្ជាជីវៈមេធាវីតាមមាត្រា៣១ នៃច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី។

- **មាត្រា៣១**: ជនដែលអាចចូលប្រកបវិជ្ជាជីវៈមេធាវីបាន ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១- ត្រូវមានសញ្ជាតិខ្មែរ

២- ត្រូវមានបរិញ្ញាប័ត្រច្បាប់ ឬសញ្ញាប័ត្រច្បាប់ដែលបានប្រកាសថាមានតម្លៃសមមូល

៣- ត្រូវមានវិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវី។ វិញ្ញាបនប័ត្រសម្បទារខាងវិជ្ជាជីវៈមេធាវីនេះ ត្រូវចេញដោយមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈមេធាវី។ ការរៀបចំ និងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលទៅនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

[១១] ផែនការណ៍យុទ្ធសាស្ត្ររបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា,ភ្នំពេញ,២០១៩

៤- មិនដែលត្រូវបានផ្តន្ទាទោសជាបទមជ្ឈិម ឬបទឧក្រិដ្ឋ ឬផ្តន្ទាទោសជាបទវិន័យ ឬផ្តន្ទាទោសជាបទរដ្ឋបាលដូចជាការលុបឈ្មោះចោល ឬការបញ្ឈប់ពីមុខងារ ការហូតងារអំពីអំពើផ្ទុយនឹងកិត្តិយស ឬអំពើមិនស្អាតស្អំ។ មិនត្រូវធនក្ស័យផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ។

ជាទូទៅ ការដាក់ពាក្យចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣១ នេះត្រូវបានគេដឹងថាជាលក្ខខណ្ឌនៃការចូលប្រកបវិជ្ជាជីវៈតាមរយៈការប្រឡងជ្រើសរើសប្រចាំឆ្នាំដូចទៅនឹងវិជ្ជាជីវៈចៅក្រម ព្រះរាជអាជ្ញា និង ក្រឡាបញ្ជី។ លក្ខខណ្ឌនៃការប្រកបវិជ្ជាជីវៈមេធាវីដោយការប្រឡងនេះត្រូវប្រព្រឹត្តឡើងក្នុងរយៈពេល ១ឆ្នាំម្តង ដោយការប្រឡងវិញ្ញាសាសរសេរ និងវិញ្ញាសាផ្ទាល់មាត់ ចំណែកឯចំនួននៃការជ្រើសរើសសិស្សដែលជាប់ស្ថាពរ និងអនុញ្ញាតឱ្យចូលរៀនត្រូវអនុលោមតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី។ ចំពោះការប្រឡងនេះមានលក្ខខណ្ឌពិសេសមួយគឺគ្រប់បុគ្គលទាំងពីរភេទដែលមានបរិញ្ញាប័ត្រផ្នែកច្បាប់ ឬទើបតែបញ្ចប់បរិញ្ញាប័ត្រច្បាប់អាចដាក់ពាក្យប្រឡង និងបំពេញឱ្យគ្រប់តាមលក្ខខណ្ឌដែលកំណត់ដោយគណៈមេធាវី។ សិស្សមេធាវី ដែលបានជាប់ជាស្ថាពរត្រូវទទួលបានការសិក្សារយៈពេល១២ខែ នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីដែលស្ថិតនៅជាមួយរាជបណ្ឌិត្យសភាតុលាការ។ សិស្សដែលបានរៀនចប់សព្វគ្រប់តាមកម្ម៉ុមនៃម៉ោងសិក្សាត្រូវឆ្លងកាត់ការប្រឡងបញ្ចប់ម្តងទៀតដែលបែងចែកជាវិញ្ញាសាសរសេរ និងវិញ្ញាសាផ្ទាល់មាត់ដដែល។ ក្រោយពីបានជាប់ការប្រឡងទាំងនេះហើយ សិស្សមេធាវីទាំងនេះមានភារកិច្ចក្នុងការបំពេញកម្មសិក្សារបស់ខ្លួនមុនក្លាយជាមេធាវីពេញសិទ្ធិ។

<u>**លក្ខខណ្ឌទី២**</u> នៃការចូលប្រកបវិជ្ជាជីវៈគឺតាមរយៈការដាក់ពាក្យចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី៖

- **មាត្រា៣២**: មិនបាច់មានវិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវី និងមិនចាំបាច់មានបរិញ្ញាប័ត្រច្បាប់៖

- ចៅក្រម ដែលបានបម្រើការងារក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី ៥ឆ្នាំ និងអតីតចៅក្រមដែលមានសញ្ញាប័ត្រមធ្យមសិក្សាច្បាប់ហើយបានបម្រើក្នុងវិជ្ជាជីវៈច្បាប់លើសពី ២ឆ្នាំ។

មិនចាំបាច់មានវិញ្ញាបនប័ត្រសម្បទាវិជ្ជាជីវៈមេធាវី៖

- អ្នកមានបរិញ្ញាបត្រច្បាប់ ហើយដែលបានបម្រើការងារក្នុងវិស័យច្បាប់ ឬតុលាការលើសពី ២ឆ្នាំ
- មេធាវីដែលមានសញ្ជាតិដើមជាខ្មែរ ដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៅប្រទេសក្រៅ
- អ្នកមានសញ្ញាប័ត្របណ្ឌិតច្បាប់

ចំពោះការដាក់ពាក្យចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២ ត្រូវបានគេស្គាល់ថាជាលក្ខខណ្ឌនៃការចូលប្រកបវិជ្ជាជីវៈមេធាវីតាមរយៈបទពិសោធន៍ផ្នែកច្បាប់ដូចមានបញ្ញត្តិក្នុងមាត្រា៣២ នៃច្បាប់លក្ខន្តិកៈមេធាវី។ ជាទូទៅការចូលប្រកបតាមលក្ខខណ្ឌនេះ ត្រូវឆ្លងកាត់ច្រើនដំណាក់កាល និងមានភាពខុសគ្នាពីមាត្រា៣១ ដោយសារបេក្ខជនដែលដាក់ចូលមកតាមវិធីនេះ ពុំតម្រូវឱ្យឆ្លងការប្រឡងវិញ្ញាសាសរសេរនោះទេ ប៉ុន្តែបេក្ខជនត្រូវឆ្លង

កាត់ដំណាក់កាលដូចជា៖ ការចុះអធិការកិច្ចដោយក្រុមអធិការកិច្ចរបស់គណៈមេធាវី ការសម្ភាសន៍ផ្ទាល់មាត់ និងការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី មានតែបេក្ខជនដែលទទួលបានការសម្រេចជាឯកច្ឆ័ន្ទពីក្រុមប្រឹក្សាគណៈមេធាវីទេ ដែលមានសិទ្ធិទទួលប្រកបវិជ្ជាជីវៈមេធាវី ដោយត្រូវជាប់កាតព្វកិច្ចមេធាវីកម្មសិក្សារយៈពេល ១២ខែជាមួយនឹងគ្រូកម្មសិក្សា។ មេធាវីកម្មសិក្សាតម្រូវឱ្យជ្រើសរើសគ្រូកម្មសិក្សាមួយរូបដែលជាសមាជិកគណៈមេធាវីមានបទពិសោធន៍ក្នុងវិជ្ជាជីវៈមេធាវីនេះ ដើម្បីពិនិត្យកម្មសិក្សា និងអមជាមួយពេលឡើងសវនាការមេធាវី កម្មសិក្សាដែលស្ថិតក្នុងកាតព្វកិច្ចកម្មសិក្សារយៈពេល១២ខែនេះ មានកាតព្វកិច្ចធ្វើរបាយការណ៍កម្មសិក្សារបស់ខ្លួនមកគណៈមេធាវីទៅតាមកាលកំណត់ ដើម្បីឱ្យក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងសម្រេចឱ្យក្លាយជាមេធាវីពេញសិទ្ធិ។

ការបណ្តុះបណ្តាលសម្រាប់សិក្ខាកាមមេធាវីតាមមាត្រា៣២ស្ថិតក្រោមមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីដដែល វគ្គសិក្សានេះត្រូវបានហៅថា **វគ្គសុក្រឹត្យការ**។ សព្វថ្ងៃមជ្ឈមណ្ឌលនេះបានបណ្តុះបណ្តាលសិក្ខាកាមសុក្រឹត្យការមេធាវីចំនួន ៧ វគ្គរួចមកហើយ សិក្ខាកាមនៃវគ្គនីមួយៗត្រូវសិក្សាលើមុខវិជ្ជាប្រមាណ ១០ មុខវិជ្ជាដែលមានថេរវេលាប្រមាណ១៨០ម៉ោង។ ការសិក្សាវគ្គបណ្តុះបណ្តាលក្នុងវគ្គសុក្រឹត្យការមេធាវីតម្រូវឱ្យគ្រប់សិក្ខាកាមអនុវត្តតាមម៉ោងនិងវិន័យដែលប្បញ្ញត្តិដោយមជ្ឈមណ្ឌល ហេតុនេះ បើសិក្ខាកាមណាមិនបានបំពេញគ្រប់ម៉ោងសិក្សាទេ ត្រូវរៀនរហូតបង្គ្រប់ម៉ោងតាមការកំណត់ទើបអាចក្លាយជាមេធាវីពេញសិទ្ធិបាន។

## ២.២ ការសិក្សាវគ្គបណ្តុះបណ្តាល និងការចុះកម្មសិក្សា

### ២.២.១ ការសិក្សាវគ្គបណ្តុះបណ្តាល

ដូចដែលបានបញ្ជាក់នៅផ្នែកខាងលើ ការសិក្សាសម្រាប់សិស្សមេធាវី និងសិក្ខាកាមសុក្រឹត្យការមេធាវីត្រូវបែងចែងដោយឡែក ប៉ុន្តែមុខវិជ្ជាដែលគេសិក្សាពុំសូវមានភាពខុសគ្នាឡើយ។ ជាទូទៅកម្មវិធីសិក្សាសម្រាប់សិស្សមេធាវីត្រូវបានកំណត់ដោយការិយាល័យសិក្សានៃមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី មុខវិជ្ជាដែលត្រូវបានកំណត់ឱ្យសិក្សា សម្រាប់សិស្សមេធាវីដែលចូលរៀនតាមមាត្រា ៣១ មានដូចជា៖

- ការវិភាគលើក្រមច្បាប់ (ការវិភាគក្រមនីតិវិធីរដ្ឋប្បវេណីក្នុងនីតិវិធីបណ្តឹង និងតំណាងរឿងក្តី...)
- នីតិវិធីព្រហ្មទណ្ឌ (បទល្មើសពិសេស និងគោលការណ៍ព្រហ្មទណ្ឌ...)
- នីតិវិធីរដ្ឋប្បវេណី (ការអនុវត្តដោយបង្ខំ ការចាត់ចែងរក្សាការពារ សិទ្ធិប្រាតិភោគប្រក្សត្យ....)
- នីតិវិធីតុលាការ (ការអនុវត្តសាលក្រម ការជម្រះក្តី និងបន្សុតកម្ម...)
- នីតិរដ្ឋបាល
- នីតិពាណិជ្ជកម្ម និងការងារ (នីតិក្រុមហ៊ុន មជ្ឈត្តកម្មពាណិជ្ជកម្ម វិវាទការងារ...)

- បច្ចេកទេសការពារក្ដីក្នុងរឿងព្រហ្មទណ្ឌ និងរឿងរដ្ឋប្បវេណី
- ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី ក្រមសីលធម៌មេធាវី និងបទបញ្ជាផ្ទៃក្នុងគណៈមេធាវី
- ច្បាប់អន្តរជាតិ និងច្បាប់សិទ្ធិមនុស្ស

ចំពោះមុខវិជ្ជាសម្រាប់វគ្គបណ្ដុះបណ្ដាល សម្រាប់សិក្ខាកាមវគ្គសុក្រឹត្យការមេធាវីតាមមាត្រា៣២ វិញការសិក្សាត្រូវបានបែងចែកជា ៧មុខវិជ្ជាធំៗ ស្មើនឹង ១៨០ម៉ោងដូចជា៖

- នីតិវិធីព្រហ្មទណ្ឌ (ព្រហ្មទណ្ឌពិសេស និងគោលការណ៍ទូទៅ, មូលដ្ឋាននៃជម្រើសការចោទប្រកាន់របស់ព្រះរាជអាជ្ញា...)
- នីតិវិធីរដ្ឋប្បវេណី (ការអនុវត្តដោយបង្ខំ, ការចាត់ចែងរក្សាការពារ, នីតិវិធីបណ្ដឹង, សន្តតិកម្ម...)
- បច្ចេកទេសការពារក្ដី
- ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី
- ក្រមសីលធម៌មេធាវី និងបទបញ្ជាផ្ទៃក្នុងគណៈមេធាវី
- ច្បាប់អន្តរជាតិ
- ច្បាប់ស្ដីពីសិទ្ធិមនុស្ស

### ២.២.២ ការចុះកម្មសិក្សា

ការចុះកម្មសិក្សា ត្រូវបានកំណត់ជាកាតព្វកិច្ចសម្រាប់មេធាវីកម្មសិក្សាគ្រប់រូបដោយច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី។ យោងតាមមាត្រា៣៥ នៃច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី បានកំណត់ឱ្យគ្រប់កម្មសិក្សាការីមេធាវីទាំងអស់ត្រូវជាប់កាតព្វកិច្ចកម្មសិក្សារយៈពេល១ឆ្នាំជាមួយនឹងគ្រូកម្មសិក្សាដែលជាសមាជិករបស់គណៈមេធាវីលើកលែងមានករណីពិសេសដែលមេធាវីកម្មសិក្សាត្រូវបានអនុញ្ញាតឱ្យផុតពីកម្មសិក្សា។ ការសម្រេចឱ្យរួចផុតពីកម្មសិក្សាត្រូវបានសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី និងមានសេចក្ដីសម្រេចពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

មុននឹងអាចធ្វើកម្មសិក្សា មេធាវីត្រូវបំពេញឱ្យគ្រប់តាមលក្ខខណ្ឌរបស់មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈមេធាវី និងគណៈមេធាវី និងត្រូវឆ្លងកាត់ការយល់ឃើញពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងធ្វើសច្ចាប្រណិធាននៅសាលាឧទ្ធរណ៍មុននឹងអាចអនុវត្តប្រកបវិជ្ជាជីវៈ និងចាប់ផ្ដើមកម្មសិក្សាបាន។ ពាក្យសម្បថសម្រាប់មេធាវីថ្មីក្នុងការធ្វើសច្ចាប្រណិធាន មានបញ្ញត្តិនៅក្នុងមាត្រា៣៤ នៃច្បាប់លក្ខន្តិកៈមេធាវី។

ក្នុងរយៈពេល ០១ឆ្នាំនៃកម្មសិក្សានេះ កម្មសិក្សាការីមេធាវី មានកាតព្វកិច្ចដូចតទៅ៖

- ត្រូវស្នើសុំគ្រូកម្មសិក្សាមួយរូប ដែលជាសមាជិកគណៈមេធាវីតាមរយៈកិច្ចសន្យាសហការ

- ក្នុងរយៈពេលកម្មសិក្សា កម្មសិក្សាការី មានកាតព្វកិច្ចត្រូវឡើងការពារសំណុំរឿងព្រហ្មទណ្ឌ ០៣រឿង និង សំណុំរឿងរដ្ឋប្បវេណី ៣រឿង (ការឡើងការពារក្នុងកំឡុងសវនាការ ត្រូវអមដោយគ្រូកម្មសិក្សា)[១២]
- ធ្វើជាមេធាវីតំណាងក្នុងកិច្ចសន្យា និងចូលរួមសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលផ្នែកច្បាប់មួយចំនួន
- នៅពេលបញ្ចប់កម្មសិក្សា កម្មសិក្សាការី ត្រូវធ្វើរបាយការណ៍កម្មសិក្សា (នៅក្នុងរបាយការណ៍នេះ មានភ្ជាប់ពីព័ត៌មាន សាលក្រម លិខិតចាត់តាំង លិខិតប្រគល់សិទ្ធិ កិច្ចសន្យា និងសំណុំរឿងដែលកម្មសិក្សាការីបានធ្វើជាអំណះអំណាន និងដាក់មកគណៈមេធាវីតាមរយៈនាយកដ្ឋានបុគ្គលិក និងរដ្ឋបាល។
- របាយការណ៍ដែលបានដាក់មក និងមានគ្រប់លក្ខខណ្ឌតាមការកំណត់របស់គណៈមេធាវី នឹងត្រូវបានលើកយកមកឱ្យក្រុមប្រឹក្សាគណៈមេធាវី ពិនិត្យ និងសម្រេច ដើម្បីឱ្យក្លាយជាមេធាវីពេញសិទ្ធិ។

ការអនុវត្តកាតព្វកិច្ចកម្មសិក្សានេះ ធ្វើឡើងសម្រាប់គ្រប់កម្មសិក្សាការី មុននឹងអាចប្រកបវិជ្ជាជីវៈមេធាវីពេញសិទ្ធិ។ សម្រាប់សិស្សមេធាវីតាមមាត្រា៣១ ត្រូវចាប់ផ្តើមកម្មសិក្សារបស់ខ្លួនក្រោយទទួលលទ្ធផលស្តាពរពីការប្រឡងបញ្ចប់ការសិក្សា ចំណែកសិក្ខាកាមសុក្រឹត្យការមេធាវីតាមមាត្រា៣២ ត្រូវចាប់ផ្តើមកម្មសិក្សារបស់ខ្លួននៅពេលក្រុមប្រឹក្សាគណៈមេធាវីបានសម្រេចឱ្យបេក្ខជន ឬបេក្ខនារីនោះចូលប្រកបវិជ្ជាជីវៈ។

## **ផ្នែកទី៣៖ ការចូលប្រកបវិជ្ជាជីវៈរបស់មេធាវីបរទេសនៅកម្ពុជា**

### **១. នីតិវិធីនៃការចូលប្រកបវិជ្ជាជីវៈ ឬបើកការិយាល័យមេធាវីបរទេស**

មេធាវីបរទេស គឺជាជនបរទេសដែលបានចុះបញ្ជីត្រឹមត្រូវជាមេធាវីក្នុងគណៈមេធាវីនៃប្រទេសកំណើត ឬប្រទេសដទៃ ក្រៅពីព្រះរាជាណាចក្រកម្ពុជា។ យោងតាមសេចក្តីសម្រេចលេខ០០៤ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦របស់គណៈមេធាវី ស្តីពីការគ្រប់គ្រប់ការប្រកបវិជ្ជាជីវៈមេធាវីបរទេស មេធាវីបរទេស អាចធ្វើការចុះឈ្មោះចូលប្រកបជាមេធាវីនៅកម្ពុជា និងក្លាយជាសមាជិកគណៈមេធាវីកម្ពុជាបាន គឺមេធាវីនោះបានប្រកបវិជ្ជាជីវៈនៅប្រទេសដើមយ៉ាងតិច ៥ឆ្នាំ និងកាលដែលគណៈមេធាវីនៃប្រទេស ឬតំបន់ដែលជននោះរស់នៅ បានធ្វើការចុះអនុស្សារណៈយោគយល់ជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាក្នុងការអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈ និងបើកការិយាល័យជាបដិទាន។ លក្ខខណ្ឌនេះក៏ត្រូវបានអនុវត្តសម្រាប់ក្រុមហ៊ុនមេធាវីបរទេស ណាដែលមានបំណងចង់បើកនៅកម្ពុជាដូចគ្នា ដែលកិច្ចការទាំងអស់នេះគឺជាកិច្ចការងាររបស់គណៈមេធាវី ដែលជាស្ថាប័នតែមួយគត់ក្នុងការអនុញ្ញាតមេធាវី និងក្រុមហ៊ុននោះ ឱ្យប្រកបវិជ្ជាជីវៈ ឬបើកសាខានៅកម្ពុជាដោយស្របច្បាប់។

មេធាវីបរទេស ដែលត្រូវបានអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈមេធាវី និងសមាជិកគណៈមេធាវីកម្ពុជា ពុំអាចឈរជាតំណាងរបស់កូនក្តីបានឡើយ ប៉ុន្តែអាចអមជាមួយមេធាវីខ្មែរបាន។ (មាត្រា៥ ច្បាប់លក្ខន្តិកៈមេធាវី

[១២] សេចក្តីណែនាំលេខ១៥៥៤/គម/១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ របស់គណៈមេធាវីស្តីពីកាតព្វកិច្ចរបស់គ្រូកម្មសិក្សានិងកម្មសិក្សាការី

## ២. សមត្ថកិច្ចរបស់គណៈមេធាវីក្នុងការអធិការកិច្ចលើមេធាវីបរទេសខុសច្បាប់

ករណីមេធាវីបរទេស ឬក្រុមហ៊ុនបរទេសណាដែលមិនអនុវត្តតាមលក្ខខណ្ឌនេះទេ គណៈមេធាវី មានសមត្ថកិច្ចគ្រប់គ្រាន់ក្នុងការចុះទៅពិនិត្យតាមរយៈការចុះអធិការកិច្ចដោយមន្ត្រីជំនាញ ឬ ធ្វើការប្តឹងទៅតុលាការ (ប្រសិនបើលក្ខខណ្ឌតម្រូវ)។ គណៈមេធាវី ក៏មានសិទ្ធិផងដែរក្នុងការព្យួរវិញ្ញាបនប័ត្ររបស់មេធាវីបរទេស ឬលុបឈ្មោះចេញពីបញ្ជីសមាជិក ព្រមទាំងអាចបិទឬលុបចោលការិយាល័យមេធាវីបរទេសណាដែលមិនបានបំពេញលក្ខខណ្ឌទាំងអស់នេះផងដែរ។ ចំពោះកិច្ចអន្តរាគមន៍តាមផ្លូវតុលាការ មានចែងក្នុងមាត្រា៥៩-៦៧ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ដែលបានប្រកាសកាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៩។

## ផ្នែកទី៤៖ តួនាទីរបស់មេធាវីក្នុងសង្គម

## ១. ការការពារក្តីឯកជនជូនអតិថិជន នៅក្នុងតុលាការ

វិជ្ជាជីវៈមេធាវី គឺជាវិជ្ជាជីវៈសេរី និងឯករាជ្យ ពីព្រោះវិជ្ជាជីវៈនេះពុំត្រូវបានកំណត់ឱ្យស្ថិតក្រោមស្ថាប័ន ឬអំណាចណាទាំងអស់ ហេតុនេះហើយទើបវិជ្ជាជីវៈមេធាវី ពុំមានក្របខណ្ឌ ឬការកំណត់អាយុការងារដូចមន្ត្រីក្របខណ្ឌឡើយ។ យើងអាចនិយាយបានថា វិជ្ជាជីវៈមេធាវី ជាវិជ្ជាជីវៈឯកជន ព្រោះមេធាវីមានសិទ្ធិគ្រប់គ្រាន់ក្នុងការជ្រើសរើសកូនក្តី និងសំណុំរឿងក្តីមកធ្វើ ការជ្រើសរើសរឿងក្តីនេះហើយជាចំណុចពិសេសនៃវិជ្ជាជីវៈនេះ។ ទំនាក់ទំនងរវាងមេធាវី និងអតិថិជន គឺជាទំនាក់ទំនងតាមកិច្ចសន្យា ហើយកិច្ចសន្យានោះមានប្រភពពីទំនៀមទំលាប់ និងការព្រមព្រៀងគ្នាទៅវិញទៅមក។ មេធាវី គឺជាអ្នកកាន់តំណែងការពារ និងតំណាងឱ្យអតិថិជន។[១៣] ក្រៅពីការការពារក្តីជូនអតិថិជន មេធាវី ក៏ជាអ្នកប្រឹក្សាយោបល់ផ្នែកច្បាប់ ជាតំណាងផ្នែកច្បាប់របស់ក្រុមហ៊ុន ឬស្ថាប័នរដ្ឋ និងឯកជននានា និងជាតំណាងក្នុងកិច្ចសន្យា ឬជាអ្នកតាក់តែងកិច្ចសន្យាផងដែរ។

## ១.១ ការប្រឹក្សាយោបល់ផ្នែកច្បាប់

ការប្រឹក្សាយោបល់ផ្នែកច្បាប់ គឺជាជំហានដំបូងនៃទំនាក់ទំនងរបស់មេធាវី និងអតិថិជន។ ដើម្បីប្រឹក្សាយោបល់ មេធាវី ត្រូវជួបដោយផ្ទាល់ជាមួយកូនក្តី និងស្តាប់ពីអង្គហេតុដែលកូនក្តីបានជួប និងចម្ងល់ផ្នែកច្បាប់[១៣] នានា ជាទូទៅ ការពិគ្រោះនេះ គឺជាកិច្ចដំបូងដែលមេធាវីត្រូវធ្វើ ពោលគឺក្រោយពីបានស្តាប់ និងវិភាគអង្គហេតុ មេធាវី ត្រូវរំលេចនូវអង្គច្បាប់ និងលក្ខខណ្ឌគតិយុត្តពាក់ព័ន្ធនឹងអង្គហេតុ ឱ្យអតិថិជនបានដឹង និងពន្យល់ពីនីតិវិធីច្បាប់ដើម្បីប្រាប់ទៅអតិថិជនវិញ។

ការប្រឹក្សាយោបល់នេះ ក៏ជាដំណាក់កាលទី១ ដែលមេធាវីត្រូវធ្វើផងដែរជាមួយនឹងអតិថិជនមុននឹងឈានទៅដល់ការធ្វើកិច្ចសន្យាព្រមព្រៀង និងកំណត់កម្រៃការពារ។ ទន្ទឹងនឹងគ្នានេះ ជនក្រីក្រ ក៏អាចទទួលបានការពិគ្រោះយោបល់ពីមេធាវីដោយឥតគិតថ្លៃផងដែរ ដោយគោលការណ៍នេះត្រូវបានអនុវត្តដោយគណៈមេធាវី ហេតុ

នេះ រាល់ជនក្រីក្រដែលមានវិបត្តិ ឬចម្ងល់ផ្លូវច្បាប់អាចទាក់ទងស្នើសុំពិគ្រោះយោបល់ផ្លូវច្បាប់បានតាមរយៈនាយកដ្ឋានការពារក្តីជូនជនក្រីក្រនៃគណៈមេធាវីបាន ដែលការពិគ្រោះយោបល់នេះ ពុំតម្រូវឱ្យមានការបង់ប្រាក់ឡើយ។

## ១.២ ការការពារក្តីជូនកូនក្តីនៅតុលាការ

មេធាវី គឺជាតំណាងរបស់អតិថិជននៅក្នុងតុលាការ ដែលការតំណាងនេះអាចធ្វើបាន លុះត្រាមានកិច្ចសន្យាព្រមព្រៀងរវាងអតិថិជន និងមេធាវី។ នៅពេលមានការព្រមព្រៀងគ្នា មេធាវី មានកាតព្វកិច្ចមួយគឺត្រូវរក្សាអាថ៌កំបាំងរបស់កូនក្តី និងត្រូវចាត់ទុកប្រយោជន៍របស់កូនក្តីដូចជាប្រយោជន៍ខ្លួនដែរ។ កូនក្តីដែលសម្រេចចិត្តពឹងពាក់មេធាវី គឺដោយមានការជឿទុកចិត្តលើសមត្ថភាពរបស់យើង ហេតុនេះ មេធាវី ចាំបាច់ត្រូវកសាងនូវទំនុកចិត្តរបស់កូនក្តីឱ្យកាន់តែជឿជាក់លើខ្លួន បន្ថែមពីលើនេះ មេធាវី ត្រូវមានទំនួលខុសត្រូវក្នុងនាមជាអ្នកចេះច្បាប់ និងមិនត្រូវប្រើឧបាយកលក្នុងការទាញប្រយោជន៍ពីកូនក្តីជាដាច់ខាត។[១៤]

### ១.២.១ ការការពារជូនកូនក្តីក្នុងសំណុំរឿងរដ្ឋប្បវេណី

ការការពារក្តីជូនកូនក្តីក្នុងសំណុំរឿងរដ្ឋប្បវេណី គឺជាការការពារលើករណីវិវាទឯកជន ឬ ប្រភេទនៃរឿងក្តីដែលបានកើតឡើងដោយសារសកម្មភាពដែលកើតឡើងក្នុងសកម្មភាពនៃទំនាក់ទំនងរវាងបុគ្គល និងបុគ្គលមួយទៀត។[១៥] នៅក្នុងរឿងរដ្ឋប្បវេណី មេធាវីតំណាងរបស់កូនក្តីត្រូវបានហៅថា **មេធាវីតំណាងដោយអាណត្តិ** ។ នីតិវិធីនៃការតំណាងដោយអាណត្តិ ត្រូវបានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីត្រង់គន្ថីទី៤ ជំពូកទី២ ផ្នែកទី៤ (មាត្រា **៣៦៤-៣៦៨**) ការតំណាងឱ្យអាណត្តិរបស់មេធាវី គឺជាកិច្ចដែលកូនក្តីយល់ព្រមឱ្យមេធាវីធ្វើជាតំណាងក្នុងការស្តាប់ និងផ្តល់យោបល់ក្នុងដំណាក់កាលនានានៅតុលាការ ដូចជា ដំណាក់កាលនីតិវិធីត្រៀមទាញហេតុផលផ្ទាល់មាត់ និងដំណាក់កាលទាញហេតុផលផ្ទាល់មាត់ជាដើម។

នៅក្នុងសំណុំរឿងរដ្ឋប្បវេណី មេធាវី ធ្វើការពិភាក្សា និងស្វែងរកដំណោះស្រាយជូនកូនក្តីដើម្បីទាមទារអ្វីដែលជាកម្មវត្ថុរបស់អតិថិជនខ្លួន។ ប្រសិនបើជាករណីវិវាទកិច្ចសន្យា មេធាវីជាអ្នកពិនិត្យមើលលក្ខខណ្ឌកិច្ចសន្យា និងការអនុវត្តរបស់ភាគី ករណីរកឃើញនូវវិការៈដែលភាគីម្ខាងទៀតបានប្រព្រឹត្ត មេធាវី ត្រូវរិះរកវិធី និងស្វែងរកវិការៈនោះបូករួមជាមួយនឹងការសំអាងទៅលើបទដ្ឋានដែលមានចែងក្នុងច្បាប់ជាធរមាន យកមកធ្វើជាមូលដ្ឋានក្នុងការទាមទារនូវសំណង ឬកម្មវត្ថុដែលកូនក្តីចង់បាន។ មេធាវី អាចចាត់ទុកថាខ្លួនជោគជ័យបាន លុះត្រាតុលាការបានសម្រេចតាមការស្នើសុំរបស់ខ្លួនដោយមិនកាត់បន្ថយ ឬបដិសេធ ហើយកូនក្តីបានទទួលតាមអ្វីដែលគាត់បានទាម

[១៣] មាត្រា១៨, ក្រមសីលធម៌មេធាវី, ភ្នំពេញ, ២០១២

[១៤] មេធាវី **ប៊ុន ហុន**, វិជ្ជាជីវៈមេធាវីនៅក្នុងសង្គមកម្ពុជា, ភ្នំពេញ, ២០១៦, ទំព័រ១៣

ទារ។[១៦] ការទទួលបានកម្រៃរបស់មេធាវី គឺអាស្រ័យទៅតាមការកំណត់ក្នុងកិច្ចសន្យារបស់មេធាវី និងអតិថិជន។

### ១.២.២ ការការពារជូនកូនក្ដីក្នុងសំណុំរឿងព្រហ្មទណ្ឌ

ការការពារក្ដីជូនកូនក្ដីក្នុងសំណុំរឿងព្រហ្មទណ្ឌ គឺជាកិច្ចដែលមេធាវីឡើងការពារជូនកូនក្ដីដែលមានជាប់ទាក់ទងក្នុងសំណុំរឿងព្រហ្មទណ្ឌ ឬបានប្រព្រឹត្តអំពើដែលប៉ះពាល់ដល់សណ្ដាប់ធ្នាប់សង្គម និងដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ។ ការការពារក្នុងសំណុំរឿងព្រហ្មទណ្ឌ តម្រូវឱ្យ មេធាវី ត្រូវស្វែងយល់ពីដំណើរអង្គហេតុដែលបានកើតឡើងឱ្យបានច្បាស់លាស់ ពិសេសគឺត្រូវដឹងអំពីមូលដ្ឋាន និងគោលការណ៍នៃច្បាប់ព្រហ្មទណ្ឌ។ ជាទូទៅមូលដ្ឋាននៃការចោទប្រកាន់របស់ព្រះរាជអាជ្ញាធ្វើឡើងនៅពេលដែលធាតុផ្សំបទល្មើសមានគ្រប់គ្រាន់ មេធាវីត្រូវដឹងច្បាស់ពីកំហុស និងអង្គហេតុដែលកូនក្ដីខ្លួនបានប្រព្រឹត្ត និងដឹងពីលក្ខខណ្ឌដែលច្បាប់បានកំណត់ចំពោះការប្រព្រឹត្តផ្ទុយនេះ តួយ៉ាងតាមរយៈសាក្សី ឬភស្តុតាងបង្ហាញនានាដែលអាចជួយកូនក្ដីបាន។ នៅក្នុងការការពារសំណុំរឿងព្រហ្មទណ្ឌ មេធាវីយកទ្រឹស្ដីចំនួន ២មកការពារ[១៧]៖

**១. <u>ស្នើឱ្យកូនក្ដីរួចផុតពីបទចោទ:</u>** ករណីដែលមេធាវី រកឃើញភស្តុតាងផ្ទុយដែលបង្ហាញថាកូនក្ដីមិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់ព្រះរាជអាជ្ញា។ ការស្នើសុំកូនក្ដីឱ្យផុតពីបទចោទ គឺជាវិធីដែលមេធាវី ប្រើប្រាស់ទ្រឹស្ដីការពាររបស់ខ្លួន ជាមធ្យោបាយក្នុងការបំផ្លាញនូវធាតុផ្សំបទល្មើសដែលតំណាងអយ្យការបានចោទ ដោយប្រើលក្ខខណ្ឌវិមតិសង្ស័យតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ជាទូទៅទ្រឹស្ដីការពារនេះ ប្រើនៅពេលដែលមេធាវីរកឃើញថាមានភាពខ្វះចន្លោះនិងភស្តុតាង ផ្ទុយដែលព្រះរាជអាជ្ញាយកមកប្រើដើម្បីចោទដូចជា របាយការណ៍របស់នគរបាល ជាដើម។

*<u>ឧទាហរណ៍:</u> ការចោទប្រកាន់ពីបទជួញដូរគ្រឿងញៀន ដោយមិនមានកម្រិតធាតុសុទ្ធគ្រប់គ្រាន់តាមច្បាប់។*

**២. <u>ស្នើសុំស្ថានសម្រាលឱ្យកូនក្ដី</u>** កាលដែលមេធាវី រកឃើញ និងដោយកូនក្ដីបានសារភាពថាបានប្រព្រឹត្តនូវបទល្មើស ហើយរាល់សកម្មភាពដែលបានប្រព្រឹត្តនោះ មានភាពស៊ីចង្វាក់ដូចនឹងការចោទរបស់តំណាងអយ្យការនោះ កិច្ចការដែលមេធាវីត្រូវធ្វើគឺការស្នើសុំតុលាការឱ្យផ្ដល់ស្ថានសម្រាល។

ស្ថានសម្រាលទោស មានបញ្ញត្តិក្នុងមាត្រា៩៣ មាត្រា៩៤ និងមាត្រា៩៥ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ការស្នើសុំស្ថានសម្រាលនេះ ត្រូវពិនិត្យទៅលើ **កាលៈទេសៈនៃបទល្មើស** មានន័យថា ជនជាប់ចោទប្រព្រឹត្តអំពើនោះដើម្បីដោះទ័លជាដើម។ ក្រៅពីនេះដែរ ការស្នើសុំស្ថានសម្រាលក៏អាចធ្វើបានដែរ ដោយផ្អែកលើបុគ្គលលក្ខណៈរបស់ជនជាប់ចោទ ដូចជា៖ ស្ថានភាពគ្រួសារ, ស្ថានភាពចិត្តសាស្ត្រ និងការអប់រំជាដើម។[១៨]

*ឧទាហរណ៍: ជនជាប់ចោទគ្មានអ្នកចិញ្ចឹមកូន ឬមានជម្ងឺប្រចាំកាយ។*

## ២. ការឈរជាតំណាងក្នុងកិច្ចសន្យានានា

មេធាវី គឺជាអ្នកដែលអនុវត្តវិជ្ជាជីវៈច្បាប់មួយដែលមានសិទ្ធិក្នុងការជ្រើសរើសយកនូវរឿងក្តីមកធ្វើដើម្បីឈរជាតំណាងរបស់អតិថិជនក្នុងស្ថាប័នយុត្តាធិការ។ ការការពារក្តីតំណាងឱ្យអតិថិជន ជាប្រភពចំណូលមួយរបស់អ្នកអនុវត្តវិជ្ជាជីវៈមេធាវី ប៉ុន្តែការងារមួយចំនួនទៀតដែល មេធាវី អាចទទួលបានប្រយោជន៍នោះគឺការធ្វើជាអ្នកប្រថាប់ត្រាលើកិច្ចសន្យា និងឈរជាតំណាងផ្នែកច្បាប់ឱ្យស្ថាប័ន ក្រុមហ៊ុន សហគ្រាស រដ្ឋ និងឯកជននានា។

### ២.១ ការប្រថាប់ត្រារបស់មេធាវីលើកិច្ចសន្យា

មេធាវី ផ្តល់យោបល់ និងតាក់តែងលិខិតស្នាមផ្សេងៗក្នុងវិស័យគតិយុត្ត[១៩] ការប្រថាប់ត្រារបស់មេធាវី គឺជាកិច្ចដែលភាគីនៃកិច្ចសន្យា ត្រូវធ្វើដើម្បីធានាថាកិច្ចសន្យាដែលភាគីបានចុះនោះមានលក្ខណៈស្របច្បាប់ និងដឹងឮពីមេធាវីដែលជាអ្នកចេះច្បាប់។ មេធាវី គឺជាអ្នកដែលពិនិត្យទៅលើលក្ខខណ្ឌរបស់កិច្ចសន្យា ដែលភាគីបានព្រមព្រៀងគ្នា ក្នុងករណីអតិថិជនចង់ឱ្យមេធាវី ជាអ្នកតាក់តែង ឬព្រាងកិច្ចសន្យានោះ កម្រៃនៃការតាក់តែងត្រូវកំណត់តាមការឯកភាពរវាង មេធាវី និងអតិថិជន។

ត្រារបស់មេធាវី ត្រូវបានកំណត់ថាស្របច្បាប់ និងត្រឹមត្រូវ លុះត្រាតែត្រានោះជារបស់សមាជិកដែលបានចុះឈ្មោះក្នុងបញ្ជីរបស់គណៈមេធាវី។ ការប្រថាប់ត្រារបស់មេធាវី ត្រូវធ្វើឡើងនៅស្របពេលដែលភាគីបានផ្តិតមេដៃឯកភាពចំពោះកិច្ចសន្យាដែលបានព្រមព្រៀង និងពិនិត្យរួចហើយ ជាទូទៅក្រោយពីការផ្តិតមេដៃ មេធាវី ចុះហត្ថលេខា និងវាយត្រារបស់ខ្លួននៅខាងក្រោមស្នាមមេដៃរបស់ភាគីទាំងសងខាងនៃកិច្ចសន្យា អមជាមួយនឹងពាក្យថា **បានផ្តិតមេដៃចំពោះមុខមេធាវី** ។ ត្រាមេធាវី ក៏មានបោះដែរនៅគ្រប់សន្លឹកនៃកិច្ចសន្យាប៉ុន្តែមិនមែនវាយទាំងមូលទេ គឺវាយជាលក្ខណៈត្រាមូលតែមួយលើក្រដាសច្រើនសន្លឹក។ ក្រោយពីភាគីបានឯកភាព និងបានវាយត្រាមេធាវីហើយ មេធាវី ដែលធ្វើជាតំណាងក្នុងកិច្ចសន្យានោះ ពុំអាចធ្វើជាមេធាវីតំណាងដោយអាណត្តិសម្រាប់ភាគីណាមួយឡើយ ពីព្រោះការធ្វើជាអ្នកតំណាងនេះ គឺដើម្បីជំរុញឱ្យកិច្ចសន្យានោះមានអានុភាព និងស្របច្បាប់។ ការចុះកិច្ចសន្យាទាំងអស់ ពុំតម្រូវឱ្យមានមេធាវីប្រថាប់ត្រានោះទេ ហេតុនេះភាគីអាចមានសិទ្ធិក្នុងការមានមេធាវី ឬអត់មេធាវីបានទៅតាមការគិតគូររបស់ភាគី។

### ២.២ ការឈរឈ្មោះជាតំណាងរបស់ក្រុមហ៊ុន ឬស្ថាប័ននានា

ក្រៅពីការឈរជាតំណាងឱ្យអតិថិជន និងជាតំណាងក្នុងកិច្ចសន្យា មេធាវី ក៏អាចឈរជាតំណាងរបស់ក្រុមហ៊ុន ឬស្ថាប័ននានាដើម្បីប្រឹក្សាយោបល់ ឬជាតំណាងផ្នែកច្បាប់សម្រាប់ពួកគេផងដែរ។

---

[១៥-១៦] បច្ចេកទេសសវនាការនៃមេធាវីរដ្ឋប្បវេណី, មេធាវី អៀវ ប៊ុនផេង, ភ្នំពេញ, ២០១១, ទំព័រ១១០-១១៣

[១៧-១៨] បច្ចេកទេសសវនាការនៃមេធាវីព្រហ្មទណ្ឌ, មេធាវី អៀវ ប៊ុនផេង, ភ្នំពេញ, ២០១១, ទំព័រ៥៥-៦១

ការឈរជាតំណាងរបស់ក្រុមហ៊ុននេះ កើតចេញដោយកិច្ចសន្យារវាងក្រុមហ៊ុន និងមេធាវី ដូចនេះ ការងារដែល ការតំណាងរបស់ក្រុមហ៊ុននេះ កើតចេញដោយកិច្ចសន្យារវាងក្រុមឈរ ហ៊ុន និងមេធាវី ដូចនេះការងារដែលត្រូវធ្វើមានកំណត់ក្នុងកិច្ចសន្យារបស់ពួកគេ។

យោងទៅតាមអ្វីដែលក្រុមយើងខ្ញុំបានជួបផ្ទាល់ជាមួយលោកមេធាវី **យុង ផានិត** សមាជិកក្រុមប្រឹក្សាគណៈមេធាវី និងជាអនុប្រធាននាយកដ្ឋានការពារក្ដីជូនជនក្រីក្រ បានឱ្យដឹងថា៖ ជាទូទៅការងាររបស់មេធាវីក្នុងការតំណាងឱ្យក្រុមហ៊ុនមានដូចជា៖

- ពិនិត្យ និងផ្ដល់យោបល់អំពីកិច្ចសន្យា កិច្ចព្រមព្រៀង បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន និងលិខិតនានាដែលទាក់ទងនឹងច្បាប់
- ពិគ្រោះយោបល់ផ្នែកច្បាប់ និងផ្ដល់ដំបូន្មាននានាជាមួយអគ្គនាយក ឬតំណាងក្រុមហ៊ុន
- បំពេញការងារជាមួយបុគ្គលិក ឬមន្ត្រីផ្នែកនីតិកម្មរបស់ក្រុមហ៊ុន
- តាក់តែងកិច្ចសន្យា និងឈរជាតំណាងក្នុងកិច្ចសន្យារបស់ក្រុមហ៊ុន
- ស្រាវជ្រាវ និងពន្យល់ចំពោះច្បាប់ពាក់ព័ន្ធនានា នៅពេលមានការប្រកាសឱ្យប្រើ ឬវិសោធនកម្មថ្មី
- ឈរជាមេធាវីតំណាងដោយអាណត្តិរបស់ក្រុមហ៊ុនក្នុងករណីវិវាទ លើកលែងតែក្នុងករណីខ្លួនជាមេធាវីតំណាងក្នុងកិច្ចសន្យាដែលជាកម្មវត្ថុនៃបណ្ដឹង

តាមរយៈការងារខាងលើនេះ មេធាវី អាចទទួលបានកម្រៃប្រចាំខែដូចមានកំណត់ក្នុងកិច្ចសន្យាជាមួយក្រុមហ៊ុន ប៉ុន្តែករណីមានវិវាទ និងឈរជាមេធាវីតំណាងដោយអាណត្តិឱ្យក្រុមហ៊ុន កម្រៃរបស់មេធាវីត្រូវធ្វើឡើងទៅតាមការកំណត់របស់មេធាវីក្នុងកិច្ចសន្យាផ្សេងដែលកំណត់ដោយច្បាប់ជាធរមាន។

## ផ្នែកទី៥៖ ការចូលរួមរបស់មេធាវីក្នុងពង្រឹងវិស័យយុត្តិធម៌

### ១. ការការពារក្ដីជូនជនក្រីក្រ

ការការពារក្ដីជូនជនក្រីក្ររបស់មេធាវី គឺជាយន្តការនៃការចូលរួមក្នុងការពង្រឹងវិស័យយុត្តិធម៌របស់មេធាវីក្នុងសង្គមកម្ពុជា។ ការការពារក្ដីជូនជនក្រីក្រ សម្ដៅទៅលើការផ្ដល់នូវសេវាផ្នែកច្បាប់ដោយមិនគិតកម្រៃដល់ជនក្រីក្រដែលមានវិវាទ ឬចម្ងល់ផ្នែកច្បាប់ ការផ្ដល់សេវាច្បាប់នោះមានដូចជា៖

- ការផ្ដល់មេធាវីការពារដោយឥតគិតថ្លៃ
- ការផ្ដល់សេវាពិគ្រោះយោបល់ដោយឥតគិតថ្លៃ

បច្ចុប្បន្នបេសកម្មក្នុងការការពារក្ដីជូនជនក្រីក្រ ប្រព្រឹត្តទៅក្នុងក្របខណ្ឌរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលមាននាយកដ្ឋានការពារក្ដីជូនជនក្រីក្រជាសេនាធិការ និងប្រតិភូគណៈមេធាវីនៅតាមសាលាដំបូង

ចំនួន២៤រាជធានី-ខេត្តទូទាំងប្រទេស។ មាត្រា២៩ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បានប្បញ្ញត្តិឱ្យមេធាវីទាំងអស់មានកាតព្វកិច្ចក្នុងការការពារក្តីជូនជនក្រីក្រ និងត្រូវដូចនឹងការជួយអតិថិជនខ្លួនដែរ ដូចនេះមេធាវីកម្មសិក្សាទាំងអស់មុននឹងអាចប្រកបវិជ្ជាជីវៈ ត្រូវតែឆ្លងដំណាក់កាលនេះមុននឹងអាចអនុវត្តការងារពេញសិទ្ធិបាន។

ចំពោះថវិកាទូទាត់វិញ ទោះជាការការពារក្តីជូនជនក្រីក្រ ត្រូវធ្វើឡើងដោយឥតគិតថ្លៃសម្រាប់ប្រជាពលរដ្ឋក៏ដោយ ក៏មេធាវីដែលទទួលកាន់ក្តីនោះមិនមែនធ្វើដោយឥតកម្រៃដែរ។ ការទូទាត់លើថវិកាសម្រាប់ការការពារក្តីជនក្រីក្រនេះ ជាបន្ទុករបស់រាជរដ្ឋាភិបាលក្នុងឆ្នាំ២០១៩ រាជរដ្ឋាភិបាល បានសម្រេចផ្តល់ជូននូវថវិកាចំនួន ១២០០លានរៀលសម្រាប់ប្រតិបត្តិការណ៍ការពារក្តីនៅទូទាំងប្រទេស ដែលថវិកាសរុបនេះបែងចែកជា ៤ត្រីមាស។ ជាគោលការណ៍ មេធាវី ទទួលបានកម្រៃសម្រាប់ការការពារក្តីជូនជនក្រីក្រនៅតុលាការចំនួន ៤០០០០០រៀលក្នុងមួយរឿង ចំណែកការពិគ្រោះយោបល់វិញ គឺ ៨០០០០រៀល ក្នុងរយៈពេល ៦០នាទី។ ការបើកថវិកា ប្រព្រឹត្តទៅតាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយការបើកឱ្យត្រូវធ្វើឡើងក្នុងរយៈពេល ១ត្រីមាសម្តង ចំណែកចំនួនទឹកប្រាក់គឺផ្អែកទៅលើឯកសារដែលផ្តល់មកក្រសួង និងពិនិត្យថាត្រឹមត្រូវតាមលក្ខខណ្ឌ។

លក្ខខណ្ឌនៃការការទទួលបានសេវាដោយមិនគិតថ្លៃចែកចេញជា ២គឺ៖ **តាមរយៈការស្នើសុំរបស់តុលាការ** និង **តាមរយៈការស្នើសុំពីប្រជាជនដែលមានលិខិតបញ្ជាក់ក្រីក្រ ឬប័ណ្ណសមធម៌។**

**ក. ការស្នើតាមរយៈតុលាការ**

ការស្នើសុំតាមរយៈតុលាការ គឺជាកិច្ចដែលតុលាការធ្វើការផ្ញើលិខិតស្នើសុំមេធាវីទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងចម្លងជូនមកគណៈមេធាវី ការស្នើសុំពីតុលាការ ភាគច្រើនគឺស្នើសុំសម្រាប់ជនជាប់ចោទដែលមានជីវភាពក្រីក្រ និងគ្មានលទ្ធភាពស្វែងរកមេធាវីឯកជនដែលកិច្ចនេះជួយឱ្យជនជាប់ចោទ អាចទទួលបានមេធាវីតំណាងដើម្បីការពារខ្លួន នាពេលជំនុំជម្រះដូចមានចែងក្នុងមាត្រា៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ នៅពេលដែលគណៈមេធាវី បានទទួលនូវលិខិតនេះ នាយកដ្ឋានការពារក្តីជូនជនក្រីក្រ នឹងពិនិត្យមើលលក្ខខណ្ឌនិងការស្នើសុំ ប្រសិនបើមានគ្រប់នីតិវិធីហើយ នាយកដ្ឋាននឹងធ្វើការចាត់តាំងមេធាវី ដោយចេញលិខិតចាត់តាំងទៅតុលាការ និងជូនដំណឹងទៅមេធាវីដែលបានចាត់តាំងនោះវិញ។ ការស្នើចាត់តាំងមេធាវីការពារជនក្រីក្រ ត្រូវធ្វើឡើងសម្រាប់តុលាការគ្រប់ជាន់ថ្នាក់ ប៉ុន្តែដោយបច្ចុប្បន្ន គណៈមេធាវី បានបង្កើតឱ្យមានប្រតិភូតំណាងនៅតាមបណ្តាតុលាការរាជធានី-ខេត្តនោះ ការស្នើសុំមេធាវីត្រូវធ្វើឡើង និងចាត់តាំងដោយផ្ទាល់ដោយការិយាល័យប្រតិភូប្រចាំខេត្តនោះ ចំណែកនៅសាលាឧទ្ធរណ៍ និងតុលាការកំពូល ការស្នើសុំមេធាវី គឺផ្ញើចូលមកនាយកដ្ឋានការពារក្តីជូនជនក្រីក្រនៃគណៈមេធាវី។ គោលការណ៍នៃការផ្តល់ឱ្យមេធាវីបាន គឺតុលាការ ត្រូវបញ្ជាក់ថា បទល្មើសដែលជនជាប់ចោទបានប្រព្រឹត្តជាបទ

---

[១៩] មាត្រា៣, ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី,ភ្នំពេញ,១៩៩៥

ឧក្រិដ្ឋ ហើយជននោះជាជនក្រីក្រគ្មានលទ្ធភាពស្វែងរកមេធាវីដោយខ្លួនឯង។

**ខ. ការស្នើសុំពីប្រជាជនដែលមានលិខិតបញ្ជាក់ក្រីក្រ ឬប័ណ្ណសមធម៌**

ការទទួលបានសេវាផ្តល់មេធាវីដោយឥតគិតថ្លៃសម្រាប់ប្រជាពលរដ្ឋដែលមានលិខិតបញ្ជាក់ក្រីក្រ ឬប័ណ្ណសមធម៌ គឺជាលក្ខខណ្ឌនៃការស្នើសុំដោយប្រជាពលរដ្ឋផ្ទាល់ ដើម្បីជួយរកមេធាវីការពារនៅតុលាការ។ លក្ខខណ្ឌនៃការទទួលបានមេធាវីក្នុងករណីនេះគឺដូចគ្នាទៅនឹងការស្នើសុំពីតុលាការដែរ គឺជនជាប់ចោទបានប្រព្រឹត្តបទឧក្រិដ្ឋ ហើយស្ថានភាពជីវភាពរបស់ជននោះពិតជាក្រីក្រមែន (តែត្រូវមានលិខិតបញ្ជាក់ភាពក្រីក្រដែលទទួលស្គាល់ដោយអាជ្ញាធរមូលដ្ឋាន ឬមានប័ណ្ណសមធម៌ដែលចេញដោយក្រសួងផែនការ)។

អ្វីទៅជា **ប័ណ្ណសមធម៌**? ប័ណ្ណសមធម៌ គឺជាប័ណ្ណដែលចេញដោយក្រសួងផែនការ ក្នុងន័យកំណត់ពីស្ថានភាពជីវភាពក្រីក្ររបស់ប្រជាពលរដ្ឋ ប័ណ្ណសមធម៌នេះក៏ត្រូវបានប្រើដែរសម្រាប់សេវាសុខាភិបាលនិងសេវាដទៃទៀតដែលប្រជាពលរដ្ឋត្រូវការពីរដ្ឋដោយឥតគិតថ្លៃ។ ប្រជាជនដែលមានឯកសារតាមលក្ខខណ្ឌតម្រូវនឹងទទួលបានការចាត់តាំងមេធាវីដើម្បីការពារ ពីនាយកដ្ឋានការពារក្តីជូនជនក្រីក្រនៃគណៈមេធាវី ឬពីប្រតិភូគណៈមេធាវីនៅតាមរាជធានី-ខេត្តដោយឥតគិតថ្លៃ។

## ២. ការប្រឹក្សា និងពិគ្រោះយោបល់ផ្នែកច្បាប់ជូនប្រជាពលរដ្ឋក្រីក្រ

ការពិគ្រោះយោបល់ផ្នែកច្បាប់សម្រាប់ប្រជាពលរដ្ឋ ក៏ជានីតិវិធីមួយដែលអនុវត្តជាធម្មតាសម្រាប់សេវាផ្នែកច្បាប់ជូនប្រជាពលរដ្ឋ។ ការពិគ្រោះយោបល់ ពុំត្រូវបានកំណត់ឱ្យមានលក្ខខណ្ឌដូចការចាត់តាំងមេធាវីការពារនោះទេ ដូច្នេះប្រជាពលរដ្ឋដែលមានចម្ងល់ ឬមិនយល់ពីនីតិវិធីច្បាប់អាចទទួលបានការពិគ្រោះយោបល់ពីនាយកដ្ឋានការពារក្តីជូនជនក្រីក្រ ឬតាមប្រតិភូគណៈមេធាវីដោយឥតគិតថ្លៃ។ ការពិគ្រោះយោបល់មិនកំណត់ថាជាបទឧក្រិដ្ឋទេ ទើបទទួលនោះទេ ប្រសិនបើប្រជាពលរដ្ឋមានវិវាទផ្នែករដ្ឋប្បវេណី ក៏អាចសាកសួរបានផងដែរ។

ចំពោះថវិកាសម្រាប់ការពិគ្រោះយោបល់នេះ គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ជាគោលការណ៍គឺពិគ្រោះយោបល់ជូនជនក្រីក្រក្នុង១ម៉ោងគឺ ៨ម៉ឺនរៀល[២០] ដែលថវិកានេះក៏ជាបន្ទុករបស់រាជរដ្ឋាភិបាលផងដែរ។

## ៣. ការចូលរួមរបស់មេធាវីនៅក្នុងការការពារផ្លូវច្បាប់ដល់ស្ត្រី និងកុមារ

### ៣.១ យន្តការនៃការប្រឹក្សាយោបល់ផ្នែកច្បាប់និងការការពារស្ត្រីក្នុងតុលាការ

ក្រៅពីការការពារក្តីជូនជនក្រីក្រ ដែលមានលក្ខខណ្ឌកំណត់ឱ្យអ្នកស្នើជាជនក្រីក្រ ជាជនជាប់ចោទនិងបានប្រព្រឹត្តបទឧក្រិដ្ឋ។ នាយកដ្ឋានការពារក្តីជូនជនក្រីក្រនៃគណៈមេធាវី ក៏មានយន្តការមួយក្នុងការការពារស្ត្រី និង

ក្មេងស្រីរងគ្រោះផងដែរ គណៈមេធាវី ចាត់ទុកការការពារក្តីជូនស្ត្រី និងកុមារីរងគ្រោះនេះជាគោលការណ៍មួយទៀតដែលចូលរួមជួយពង្រឹងយុត្តិធម៌សង្គម និងវិជ្ជាជីវៈមេធាវី។

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា សហការជាមួយនឹងក្រុមប្រឹក្សាជាតិដើម្បីស្ត្រី (ក.ប.ជ.ដ.ស) បានចុះអនុស្សារណៈមួយស្តីពី កិច្ចសហប្រតិបត្តិការផ្តល់សេវាការពារក្តីដល់ស្ត្រី និងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សា និងការអប់រំច្បាប់ កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩កន្លងទៅនេះ។ អត្ថន័យនៃអនុស្សារណៈនេះមានគោលបំណងបង្កើតឱ្យមានកិច្ចសហការរវាងគណៈមេធាវី និងក្រុមប្រឹក្សាជាតិដើម្បីស្ត្រី ក្នុងការផ្តល់សេវាច្បាប់ពីមេធាវីដល់ស្ត្រី និងក្មេងស្រីរងគ្រោះដោយឥតគិតកម្រៃ។ យោងតាមអនុស្សារណៈនេះ បទល្មើសចំនួន ៣ នឹងត្រូវយកមកជាលក្ខខណ្ឌនៃការផ្តល់សេវាបាន[២២] មានដូចជា៖

១. អំពើហិង្សាក្នុងគ្រួសារ

២. អំពើរំលោភសេពសន្ថវៈ

៣. អំពើជួញដូរ និងធ្វើអាជីវកម្មផ្លូវភេទ

ដើម្បីទទួលបានសេវាការពារនេះ បានក្រសួង ឬមន្ទីរកិច្ចការនារីរាជធានី-ខេត្ត ត្រូវធ្វើពាក្យស្នើសុំមេធាវីមកគណៈមេធាវី ឬទៅតាមប្រតិភូគណៈមេធាវី ដើម្បីចាត់តាំងមេធាវីអមជាមួយជនរងគ្រោះនៅគ្រប់ដំណាក់កាល។ មេធាវី ដែលត្រូវបានចាត់តាំងដោយគណៈមេធាវី ឬប្រតិភូគណៈមេធាវីមានភារកិច្ចក្នុងការអមនិងតាមជាមួយជនរងគ្រោះតាំងពីដំណាក់កាលមុននគរបាលយុត្តិធម៌ រហូតដល់ដំណាក់កាលជំនុំជម្រះ។

ក្រៅពីការផ្តល់សេវាការពារក្តី គណៈមេធាវី ក៏មានតួនាទីក្នុងការប្រឹក្សាយោបល់ជូនស្ត្រី និងក្មេងស្រីជាជនរងគ្រោះផងដែរ។ ចំពោះថវិកាសម្រាប់ការផ្តល់សេវាប្រឹក្សាយោបល់ និងសេវាការពារក្តីនឹងត្រូវសម្រេចដោយស្ថាប័នទាំងពីរនៅពេលក្រោយ។

### ៣.២ ការការពារកុមារតាមយន្តការកុមារមេត្រី

ការការពារកុមារ គឺជាកិច្ចការពារផ្នែកច្បាប់របស់មេធាវីក្នុងការតំណាងឱ្យកុមារ ឬអនីតិជនដែលជាជនមានអាយុក្រោម១៨ (ដប់ប្រាំបីឆ្នាំ)[២២]។ ការការពារកុមារតាមយន្តការកុមារមេត្រី គឺជាយន្តការដ៏សំខាន់របស់មេធាវីក្នុងការចូលរួមអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលបានប្រកាសឱ្យប្រើកាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ ដែលច្បាប់នេះមានគោលបំណង[២៣] ដូចតទៅ៖

- ធានាការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់អនីតិជនដែលប្រព្រឹត្តក្នុងបទល្មើស
- គាំទ្រដល់ការស្តារសម្បទា និងការធ្វើសមាហរណកម្មអនីតិជនទៅក្នុងសង្គម និងសហគមន៍

[២០] តារាងប្រាក់ឧបត្ថម្ភមេធាវីក្នុងការពិគ្រោះយោបល់ជូនជនក្រីក្រ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៩ របស់គណៈមេធាវី

- ធានាការពារផលប្រយោជន៍សង្គម និងសហគមន៍

យន្តការកុមារមេត្រី គឺជាយន្តការដែលបង្កើតឡើងក្នុងន័យជួយឱ្យកុមារដែលបានប្រព្រឹត្តបទល្មើសបានទទួលនូវអ្វីដែលកុមារជាអនីតិជនអាចទទួលយកបានពេលអនុវត្តនីតិវិធីច្បាប់ យន្តការកុមារមេត្រី មានកំណត់ក្នុងមាត្រា៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

**តើ មេធាវី ចូលរួមយ៉ាងដូចម្តេចក្នុងការការពារកុមារតាមយន្តការកុមារមេត្រីនេះ?**

ដូចដែលមានបញ្ជាក់នៅចំណុចខាងលើ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មានបំណងថែរក្សានិងធានានូវសិទ្ធិរបស់អនីតិជន ដែលប្រព្រឹត្តបទល្មើសឱ្យទទួលយកបានការងារនៅពេលអនុវត្តនីតិវិធីច្បាប់ និងបញ្ឈប់រាល់ទង្វើដែលប៉ះពាល់ដល់រាងកាយរបស់អនីតិជនពេលត្រូវបានឃាត់ខ្លួន ឬយកទៅអនុវត្តនីតិវិធីផ្សេង ដូចជា ដំណាក់កាលនគរបាលយុត្តិធម៌ជាដើម។ ដោយផ្តោតលើចំណុចនេះហើយ ទើបយើងអាចកំណត់បានថា មេធាវី គឺជាអ្នកដែលមានសមត្ថកិច្ចក្នុងការចូលរួមជួយអនីតិជនស្របតាមយន្តការកុមារមេត្រី ពីព្រោះយោងតាមច្បាប់ ប្រសិនបើអនីតិជនត្រូវបានឃាត់ខ្លួនដោយសង្ស័យថាបានប្រព្រឹត្តបទល្មើសជននោះអាចស្វែងរកមេធាវីក្នុងការការពារបានភ្លាមៗ ដើម្បីជួយប្រឹក្សាអមជាមួយខ្លួន និងប្រាប់ពីនីតិវិធីនានា ហេតុនេះតាមរយៈការចូលរួមនេះ មេធាវី បានចូលរួមយ៉ាងសំខាន់ក្នុងការធានា និងការពារនូវសិទ្ធិរបស់អនីតិជន និងបានចូលរួមជួយពង្រឹងនូវការអនុវត្តយន្តការកុមារមេត្រីនេះ ទៅតាមគោលការណ៍ដែលច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានកំណត់។

[២១] ប្រការ២, អនុស្សារណៈយោគយល់រវាងគណៈមេធាវី និងក្រុមប្រឹក្សាជាតិដើម្បីស្ត្រី, ខែមីនា ២០១៩

[២២] មាត្រា១៧ នៃក្រមរដ្ឋប្បវេណី និងមាត្រា៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

[២៣] មាត្រា១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

# ជំពូកទី៣៖
# តួនាទីតុលាការ

## ផ្នែកទី១៖ តុលាការ និងអយ្យការ

**តុលាការ** ជាស្ថាប័នរបស់រដ្ឋដែលមានតួនាទីបម្រើផលប្រយោជន៍ប្រជាជនទូទៅ។ នៅក្នុងប្រព័ន្ធតុលាការមានអយ្យការ ក៏ប៉ុន្តែអយ្យការ (ព្រះរាជអាជ្ញា) គឺជាស្ថាប័នមួយដាច់ដោយឡែកពីចៅក្រម ដោយស្ថាប័នអយ្យការមានតួនាទីចោទប្រកាន់ក្នុងបទល្មើសព្រហ្មទណ្ឌនានា ដែលមានព្រះរាជអាជ្ញាជាអ្នកសម្រេច។ ចំណែកឯ ចៅក្រមសំដៅដល់បុគ្គលក្នុងស្ថាប័នតុលាការ ដែលមានសិទ្ធិអំណាចក្នុងការកាត់សេចក្តីតាមផ្លូវច្បាប់លើជនណាម្នាក់ដែលល្មើសច្បាប់ ហើយក៏ជាអ្នកសម្រេចឲ្យជនណាម្នាក់រួចខ្លួនបានដែរ ប្រសិនបើរកឃើញថា ជននោះគ្មានកំហុស។

នៅក្នុងតុលាការ ចៅក្រមត្រូវបែងចែកជា ២ គឺ៖

- ចៅក្រមជំនុំជម្រះ ដែលជាចៅក្រមទទួលបន្ទុកការកាត់ និងសម្រេចអង្គសេចក្តីនាពេលសវនាការ
- ចៅក្រមស៊ើបសួរ ដែលជាចៅក្រមទទួលបន្ទុកលើការស៊ើបអង្កេតលើសំណុំរឿងមួយក្នុងនាមតុលាការក្រោយពីទទួលបានសេចក្តីសន្និដ្ឋានពីតំណាងអយ្យការ។[២៤]

ពាក្យថា **អយ្យការអមតុលាការ** តាមខ្លឹមសារនេះ មានអត្ថន័យថាស្ថាប័នមួយនេះ មិនស្ថិតក្រោមអំណាចតុលាការទេ តែជាស្ថាប័នដែលមានសិទ្ធិចោទប្រកាន់ទៅលើនរណាម្នាក់ដែលបានប្រព្រឹត្តខុស ឬប្រឆាំងនឹងច្បាប់ទាក់ទងនឹងច្បាប់ព្រហ្មទណ្ឌ។ អយ្យការអមតុលាការ មានសិទ្ធិអំណាចគ្រប់គ្រងលើកម្លាំងសមត្ថកិច្ចនៅតាមបណ្តាខេត្ត-ក្រុង។

ទាក់ទិននឹងចៅក្រមអយ្យការ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃមាត្រា២៨ បានបញ្ញត្តិថាចៅក្រមអយ្យការត្រូវបែងចែកជា ៣ប្រភេទ[២៥] គឺ៖

- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល
- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង។

[២៤] លោកសាស្ត្រាចារ្យ **សាន់ ជួយ**, នីតិព្រហ្មទណ្ឌពិសេសភ្នំពេញ, ២០១៨

[២៣] មាត្រា២៨ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

## **១. លិខិតបទដ្ឋានដែលពាក់ព័ន្ធនឹងវិស័យតុលាការ និងអយ្យការ**

ជាគោលការណ៍វិស័យតុលាការ និងអយ្យការត្រូវគោរពតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចែងអំពីគោលការណ៍គ្រឹះនៃស្ថាប័នតុលាការ និងអង្គការអយ្យការ។ វិស័យតុលាការ គឺជាវិស័យសាធារណៈដែលរាល់តួនាទីទាំងអស់ គឺត្រូវកំណត់ដោយបទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ដែលពាក់ព័ន្ធនឹងវិស័យតុលាការមានដូចជា៖

- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- និង ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា។

ក្រៅពីបទដ្ឋានច្បាប់ដែលមាននាយនៅខាងលើនេះ វិស័យតុលាការកម្ពុជាក៏ទទួលបាននូវឥទ្ធិពលនៃការអនុវត្តច្បាប់មួយចំនួនពីបទដ្ឋានអន្តរជាតិផងដែរ ជាក់ស្តែងលិខិតបទដ្ឋានគតិយុត្តជាតិដែលបានប្រកាសនិងចូលជាធរមាន ក៏មានការដាក់បញ្ចូលនូវគោលការណ៍មួយចំនួនដែលមានចែងជាអន្តរជាតិ ដូចជាសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស និង លិខិតបទដ្ឋានអន្តរជាតិមួយចំនួនទាក់ទងនឹងអំណាចចៅក្រម និង ព្រះរាជអាជ្ញាជាដើម ប៉ុន្តែទោះជាមានការចែង ឬបញ្ចូលច្បាប់អន្តរជាតិចូលទៅក្នុងច្បាប់ជាតិក៏ដោយ ក៏ច្បាប់ទាំងនោះត្រូវអនុវត្តស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលជាច្បាប់កំពូលរបស់ជាតិដដែល។

លិខិតបទដ្ឋានដែលមានចែងពីច្បាប់ទាក់ទងនឹងវិស័យយុត្តាធិការនៅកម្ពុជា មាន៖

### **១.១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា:**

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជាច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសឱ្យប្រើកាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៣ មានសរុប១៥ជំពូក ស្មើនឹង ១៥១មាត្រា។ ទាក់ទងនឹងវិស័យតុលាការនេះ រដ្ឋធម្មនុញ្ញ បានកំណត់នៅក្នុងជំពូកទី១១ ចាប់ពីមាត្រា១២៨ ដល់មាត្រា១៣៥ ដោយកំណត់ជាគោលការណ៍ថា អំណាចតុលាការ ជាអំណាចឯករាជ្យ ដែលមានតួនាទីក្នុងការធានារក្សាអនាគតនិងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋដែលមានសមត្ថកិច្ចគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់រួមទាំងរឿងក្តីរដ្ឋបាលផងដែរ។

**មាត្រា១២៩** នៃរដ្ឋធម្មនុញ្ញកម្ពុជា បានកំណត់ថាមានតែ **ចៅក្រម** ទេដែលមានសិទ្ធិជម្រះក្តីដោយការជម្រះក្តីផ្តល់យុត្តិធម៌ត្រូវធ្វើក្នុងនាមជាប្រជារាស្ត្រខ្មែរ ដោយយោងតាមនីតិវិធីនិងច្បាប់ជាធរមាន។ ចៅក្រមត្រូវបំពេញភារកិច្ចនេះដោយគោរពយ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។ ចំពោះសិទ្ធិធ្វើបណ្តឹងអាជ្ញាគឺត្រូវបានផ្តល់ទៅអង្គការអយ្យការ (**មាត្រា១៣០** នៃរដ្ឋធម្មនុញ្ញ) ។

## ១.២ លិខិតតុបករណ៍អន្តរជាតិ:

លិខិតតុបករណ៍អន្តរជាតិ គឺជាបណ្តាលិខិតបទដ្ឋានគតិយុត្តនានា ដែលមានតម្លៃ និងដាក់ឱ្យអនុវត្តជាអន្តរជាតិ។ នៅក្នុងប្រព័ន្ធតុលាការកម្ពុជា លិខិតបទដ្ឋានអន្តរជាតិដែលមានឥទ្ធិពល និងប្រើជាមូលដ្ឋានក្នុងច្បាប់តុលាការកម្ពុជា មានដូចជា:

- សេចក្តីប្រកាសជាសាកលស្តីអំពីសិទ្ធិមនុស្ស "*សិទ្ធិស្មើភាពគ្នានៅចំពោះមុខតុលាការ*"
- មាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលបានប្រកាសឱ្យប្រើកាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៦ ដោយអង្គការសហប្រជាជាតិ "*សិទ្ធិស្មើភាពគ្នានៅចំពោះមុខតុលាការ និងសាលាជម្រះក្តី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌*" ដែលរាជរដ្ឋាភិបាលកម្ពុជាផ្តល់សច្ចាប័ននៅក្នុងឆ្នាំ១៩៩២
- គោលការណ៍មូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលាការ ឆ្នាំ១៩៨៥
- គោលការណ៍ជាមូលដ្ឋានសម្រាប់ចៅក្រម និងព្រះរាជអាជ្ញា ដែលមានរួមបញ្ចូលក្នុងច្បាប់កម្ពុជា នាសម័យអ៊ុនតាក់ ឆ្នាំ ១៩៩០

លិខិតតុបករណ៍អន្តរជាតិខាងលើ មិនត្រឹមតែបានបញ្ញត្តិជាមូលដ្ឋាននៃច្បាប់តុលាការកម្ពុជាប៉ុណ្ណោះទេ បទដ្ឋានខាងលើនេះក៏ត្រូវបានយកទៅធ្វើទៅចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (មាត្រា១២៨និងមាត្រា៣១) ផងដែរ។ ក្រៅពីការចូលរួមជាមូលដ្ឋានច្បាប់ជាតិ បទដ្ឋានអន្តរជាតិ និងអង្គការពាក់ព័ន្ធអន្តរជាតិក៏បានចូលរួមក្នុងការធ្វើសេចក្តីព្រាង និងការអនុវត្តច្បាប់នេះដែរ ជាក់ស្តែងការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សកម្ពុជា បានធ្វើលិខិតជាអនុសាសន៍លើសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា[២៤] ចំណែកក្នុងចូលរួមអនុវត្តច្បាប់វិញកាលពីខែវិច្ឆិកា ឆ្នាំ២០១៤ អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ (The United Nation Special Rapporteur) ទទួលបន្ទុកលើកិច្ចការឯករាជ្យភាពរបស់ចៅក្រម និងមេធាវី បានស្នើព្រះមហាក្សត្រទ្រង់បញ្ឈប់ច្បាប់ទាំងឡាយណា ដែលទំនងជាបង្កើនឥទ្ធិពលអំណាចនីតិប្រតិបត្តិទៅលើអំណាចតុលាការតាមរយៈក្រសួងយុត្តិធម៌[២៥] ដែលជាក្រសួងទទួលខុសត្រូវលើការការពារឯករាជ្យរបស់តុលាការ។[២៦]

[២៤] មតិយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអជ្ញាទាក់ទងនឹងបទដ្ឋានសិទ្ធិមនុស្ស, ខែឧសភា ឆ្នាំ២០១៤

[២៥] **ហ៊ុល រស្មី** និង **ឡូរ៉េន ក្រូឌី**, កាសែ្សត ឌឹ ខេមបូឌា ដេលី ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥

[២៦] អនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥

## ១.៣ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ត្រូវបានបង្កើតឡើងដោយព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ក្នុងគោលបំណងធានាឯករាជ្យនៃអំណាចតុលាការ ធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពប្រជាពលរដ្ឋ ធានាឲ្យមានកិច្ចដំណើរការល្អរបស់អង្គការតុលាការ និងអង្គការអយ្យការ លើកកំពស់សេវាសាធារណៈឲ្យមានប្រសិទ្ធិភាព និងឆាប់រហ័សធានាក្នុងការផ្តល់យុត្តិធម៌លើរឿងក្តីគ្រប់ប្រភេទដើម្បីបង្កើនជំនឿទុកចិត្តពីប្រជាពលរដ្ឋ និងចូលរួមចំណែកពង្រឹងសុវត្ថិភាពសង្គម។ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មានសរុប ៦ ជំពូកស្មើនឹង ១១១ មាត្រា ដែលច្បាប់ទាំងមូលមានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការតុលាការគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ដែលជាសាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា កំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់នៃព្រះរាជាណាចក្រកម្ពុជា កំណត់អំពីសមត្ថកិច្ចរបស់តុលាការគ្រប់ផ្នែក និង គ្រប់ជាន់ថ្នាក់ទៅតាមជំនាញ និង រៀបចំកិច្ចការងារគ្រប់គ្រង ការងាររដ្ឋបាល និងដំណើរការប្រព្រឹត្តទៅរបស់តុលាការផងដែរ។

នៅក្នុងច្បាប់នេះ ស្ថាប័នយុត្តាធិការកម្ពុជា បែងចែកជា តុលាការ និងអង្គការអយ្យការមាន ៣ គឺ[២៧]៖

- សាលាដំបូង និងអយ្យការអមសាលាដំបូង
- សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
- តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល

## ១.៤ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបានបង្កើតឡើងដោយព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ អនុលោមតាមមាត្រា ១៣៤ ថ្មី នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣។ ច្បាប់នេះ មានគោលដៅបង្កើតនិងកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងគោលបំណងជួយ **ព្រះមហាក្សត្រ** ដើម្បីធានាឯករាជ្យនៃអំណាចតុលាការស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមានវិសាលភាពអនុវត្តទៅលើចៅក្រម និងព្រះរាជអាជ្ញាទូទាំងព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានច្បាប់ដោយឡែកកំណត់ផ្សេងពីនេះ។[២៨]

[២៧] មាត្រា៣ និងមាត្រា៨ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើកាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤

[២៨] មាត្រា១-២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

### ១.៥ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា

ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ត្រូវបានបង្កើតឡើងដោយព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ មានសរុប ៦ ជំពូក ស្មើនឹង ១១១ មាត្រា ក្នុងគោលបំណងកំណត់ពីគោលការណ៍ទាក់ទងនឹងចៅក្រម និងព្រះរាជអាជ្ញា ក្នុងគោលបំណងធានាឯករាជ្យនៃអំណាចតុលាការស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម ធ្វើការបញ្ញត្តិពីតួនាទី និងមុខងាររបស់ចៅក្រមទាំងក្នុងការអនុវត្តការងារពោលគឺចៅក្រមទាំងអស់ ត្រូវតែធ្វើការគោរពឱ្យបានម៉ឺងម៉ាត់នូវច្បាប់ជាធរមាន និងសតិសម្បជញ្ញៈរបស់ខ្លួនពិសេសត្រូវប្រកាន់គោលការណ៍អព្យាក្រឹត្យក្នុងពេលអនុវត្តវិជ្ជាជីវៈ។ ច្បាប់នេះក៏មានកំណត់អំពីឯកសណ្ឋានចៅក្រម ងារកិត្តិយស ប្រាក់បៀវត្ស និងទណ្ឌកម្មវិន័យចំពោះចៅក្រមដែលប្រព្រឹត្តខុសផងដែរ។

## ២. តួនាទីរបស់ចៅក្រម និងព្រះរាជអាជ្ញា

ចៅក្រម និងព្រះរាជអាជ្ញា គឺជាតំណាងនៃតុលាការ និងអយ្យការ ឬអាចហៅជារួមថាអង្គចៅក្រម។ ចៅក្រម និងព្រះរាជអាជ្ញា ជាមន្ត្រីដែលស្ថិតក្រោមក្របខណ្ឌក្រសួងយុត្តិធម៌ និងគ្រប់គ្រងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដូចគ្នា បុគ្គលដែលប្រកបវិជ្ជាជីវៈនេះ មានតួនាទីផ្សេងគ្នានៅក្នុងតុលាការ និងក្នុងអង្គសវនាការៈ

- **ចៅក្រម** ៖ ចៅក្រម គឺជាអ្នកដែលមានអំណាចក្នុងការជំនុំជម្រះក្តីលើជនណាដែលប្រព្រឹត្តបទល្មើសដែលប៉ះពាល់ដល់សណ្តាប់ធ្នាប់ ឬដោយការមិនសុខចិត្តនឹងអ្វីមួយ។ ចៅក្រម មានពីរគឺ៖ ចៅក្រមជំនុំជម្រះដែលជាចៅក្រមទទួលបន្ទុកលើការជម្រះក្តីក្នុងអង្គសវនាការ និង ចៅក្រមស៊ើបសួរ ដែលមានភារកិច្ចក្នុងស៊ើបបន្ថែម ឬសាកសួរជនល្មើសបន្ថែម ក្រោយពីទទួលបានដីកាបញ្ជូនឱ្យសាកសួរពីព្រះរាជអាជ្ញា។
- **ព្រះរាជអាជ្ញា** ៖ ព្រះរាជអាជ្ញា គឺជាបុគ្គលដែលតំណាងឱ្យស្ថាប័នអយ្យការស្ថិតនៅអមជាមួយនឹងតុលាការ។ ព្រះរាជអាជ្ញា ជាម្ចាស់ផ្តាច់មុខនៃបណ្តឹងអាជ្ញា និងការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌនានាទៅលើជនណាដែលមានភស្តុតាងធ្ងន់ល្មមក្នុងការចោទថាបានប្រព្រឹត្តបទល្មើស។

## ៣. ប្រភេទនៃតុលាការជំនាញ និងសាលាជំនាញ

មាត្រា១២៨ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ថា អំណាចក្នុងការជម្រះក្តីត្រូវបានប្រគល់ទៅឱ្យតុលាការកំពូល និងសាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ថ្នាក់។ សាលាជម្រះក្តី គឺជាសាលាដែលទទួលបន្ទុកក្នុងការជំនុំជម្រះលើសំណុំរឿងដែលបុគ្គលណាមួយបានប្រព្រឹត្តខុសនឹងច្បាប់ជាធរមាន ឬដោយមិនសុខចិត្តនឹងអ្វីមួយដែលទាមទារឱ្យមានដំណោះស្រាយផ្លូវច្បាប់។

យោងតាមមាត្រា៣ និងមាត្រា៨ នៃច្បាប់ស្តីពីរៀបចំអង្គការតុលាការ សាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា មាន ៣ប្រភេទ គឺ៖

- សាលាដំបូង
- សាលាឧទ្ធរណ៍
- តុលាការកំពូល

តុលាការទាំង៣ នេះមានសមត្ថកិច្ចរបស់ខ្លួនក្នុងការជម្រះក្តីក្នុងដែនកំណត់របស់ខ្លួន។ សមត្ថកិច្ចរបស់តុលាការកម្ពុជាទាំង ៣ប្រភេទ មានដូចតទៅ៖

១. <u>សាលាដំបូង និងអយ្យការអមសាលាដំបូង:</u> **ការរៀបចំ និង ការប្រព្រឹត្តទៅរបស់សាលាដំបូង៖** សាលាដំបូងជាសាលាជម្រះក្តីថ្នាក់ទីមួយ ដែលបង្កើតឲ្យមាននៅរាជធានីភ្នំពេញ និងគ្រប់បណ្តាខេត្តនៃព្រះរាជាណាចក្រកម្ពុជា។ ការដាក់ឲ្យដំណើរការសាលាដំបូងនានា ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ។ តុលាការជំនាញផ្សេងសាលាដំបូងត្រូវបែងចែកជាតុលាការជំនាញ ដែលមានដូចជាតុលាការរដ្ឋប្បវេណី តុលាការព្រហ្មទណ្ឌ តុលាការពាណិជ្ជកម្ម និងតុលាការការងារ។ តុលាការទៀតអាចនឹងត្រូវបង្កើតឡើងក្នុងករណីដែលចាំបាច់ដោយបង្កើតតាមរយៈព្រះរាជក្រឹត្យ (មាត្រា១៤)។ តុលាការជំនាញនីមួយៗរបស់សាលាដំបូងចេញសេចក្តីសម្រេចរបស់ខ្លួន ប្រកបដោយស្វ័យភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងនាមសាលាដំបូងដែលតុលាការជំនាញនោះស្ថិតនៅ(មាត្រា១៤)។ សមាសភាពរបស់តុលាការជំនាញនីមួយៗរួមមាន ប្រធានតុលាការ ចៅក្រម ក្រឡាបញ្ជី ដែលត្រូវបានចាត់តាំងដោយប្រធានសាលាដំបូង (មាត្រា១៥)។ សាលាដំបូងមានសមត្ថកិច្ចជំនុំជម្រះក្តីទៅលើរឿងក្តីទាំងអស់ លើកលែងតែរឿងក្តីដែលស្ថិតនៅក្រោមសមត្ថកិច្ចនៃសាលាជម្រះក្តីពិសេស ឬសាលាជម្រះក្តីវិសាមញ្ញដែលបង្កើតឡើងដោយច្បាប់ដោយឡែក(មាត្រា១២)។

**អយ្យការអមសាលាដំបូង៖** សមាសភាពអយ្យការអមសាលាដំបូង រួមមាន ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ក្រឡាបញ្ជី មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ទៀតដែលបម្រើការងារនៅអយ្យការអមសាលាដំបូង (មាត្រា២៩)។ អយ្យការជា អង្គអវិភាគ មានមុខងារធ្វើបណ្តឹងអាជ្ញា និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ព្រមទាំងអនុវត្តមុខងារផ្សេងទៀតតាមការកំណត់របស់ច្បាប់ និងបទបញ្ញត្តិជាធរមាន។ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង គឺជាតំណាងអយ្យការអមសាលាដំបូងដែលខ្លួនបំពេញការងារ។ ព្រះរាជអាជ្ញារង ចូលរួមអនុវត្តមុខងាររបស់អយ្យការក្រោមការដឹកនាំ និងទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង (មាត្រា៣០ នៃកថាខណ្ឌទី១ និងទី២)។

២. <u>សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍</u> **ការរៀបចំ និងការប្រព្រឹត្តទៅនៃសាលាឧទ្ធរណ៍៖** សាលាឧទ្ធរណ៍ គឺជាសាលាជម្រះក្តីថ្នាក់ទីពីរ។ ការដាក់ឲ្យដំណើរការសាលាឧទ្ធរណ៍ តំបន់នីមួយៗអំពីសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍តំបន់នេះត្រូវធ្វើដោយអនុក្រឹត្យ (មាត្រា៣៥)។ សមាសភាពសាលាឧទ្ធរណ៍រួមមាន ប្រធាន អនុប្រធាន ចៅក្រម ក្រឡាបញ្ជីនិងមន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅសាលាឧទ្ធរណ៍(មាត្រា៣៦)។ សាលាឧទ្ធរណ៍មានសភាជំនាញដូចជា សភាព្រហ្មទណ្ឌ សភារដ្ឋប្បវេណី សភាស៊ើបសួរ សភាពាណិជ្ជកម្ម និងសភាការងារ។ ក្នុងករណីចាំបាច់ សភាជំនាញផ្សេងទៀតនៃសាលាឧទ្ធរណ៍អាចត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យ។ សភានីមួយៗចេញសេចក្តីសម្រេចដោយស្វ័យភាពក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួនក្នុងនាមសាលាឧទ្ធរណ៍ដែលសភានោះស្ថិតនៅ (មាត្រា៣៧)។ ចំណែកឯសមាសភាពនីមួយៗរួមមាន៖ ប្រធានសភា ចៅក្រម និងក្រឡាបញ្ជី ដែលត្រូវចាត់តាំងដោយប្រធានសាលាឧទ្ធរណ៍ និងចំនួនចៅក្រម ក្រឡាបញ្ជី និងដំណើរការរបស់សភាទាំងនេះ ត្រូវកំណត់ដោយប្រធានសាលាឧទ្ធរណ៍ (មាត្រា៣៨)។ សាលាឧទ្ធរណ៍ មាន សមត្ថកិច្ចជំនុំជម្រះរឿងក្តី ដែលស្ថិតក្នុងដែនដីរបស់ខ្លួនលើកលែងរឿងក្តីទាំងឡាយដែលច្បាប់ប្រគល់សមត្ថកិច្ចទៅឲ្យតុលាការផ្សេងទៀត (មាត្រា៤១)។

**មហាអយ្យការអមសាលាឧទ្ធរណ៍៖** នៅអមសាលាឧទ្ធរណ៍មានមហាអយ្យការមានសមាសភាពដូចជា អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅមហាអយ្យការអមសាលាឧទ្ធរណ៍។ មហាអយ្យការអមសាលាឧទ្ធរណ៍ត្រូវបានប្រគល់មុខងារឲ្យព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលត្រូវចូលរួមក្នុងការអនុវត្តមុខងារនេះ ក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍(មាត្រា៥០ កថាខណ្ឌទី១)។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានអំណាចគ្រប់គ្រងលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ចាត់តាំង និងបែងចែកដល់អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ក្នុងការងារផ្សេងៗនៃមហាអយ្យការ និងអង្គជំនុំជម្រះ (មាត្រា៥១ នៃកថាខណ្ឌទី១ និងទី២)។

៣. <u>តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល</u> **ការរៀបចំ និងការប្រព្រឹត្តទៅរបស់តុលាការកំពូល៖** តុលាការកំពូលមានតែមួយគត់ ដែលមានទីតាំងនៅរាជធានីភ្នំពេញ(មាត្រា៥៥) ដែលមានសមាសភាពដូចជា ប្រធាន អនុប្រធាន ចៅក្រម ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅតុលាការកំពូល(មាត្រា៥៦)។ តុលាការកំពូលមានសភាជំនាញដូចជា សភាព្រហ្មទណ្ឌ សភារដ្ឋប្បវេណី សភាពាណិជ្ជកម្ម និងសភាការងារ។ ក្នុងករណីចាំបាច់ សភាជំនាញផ្សេងទៀតនឹងអាចត្រូវបានបង្កើតដោយព្រះរាជក្រឹត្យ។ សភានីមួយៗចេញសេចក្តីសម្រេចរបស់ខ្លួនប្រកបដោយស្វ័យភាព ក្នុងនាម

តុលាការកំពូល (មាត្រា៥៧)។ រីឯសមាសភាពរបស់សភានីមួយៗរួមមាន ប្រធានសភា ចៅក្រម និងក្រឡាបញ្ជី ដែលត្រូវចាត់តាំងដោយប្រធានតុលាការកំពូល។ ចំនួនចៅក្រម ក្រឡាបញ្ជី និងដំណើរការរបស់សភាទាំងនេះ ត្រូវកំណត់ដោយប្រធានតុលាការកំពូល(មាត្រា៥៨)។

តុលាការកំពូល មានសមត្ថកិច្ចដោះស្រាយរឿងក្តីដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន ស្របតាមការកំណត់របស់ច្បាប់(មាត្រា៦១)។ ក្នុងនោះផងដែរ សភាពេញអង្គត្រូវបានបង្កើតឲ្យមានដំណើរការ ដោយដីកាសម្រេចរបស់ប្រធានតុលាការកំពូល ដើម្បីជំនុំជម្រះជាអាទិ៍៖

- លើបណ្តឹងសាទុក្ខលើកទីពីរចំពោះសាលដីការបស់សាលាឧទ្ធរណ៍ ស្របតាមនីតិវិធីជាធរមាន
- លើបណ្តឹងសើរើចំពោះសាលក្រម និងសាលដីកាស្ថាពរ ស្របតាមនីតិវិធីជាធរមាន។

សភាពេញអង្គក៏អាចត្រូវបានបង្កើតឲ្យមានដំណើរការផងដែរ ដើម្បីជំនុំជម្រះលើបណ្តឹងសើរើ ឬបណ្តឹងជំនុំជម្រះសាជាថ្មី ក្នុងករណីដែលមានកាស្នើសុំឲ្យមានការពិនិត្យ និងសម្រេចឡើងវិញចំពោះរឿងក្តីណាមួយពីព្រះមហាក្សត្រ ដែលជាព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ សភាពេញអង្គប្រព្រឹត្តទៅតាមការអញ្ជើញរបស់ប្រធានតុលាការកំពូល។ សភាពេញអង្គនៃតុលាការកំពូល គឺជាអង្គជំនុំជម្រះដែលចេញសេចក្តីសម្រេចក្នុងនាមតុលាការកំពូល (មាត្រា៦២)។

**មហាអយ្យការអមតុលាការកំពូល៖** មហាអយ្យការអមតុលាការកំពូលមានសមាសភាពដូចជា អគ្គព្រះរាជអាជ្ញា អង្គព្រះរាជអាជ្ញារង ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅមហាអយ្យការអមតុលាការកំពូល(មាត្រា៦៨)។ មុខងាររបស់មហាអយ្យការអមតុលាការកំពូល ត្រូវបានប្រគល់ឲ្យអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល ចូលរួមអនុវត្តមុខងារនេះ ក្រោមការដឹកនាំ និងការទទួលខុសត្រូវរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល(មាត្រា៦៩ នៃកថាខណ្ឌទី១)។ អគ្គព្រះរាជអាជ្ញាអមតុលាការឧទ្ធរណ៍ មានអំណាចគ្រប់គ្រងលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលចាត់តាំង និងបែងចែកដល់អគ្គព្រះរាជអាជ្ញារង និង ព្រះរាជអាជ្ញាអមតុលាការកំពូលទៅក្នុងការងារផ្សេងៗនៃមហាអយ្យការ និងក្នុងអង្គជំនុំជម្រះ(មាត្រា៧០ នៃកថាខណ្ឌទី១)។

ចំពោះថវិកាសាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តី ត្រូវបានបញ្ញត្តិក្នុងមាត្រា៧៩ ដែលសាលាដំបូង និងអយ្យការអមសាលាដំបូង សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រមទាំងតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល មានកញ្ចប់ថវិការដោយឡែក សម្រាប់ដំណើរការ ដែលស្ថិតនៅក្នុងកញ្ចប់ថវិការរបស់ក្រសួងយុត្តិធម៌។ ប្រធានសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ជាអាណាប័កផ្ទេរសិទ្ធិពីរដ្ឋមន្ត្រី

ក្រសួងយុត្តិធម៌។ ចំពោះការគ្រប់គ្រង និងការចាត់ចែងថវិការបស់សាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីដូចបានកំណត់ក្នុងមាត្រានេះ កថាខណ្ឌទី១ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ២.១ តុលាការជំនាញនៃតុលាការជាន់ទាប

តុលាការជំនាញនៃតុលាការជាន់ទាប គឺជាតុលាការដែលធ្វើឡើងនៅក្នុងតុលាការជាន់ទាប ដែលមានតួនាទីជំនាញរបស់ខ្លួន ដូចជា៖ ព្រហ្មទណ្ឌ រដ្ឋប្បវេណី ពាណិជ្ជកម្ម ការងារ ជាដើម។ តុលាការជំនាញនៃសាលាដំបូង មានដូចជាតុលាការរដ្ឋប្បវេណី តុលាការព្រហ្មទណ្ឌ តុលាការពាណិជ្ជកម្ម និងតុលាការការងារ។ តុលាការជំនាញដទៃទៀត អាចនឹងត្រូវបង្កើតឡើងក្នុងករណីដែលចាំបាច់ដោយបង្កើតតាមរយៈព្រះរាជក្រឹត្យ (មាត្រា១៤)។

### ៣.១.១ តុលាការព្រហ្មទណ្ឌ និងតុលាការរដ្ឋប្បវេណី

- **តុលាការព្រហ្មទណ្ឌៈ** ទទួលបន្ទុកលើការងារផ្នែកព្រហ្មទណ្ឌ និងចាត់ការលើបណ្តឹងអាជ្ញាដែលដាក់មកដោយតំណាងអយ្យការដោយអនុលោមតាមបទប្បញ្ញត្តិនៃនីតិវិធីព្រហ្មទណ្ឌ[២៩]
- **តុលាការរដ្ឋប្បវេណីៈ** ទទួលបន្ទុកលើវិវាទផ្នែករដ្ឋប្បវេណី និងចាត់ការលើរាល់បណ្តឹងដទៃទៀតដែលពុំមានបទប្បញ្ញត្តិណាមួយប្រគល់សមត្ថកិច្ចទៅតុលាការជំនាញដទៃ ដោយអនុវត្តតាមបទប្បញ្ញត្តិនៃនីតិវិធីរដ្ឋប្បវេណី។[៣០]

### ៣.១.២ តុលាការពាណិជ្ជកម្ម និងតុលាការការងារ

- **តុលាការពាណិជ្ជកម្មៈ** ទទួលបន្ទុកលើវិវាទពាណិជ្ជកម្មក្នុងការងារពាណិជ្ជកិច្ច រឿងក្តីក្ស័យធនក្នុងរឿងពាណិជ្ជកម្មដោយអនុវត្តតាមបទប្បញ្ញត្តិនៃនីតិវិធីពាណិជ្ជកម្ម។ ដំណើរការងារដែលប្រព្រឹត្តទៅក្នុងវិវាទពាណិជ្ជកម្ម ត្រូវធ្វើឡើងដោយមាត្រាបន្តបន្ទាប់។[៣១]
- **តុលាការការងារៈ** ទទួលបន្ទុកលើការដោះស្រាយរឿងក្តីការងារដែលមានសមត្ថកិច្ចជំនុំជម្រះតាមបទប្បញ្ញត្តិនៃនីតិវិធីការងារ។[៣២]

តុលាការជំនាញនីមួយៗខាងលើរបស់សាលាដំបូង មានចៅក្រម និងមន្ត្រីជំនាញក្នុងការជំនុំជម្រះលើសំណុំរឿង និង មានសិទ្ធិក្នុងការចេញសេចក្តីសម្រេចរបស់ខ្លួនប្រកបដោយស្វ័យភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងនាមសាលាដំបូងដែលតុលាការជំនាញនោះស្ថិតនៅ (មាត្រា១៤)។ សេចក្តីសម្រេចរបស់តុលាការជំនាញនៃសាលាដំបូងមានតម្លៃដូចនឹងសាលក្រមតុលាការដែរ។ នៅក្នុងការងាររដ្ឋបាល តុលាការជំនាញមានប្រធានមួយរូប ដែលសមាសភាពនៃប្រធាននោះ ជាចៅក្រមដែលមានជំនាញផ្នែកនោះ (ការជ្រើសរើសប្រធាននៃតុលាការ

ជំនាញណាមួយត្រូវធ្វើឡើងដោយប្រធានតុលាការ) ក្នុងករណីតុលាការជំនាញមានវិវាទ ប្រធានតុលាការជាអ្នកទទួលបន្ទុកក្នុងការដោះស្រាយ និងចេញដីកាសម្រេចបិទផ្លូវតវ៉ា។ (មាត្រា១៩ នៃច្បាប់រៀបចំអង្គការតុលាការ)

## ២.២ សភាជំនាញនៃតុលាការជាន់ខ្ពស់

តុលាការជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា បែងចែកជា សាលាឧទ្ធរណ៍ និង តុលាការកំពូល។ សាលាជម្រះក្តីជាន់ខ្ពស់ទាំងពីរនេះមានសភាជំនាញរបស់ខ្លួន។

### ២.២.១ សភាជំនាញនៃសាលាឧទ្ធរណ៍

សាលាឧទ្ធរណ៍ មានជំនាញរបស់ខ្លួនចំនួន ៥ គឺៈ

- **សភាព្រហ្មទណ្ឌៈ** ទទួលបន្ទុកលើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូង និងរឿងក្តីផ្សេងទៀតដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ (មាត្រា៤៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ)
- **សភារដ្ឋប្បវេណីៈ** ទទួលបន្ទុកលើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមរដ្ឋប្បវេណីរបស់សាលាដំបូង និងរឿងក្តីផ្សេងទៀតដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ (មាត្រា៤៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ)
- **សភាស៊ើបសួរៈ** ទទួលបន្ទុកលើបណ្តឹងនានាចំពោះកិច្ចស៊ើបសួរ និងដីកាសម្រេចនានារបស់ចៅក្រមស៊ើបសួរដែលស្ថិតក្នុងរឿងក្តីដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន។ (មាត្រា៤៥ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ)
- **សភាពាណិជ្ជកម្មៈ** ទទួលបន្ទុកលើការជម្រះលើបណ្តឹងឧទ្ធរណ៍ និងសាលក្រម និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលក្រម និងរឿងក្តីដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន។ (មាត្រា៤៦)
- និង **សភាការងារៈ** ទទួលបន្ទុកលើការជម្រះលើបណ្តឹងឧទ្ធរណ៍ និងសាលក្រមរឿងក្តីពាណិជ្ជកម្ម និងរឿងក្តីផ្សេងទៀតដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន។ (មាត្រា៤៦)

សភាជំនាញនៃសាលាឧទ្ធរណ៍ ចេញសេចក្តីសម្រេចក្នុងនាមសាលាឧទ្ធរណ៍។

### ២.២.១ សភាជំនាញនៃតុលាការកំពូល

តុលាការកំពូល មានជំនាញរបស់ខ្លួនចំនួន ៥ គឺៈ

- សភាព្រហ្មទណ្ឌ
- សភារដ្ឋប្បវេណី
- សភាស៊ើបសួរ
- និង សភាការងារ

[២៩-៣០] មាត្រា២០ និងមាត្រា២១ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

[៣១-៣២] មាត្រា២២ និងមាត្រា២៥ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

ប្រធាននៃសភាជំនាញនីមួយៗ ត្រូវបានចាត់តាំងដោយប្រធានតុលាការកំពូលចំណែកសមាសភាពនៃចៅក្រមជំនាញនៃសភានីមួយៗគឺ ០៥ រូបដែលមានមួយរូបជាប្រធាន។ សភាជំនាញចេញសេចក្តីសម្រេចក្នុងនាមតុលាការកំពូល។

## ផ្នែកទី២៖ នីតិវិធីនៃការទទួលបណ្តឹង និងការលើកយកបណ្តឹងមកកាត់សេចក្តី

### ១. សិទ្ធិជាមូលដ្ឋាន ក្នុងការដាក់ពាក្យបណ្តឹង និងទទួលបានការការពារតាមផ្លូវតុលាការ

សិទ្ធិជាមូលដ្ឋានក្នុងការដាក់ពាក្យបណ្តឹង និង ទទួលបានការការពារតាមផ្លូវតុលាការគឺជាគោលការណ៍ដែលកំណត់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងដោយលិខិតបទដ្ឋានគតិយុត្តអន្តរជាតិនានា ក្នុងន័យបើកឱ្យមនុស្សគ្រប់រូបទោះមាន ឬក្រ ចំណេះដឹងតិចច្រើន គ្រប់ពូជសម្បុរ និងសាសនា អាចទទួលបានសិទ្ធិគ្រប់គ្រាន់ក្នុងការដាក់ពាក្យបណ្តឹង និងទទួលបានការការពារតាមផ្លូវតុលាការ។

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ[២៩] ហេតុនេះការទទួលបានការការពារតាមផ្លូវតុលាការគឺជាសិទ្ធិមូលដ្ឋានដែលរដ្ឋបានទទួលស្គាល់។ ជាទូទៅ ការដាក់ពាក្យបណ្តឹងត្រូវធ្វើឡើង ដោយហេតុមានភាគីណាមួយមិនសុខចិត្តនឹងអ្វីដែលគេបានជួបហើយធ្វើការទាមទាររកដំណោះស្រាយតាមរយៈតុលាការដោយទុកសមត្ថកិច្ចឱ្យច្បាប់ជាអ្នកចាត់ការ នៅក្នុងពាក្យបណ្តឹង ដើមចោទធ្វើសកម្មភាពទាមទារចំពោះចុងចម្លើយទៅតុលាការដើម្បីបើកការជំនុំជម្រះលើកទីមួយដែលត្រូវបានកំណត់ *ឧទាហរណ៍៖ ការដាក់ពាក្យបណ្តឹងទៅសាលាដំបូងរាជធានី-ខេត្ត ដោយដើមចោទ បានលើកឡើងពីការអះអាងអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តិតាមផ្លូវច្បាប់នីតិឯកជនកំណត់មួយ។*

ការអះអាងបែបនេះ គេហៅថា ការទាមទារតាមផ្លូវបណ្តឹង មានន័យថា ចាំបាច់ត្រូវអះអាងអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់សារជាតុដែលបានកំណត់គោលបំណងក្នុងការទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារកំណត់មួយ ដោយផ្អែកលើការអះអាងទាំងនេះហើយជាគោលការណ៍សកម្មភាពបណ្តឹងទាំងនេះត្រូវបានធ្វើឡើងតាមវិធីដាក់ពាក្យបណ្តឹង ដូចនេះតាមរយៈការដាក់ពាក្យបណ្តឹង នីតិវិធីនៃបណ្តឹងនឹងត្រូវបានចាប់ផ្តើម។ ការទទួលពាក្យបណ្តឹង ពុំអាចត្រូវបានដាក់ឱ្យអនុវត្តភ្លាមៗទេ ជាទូទៅសំណុំរឿងមួយត្រូវមានការចុះលេខ វាយត្រា និងពិនិត្យដោយក្រឡាបញ្ជីតុលាការ និងបែងចែកទៅឱ្យចៅក្រមតាមលំដាប់ដែលមានរៀបដោយមន្ត្រីតុលាការ។ ការចាប់ផ្តើមនីតិវិធីបណ្តឹង គឺជាកិច្ចដែលតុលាការចាប់ផ្តើមអនុវត្តការងាររបស់ខ្លួនដូចការប្តឹងរបស់ភាគីដោយកំណត់ពីប្រភេទសំណុំរឿង និងតម្រូវឱ្យភាគីអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការស្វែងរកអ្នកតំណាងជាមេធាវី សាក្សី ឬភស្តុតាងបន្ថែមដើម្បីយកជាមូលដ្ឋានក្នុងការតវ៉ានៅក្នុងអង្គសវនាការ។

## ២. ការប្រព្រឹត្តទៅនៃសំណុំរឿងព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ គឺជាសំណុំរឿងដែលកើតចេញពីបណ្តឹងអាជ្ញា។ សំណុំរឿងព្រហ្មទណ្ឌ គឺជាសំណុំរឿងដែលកើតចេញពីកាយវិការ ឬសម្តីដែលធ្វើឡើងដោយបុគ្គលណាមួយ ហើយបានបង្កឱ្យមាននូវផលប៉ះពាល់ដល់សណ្តាប់ធ្នាប់រៀបរយរបស់សង្គម និង ដោយសកម្មភាពនោះផ្ទុយពីបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ សំណុំរឿងព្រហ្មទណ្ឌ ធ្វើឡើងក្នុងដោយព្រះរាជអាជ្ញា ដែលជាមន្ត្រីនៅអង្គការអយ្យការ មានតួនាទីទទួលបន្ទុកផ្នែកបណ្តឹងអាជ្ញា និងជាអ្នកចោទ ក៏ដូចជាបញ្ជូនរឿងនេះទៅតុលាការជំនាញដើម្បីជំនុំជម្រះ។

បណ្តឹងព្រហ្មទណ្ឌចែកចេញជា ២ គឺ[២៩]៖

- **<u>បណ្តឹងអាជ្ញា</u>៖** មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឲ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននោះតាមច្បាប់កំណត់។
- **<u>បណ្តឹងរដ្ឋប្បវេណី</u>៖** ជាបណ្តឹងដែលធ្វើដោយជនរងគ្រោះ ដែលមានគោលបំណងធ្វើឲ្យបានជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះឲ្យអ្នករងគ្រោះបានទទួលសំណងជម្ងឺចិត្តជូនល្មមនឹងព្យសនកម្មដែលខ្លួនបានទទួល។

### ២.១ ការទទួលពាក្យបណ្តឹង និងការធ្វើបណ្តឹងអាជ្ញា

ការទទួលពាក្យបណ្តឹងព្រហ្មទណ្ឌ ត្រូវធ្វើឡើងដោយអង្គការអយ្យការដែលមានព្រះរាជអាជ្ញាជាអ្នកទទួលបន្ទុក។ កាតព្វកិច្ចនេះ ត្រូវកំណត់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ជាធរមានរបស់កម្ពុជា។ ដើម្បីបើកសំណុំរឿងព្រហ្មទណ្ឌបាន ដើមចោទ ត្រូវចាប់ផ្តើមដោយការដាក់ពាក្យបណ្តឹង ក្រឡាបញ្ជីត្រូវបោះត្រាបញ្ជាក់ពីថ្ងៃ-ខែ-ឆ្នាំ ដែលបានទទួលពាក្យបណ្តឹង ដោយបន្ថែមក្រប ព្រមទាំងចុះលេខបណ្តឹងផង។

នៅក្នុងតុលាការ និងអយ្យការ ការទទួលបណ្តឹងព្រហ្មទណ្ឌ ធ្វើឡើងតាមរយៈ ២ របៀបគឺ៖

- ការទទួលបានពីភ្នាក់ងារនគរបាលយុត្តិធម៌ ក្រោយពីបានចាប់ជនសង្ស័យណាមួយដែលពាក់ព័ន្ធនឹងការរំលោភលើបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ ឬដោយប្រព្រឹត្តបទល្មើសជាក់ស្តែងណាមួយដែលផ្ទុយពីច្បាប់
- ការប្តឹងមកដោយផ្ទាល់ដោយប្រជាពលរដ្ឋ និងដោយមានការសម្របសម្រួលពីនគរបាលមានសមត្ថកិច្ច

បណ្តឹងអាជ្ញា គឺជាបណ្តឹងសុំឲ្យពិន័យជាប្រាក់ ឬដាក់ពន្ធនាគារមានកាលកំណត់ ឬ ដាក់ពន្ធនាគារអស់មួយជីវិត ចំពោះជនដែលប្រព្រឹត្តអំពើដែលនាំឲ្យគ្រោះថ្នាក់ដល់សង្គម ឬប្រឆាំងនឹងច្បាប់ព្រហ្មទណ្ឌ។ បណ្តឹងអាជ្ញា ត្រូវបានគេមើលឃើញថាជា បណ្តឹងប្រឆាំងនឹងជនល្មើសដែលបានប្រព្រឹត្តបទល្មើសណាមួយដោយទាមទារឲ្យតុលាការផ្តន្ទាទោសជននោះទៅតាមច្បាប់។

[២៩] មាត្រា១៨ និង ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើកាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣

បណ្ដឹងអាជ្ញា មានគោលបំណងពិនិត្យទៅលើ អត្ថិភាពនៃបទល្មើស និងបង្ហាញឲ្យឃើញនូវពិរុទ្ធភាពនៃជនល្មើស និង ផ្ដន្ទាទោសជននេះតាមច្បាប់កំណត់។ យោងតាមការកំណត់និយមន័យនេះទ្រឹស្ដីព្រហ្មទណ្ឌបានកំណត់ពីចរិតនៃបទល្មើសដូចខាងក្រោមនេះ៖

- អំពើដែលបង្កឲ្យមានគ្រោះថ្នាក់ដល់សង្គម
- អំពើដែលច្បាប់ព្រហ្មទណ្ឌបានកំណត់ថាជាបទល្មើស
- គោលការណ៍នៃកំហុសដោយចេតនា ឬអចេតនា។

ស្ថាប័នអយ្យការ គឺជាម្ចាស់បណ្ដឹងអាជ្ញា ឬជាទូទៅត្រូវបានហៅថា "បណ្ដឹងព្រហ្មទណ្ឌ"។[៣០] អង្គអយ្យការ ជាម្ចាស់បណ្ដឹងអាជ្ញាមាននៅអមគ្រប់សាលាជម្រះក្ដីបំពេញតួនាទីការពារផលប្រយោជន៍ និង សណ្ដាប់ធ្នាប់សាធារណៈ។ ការចាប់ផ្ដើមបណ្ដឹងអាជ្ញាដោយអយ្យការ មានន័យថាតំណាងអយ្យការធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ (អាចជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ) ដោយអយ្យការត្រូវធ្វើការចោទប្រកាន់ និងសុំឲ្យអនុវត្តច្បាប់ចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។ ការចាប់ផ្ដើមបណ្ដឹងអាជ្ញា ដោយជនរងគ្រោះជាគោលការណ៍ថ្មីនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដែលអនុញ្ញាតឲ្យជនរងគ្រោះអាចដាក់ពាក្យបណ្ដឹងដោយតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ។ ពាក្យបណ្ដឹងនេះមានអានុភាពប្ដឹងដល់ចៅក្រមស៊ើបសួរអំពីបណ្ដឹងអាជ្ញានៅក្នុងលក្ខខណ្ឌដែលបានបញ្ញត្តិដោយមាត្រា ១៣៩ បានចែងអំពីការបញ្ជូនបណ្ដឹងទៅព្រះរាជអាជ្ញា និងមាត្រា១៤០ ការបង់ប្រាក់តម្កល់នៃក្រមនេះ។ ជាទូទៅ នៅពេលដែលតំណាងអយ្យការ រួមមាន អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង បានដឹង ឬបានទទួលពាក្យបណ្ដឹងពីជនរងគ្រោះ ឬក៏កំណត់ហេតុពីមន្ត្រីនគរបាលយុត្តិធម៌ ពាក់ព័ន្ធនឹងបទល្មើសណាមួយ អាចធ្វើការចោទប្រកាន់ទៅលើអំពើនោះ ឬ សម្រេចតម្កល់រឿងទុកឥតចាត់ការ។ ក្នុងករណីដែលតំណាងអយ្យការពិនិត្យឃើញថា អំពើនោះមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ដើម្បីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយ នោះអយ្យការ ត្រូវធ្វើការចោទប្រកាន់ហើយអាចជ្រើសរើសបើកការស៊ើបសួរ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរ ឬតាមការបញ្ជូនជំនុំជម្រះផ្ទាល់ ឬនីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម។ ប៉ុន្តែប្រសិនបើអយ្យការយល់ឃើញថា អំពើទាំងនោះពុំមានធាតុផ្សំគ្រប់គ្រាន់ទេ អយ្យការអាចសម្រេចមិនធ្វើការចោទប្រកាន់ ដោយតម្កល់រឿងទុកឥតចាត់ការតាមរយៈដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ។

## ២.២ នីតិវិធីនៃការសួរចម្លើយជនត្រូវចោទនៅជំណាក់កាលអយ្យការ

ការចោទប្រកាន់ជាតួនាទីរបស់អយ្យការ ដែលការចោទប្រកាន់ធ្វើឡើងតាមរយៈបណ្ដឹងអាជ្ញា។ ព្រះរាជអាជ្ញាដឹកនាំ និង សម្របសម្រួលសកម្មភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ និង ភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់

នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ហេតុនេះហើយ ព្រះរាជអាជ្ញាអាចចុះទៅកាន់កន្លែងស៊ើបអង្កេត និង ធ្វើគ្រប់ការណែនាំដែលមានប្រយោជន៍ដល់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌។

ជាទូទៅ នៅពេលដែលជនសង្ស័យណាដែលគេរកឃើញថាមានពាក់ព័ន្ធ ឬបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ត្រូវបានគេឃាត់ខ្លួន មានភស្តុតាង និង ឆ្លងតាមកំណត់ហេតុសួរចម្លើយរបស់នគរបាល ជននោះនឹងត្រូវបញ្ជូនទៅតំណាងអយ្យការនៃសាលាដំបូងនៃទីតាំងបទល្មើស ដើម្បីឱ្យព្រះរាជអាជ្ញាធ្វើការសាកសួរ ដំណាក់កាលនេះ ហៅថា **ដំណាក់កាលអយ្យការ** ដែលព្រះរាជអាជ្ញាត្រូវធ្វើការសាកសួរជនសង្ស័យបន្ថែម ក្នុងន័យបញ្ជាក់ និងស្វែងរកនូវភស្តុតាងដែលអាចជាបន្ទុក(ធាតុផ្សំបទល្មើស) ដើម្បីធ្វើការចោទប្រកាន់ទៅលើជននោះ។ ការសួរចម្លើយនៅដំណាក់កាលអយ្យការ ត្រូវអមដោយក្រឡាបញ្ជី និងមេធាវីរបស់ជនសង្ស័យ (ប្រសិនបើមាន) ក្រោយពីការសួរចម្លើយក្រឡាបញ្ជីនឹងធ្វើកំណត់ហេតុ

មួយ ប្រសិនបើមានពិរុទ្ធភាពគ្រប់គ្រាន់ ព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់ជននោះដោយដីកាសន្និដ្ឋានបញ្ជូនទៅស៊ើបសួរ (ទៅចៅក្រមស៊ើប) ផ្ទុយទៅវិញ ប្រសិនបើពិនិត្យ និងសាកសួរទៅពុំមានពិរុទ្ធភាពក្នុងការចោទប្រកាន់ទេ ព្រះរាជអាជ្ញា ធ្វើការលើកការតម្កល់រឿងទុកឥតចាត់ការ។

ក្នុងករណីកង្វះភស្តុតាងក្នុងការចោទប្រកាន់ តំណាងអយ្យការអាចធ្វើការស្វែងរកភស្តុតាងបន្ថែម ដើម្បីឱ្យរកភស្តុតាងថ្មី ឬ ដោយព្រះរាជអាជ្ញាបើកការសាកសួរបឋម ឬ ការស៊ើបអង្កេតបន្ថែមដោយយោងតាមមាត្រា ៤០ កថាខណ្ឌទី២ វាក្យខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

បុគ្គលដែលត្រូវបានតំណាងអយ្យការចោទថាបានប្រព្រឹត្តបទល្មើស ដែលជននោះហៅថា **ជនត្រូវចោទ** នឹងត្រូវបញ្ជូនបន្តចៅក្រមស៊ើបសួរដោយដីកាបញ្ជូនទៅស៊ើបសួរ ដែលដំណាក់កាលបន្ទាប់នេះ ហៅថា **ដំណាក់កាលចៅក្រមស៊ើប** ។

### ២.៣ នីតិវិធីនៅដំណាក់កាលចៅក្រមស៊ើបសួរ

ដំណាក់កាលចៅក្រមស៊ើបសួរ គឺជានីតិវិធីបន្តដែលចៅក្រមស៊ើបសួរត្រូវអនុវត្ត បន្ទាប់ពីទទួលបានដីកាបញ្ជូនឱ្យស៊ើបសួរពីតំណាងអយ្យការ។ នៅដំណាក់កាលចៅក្រមស៊ើប ចៅក្រមស៊ើបធ្វើការពិនិត្យមើលភស្តុតាងដាក់បន្ទុកដែលតំណាងអយ្យការបានចោទលើជនត្រូវចោទ និងធ្វើការស៊ើបបន្ថែមលើសំណុំរឿងនេះ ប្រសិនបើចៅក្រមស៊ើបពិនិត្យទៅឃើញថា ជនត្រូវចោទ ពិតជាមានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់មែន ចៅក្រមស៊ើបសួរធ្វើការចេញដីកាបញ្ជូនទៅតំណាងអយ្យការវិញ ដើម្បីចេញដីកាសន្និដ្ឋានស្ថាពរ និងបញ្ជូនទៅចៅក្រមជំនុំជម្រះ ដើម្បីការជំនុំជម្រះតាមទង្វើដែលជនជាប់ចោទបានប្រព្រឹត្ត និងទៅតាមបញ្ញត្តិច្បាប់ជាធរមាន។

[២៩] មាត្រា២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[៣០] ការបកស្រាយប្រធានបទស្តីពី **បណ្តឹងអាជ្ញា** តាមរយៈកម្មវិធីយល់ដឹងផ្នែកច្បាប់របស់អង្គភាពព័ត៌មាន Fresh News

## ២.៤ ដំណាក់កាលជំនុំជម្រះ

ដំណាក់កាលជំនុំជម្រះ គឺជាដំណាក់កាលចុងក្រោយក្នុងកំណត់ទោស និងទណ្ឌកម្មរបស់បុគ្គលដែលបានប្រព្រឹត្តអំពើដែលផ្ទុយអំពីច្បាប់ជាធរមាន។ នៅក្នុងដំណាក់កាលជំនុំជម្រះ មានចៅក្រមប្រឹក្សា ព្រះរាជអាជ្ញា ក្រឡាបញ្ជី មេធាវី សាក្សី និងភាគីដើមចោទ (ប្រសិនបើមានវត្តមាន) ដោយធ្វើការបើកការជម្រះលើករណីបុគ្គលនោះ នៅពេលជំនុំជម្រះ ព្រះរាជអាជ្ញា នឹងធ្វើការសាកសួរ ក៏ដូចជាធ្វើសេចក្តីសន្និដ្ឋានទៅចៅក្រមប្រឹក្សាដើម្បីឱ្យចៅក្រមសម្រេចលើទណ្ឌកម្មស្របតាមការណ៍ដែលបានប្រព្រឹត្ត ការជំនុំជម្រះ ក៏តម្រូវឱ្យជនជាប់ចោទមានមេធាវីដែរ ដូចនេះ នៅដំណាក់កាលជំនុំជម្រះព្រះរាជអាជ្ញា និងមេធាវីការពារជនជាប់ចោទ សុទ្ធតែរករកវិធីដើម្បីធ្វើយ៉ាងណាឱ្យចៅក្រមស្របតាមការលើកឡើង និងសម្រេចសេចក្តីដែលស្តែងចេញតាមរយៈសាលក្រម។

បុគ្គលមានពិរុទ្ធភាព និងត្រូវបានតុលាការធ្វើការឃុំខ្លួនក្នុងពេលវេលាកំណត់ ត្រូវទទួលទោសដែលបានកំណត់នោះ ប៉ុន្តែបើគេមិនពេញចិត្តទេច្បាប់បើកឱ្យជនជាប់ចោទធ្វើការតវ៉ាទៅតុលាការជាន់ខ្ពស់តាមបញ្ញត្តិច្បាប់ក្នុងកាលកំណត់។ ជនដែលត្រូវបានតុលាការចោទប្រកាន់ និងបញ្ជូនឱ្យឃុំខ្លួននៅពន្ធនាគារ ហៅថា **ទណ្ឌិត**។

## ៣. ការប្រព្រឹត្តទៅនៃសំណុំរឿងរដ្ឋប្បវេណី

បណ្តឹងរដ្ឋប្បវេណី គឺជាសិទ្ធិមួយដែលច្បាប់ទទួលស្គាល់សម្រាប់បុគ្គលឯកជន អាចជារូបវន្តបុគ្គល ឬជានីតិបុគ្គល ក្នុងការធ្វើបណ្តឹងទៅស្ថាប័នតុលាការ ឲ្យជួយដោះស្រាយនូវបញ្ហាដែលកើតមានឡើងក្នុងគោលបំណងទាមទារឲ្យតុលាការចេញសាលក្រមតាមការទាមទារដោយផ្អែកតាមភស្តុតាង និងគតិច្បាប់។

គោលបំណងនៃបណ្តឹងរដ្ឋប្បវេណីគឺ សិទ្ធិពឹងពាក់តុលាការ[៣៣] ដូចជា៖

- មានគោលបំណងឲ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណី ដោយពឹងផ្អែកលើច្បាប់ ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន។
- ជនគ្រប់រូបត្រូវបានធានានូវសិទ្ធិពឹងពាក់តុលាការចំពោះវិវាទរដ្ឋប្បវេណី ដែលមានចែងក្នុងមាត្រា២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

តុលាការដែលមានសមត្ថកិច្ចត្រូវ បានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍។ បណ្តឹងចំពោះចុងចម្លើយដែលបានកំណត់ក្នុងចំណុចខាងក្រោមត្រូវដាក់ពាក្យបណ្តឹងនៅសាលាដំបូង ដែលមានកំណត់សមត្ថកិច្ចជម្រះក្តីនៅទីកន្លែងដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោម៖

ក. រូបវន្តបុគ្គល៖ លំនៅឋានរបស់ចុងចម្លើយ ឬនៅទីសំណាក់ បើមានលំនៅឋានមិនពិតប្រាកដនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬក៏លំនៅឋានចុងក្រោយ បើពុំមានទីសំណាក់ ឬមានទីសំណាក់មិនពិតប្រាកដ។

ខ. នីតិបុគ្គលក្នុងប្រទេសៈ ទីតាំងនៃទីស្នាក់ការ ឬទីកន្លែងអាជីវកម្មជាចម្បង ឬទៅទីលំនៅឋានរបស់អ្នកតំណាង ឬរបស់អ្នកទទួលខុសត្រូវភារកិច្ចចាត់ចែងការងារជាចម្បង បើគ្មានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មទេ។

គ នីតិបុគ្គលបរទេសៈ ទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មជាចម្បង។.ឬទីលំនៅឋានរបស់អ្នកទទួលខុសត្រូវភារកិច្ចចាត់ចែងការងារជាមធ្យមក្នុងព្រះរាជាណាចក្រកម្ពុជា បើគ្មានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនៅក្នុងប្រទេសព្រះរាជាណាចក្រកម្ពុជា ទេ (មាត្រា៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

## ៣.១ ការទទួលបណ្តឹងរដ្ឋប្បវេណី

បណ្តឹងរដ្ឋប្បវេណី ជាបណ្តឹងដែលមានគោលបំណងធ្វើឱ្យមានការជួសជុលការខូចខាតដែលបណ្តាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះអ្នករងគ្រោះបានទទួលសំណងជំងឺចិត្តសមល្មមនឹងកំហូចខាតដែលខ្លួនបានបាត់បង់។ ការដាក់ពាក្យបណ្តឹងត្រូវធ្វើឡើងនៅការិយាល័យទទួលពាក្យបណ្តឹងនៃសាលាដំបូងរាជធានី-ខេត្ត។ ភាគីដែលមានសិទ្ធិធ្វើបណ្តឹងរដ្ឋប្បវេណីរួមមាន ភាគីដែលមានប្រយោជន៍មានសិទ្ធិឬទ្រព្យសម្បត្តិរបស់ខ្លួនដែលត្រូវធ្វើឱ្យខូចខាតឬរំខានដោយភាគីមួយទៀត ម្ចាស់ទ្រព្យសម្បត្តិ អ្នកទទួលមរតក ឬម្ចាស់បំណុលជាដើម និងជនដែលមានសមត្ថភាពឬគ្មានសមត្ថភាព ត្រូវមានតំណាងដោយមានលិខិតសិទ្ធិប្រទាន ដូចមេធាវី ជាដើម។

## ៣.២ ដំណាក់កាលផ្សះផ្សា

នៅក្នុងបណ្តឹងរដ្ឋប្បវេណីមានដំណាក់កាលផ្សះផ្សាដែលនៅក្នុងដំណាក់កាលផ្សះផ្សារនេះមានតែចៅក្រមម្នាក់និងក្រឡាបញ្ជីម្នាក់ដែលជាអ្នកកត់ត្រាប៉ុណ្ណោះ ។ ចៅក្រម ព្យាយាមប្រើនិតិវិធីនិយាយឲ្យគូភាគីទាំងសងខាងត្រូវរ៉ូវគ្នាវិញ ក្នុងគោលបំណងឲ្យមានសាមគ្គីភាព និង ការយោគយល់គ្នាទៅវិញទៅមក ដើម្បីឈានទៅរកការដកពាក្យបណ្តឹងទៅវិញ ។ ក្នុងការផ្សះផ្សានេះចៅក្រមពុំចាំបាច់មានភស្តុតាង ឬ សាក្សីអ្វីឡើយ ។

ដំណាក់កាលផ្សះផ្សា ភាគច្រើនត្រូវយកមកអនុវត្តនៅពេលចៅក្រមកោះហៅភាគីមកចូលរួមក្នុងនីតិវិធីត្រៀមទាញហេតុផលផ្ទាល់មាត់លើកទី១។ ប្រសិនបើការផ្សះផ្សាមិនជោគជ័យទេ ចៅក្រមអាចបញ្ឈប់ ឬធ្វើម្តងទៀតជាមួយភាគីបណ្តឹងនៅដំណាក់កាលនីតិវិធីត្រៀមទាញហេតុផលផ្ទាល់មាត់លើកទី២ ។

## ៣.៣ នីតិវិធីត្រៀមទាញហេតុផលផ្ទាល់មាត់

**នីតិវិធីត្រៀមទាញហេតុផលផ្ទាល់មាត់:** គឺជានីតិវិធីនៃការជម្រះក្តីដែលផ្អែកលើគោលការណ៍នៃការជម្រះក្តីដោយផ្ទាល់មាត់។ គោលការណ៍ជម្រះក្តីដោយផ្ទាល់មាត់ គឺជាគោលការណ៍ជំនុំជម្រះលើបណ្តឹងតាមការធ្វើសេចក្តីថ្លែងការណ៍ របស់ភាគី និងពិនិត្យភស្តុតាង ដែលធ្វើឡើងដោយសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ និងការស្តាប់សេចក្តីថ្លែងការណ៍នោះក្នុងសាលសវនាការសាធារណៈ។

ភាពចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់គឺ នៅក្នុងករណីដែលតម្រូវតុលាការអាចយកធ្វើជាមូលដ្ឋាននៃការចេញសាលក្រមបាន តែអ្វីដែលបានបង្ហាញ ឬ លទ្ធផលនៃការពិនិត្យភស្តុតាងដែលធ្វើឡើងនៅពេលទាញហេតុផលប៉ុណ្ណោះ។ ប៉ុន្តែចំពោះបញ្ហាដែលត្រូវសម្រេចដោយដីកាសម្រេច តុលាការ សម្រេចដោយឆន្ទានុសិទ្ធិថាតើគួរធ្វើការជម្រះដោយការទាញហេតុផលផ្ទាល់មាត់ឬទេ។ ដោយសារតែជាបញ្ហាបន្ទាប់បន្សំ ដែលមិនកមកធ្ងន់ធ្ងរដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីឬជាបញ្ហាដែលត្រូវលើកមកដោយការទាញហេតុផលផ្ទាល់មាត់ ឬជាបញ្ហាដែលត្រូវជម្រះឲ្យបានឆាប់រហ័ស។ នីតិវិធីត្រៀមទាញហេតុផលផ្ទាល់មាត់ ធ្វើឡើងដើម្បីធានាឲ្យបាននូវការជម្រះក្តីដោយការទាញហេតុផលផ្ទាល់មាត់មួយដែលជាទីពេញចិត្ត និងដើម្បីទទួលបានសាលក្រមមួយដែលឆ្លើយតបទៅនឹងការពិត។

ចំពោះឯកសារដែលត្រូវត្រៀមមានដូចជា ឯកសារដែលភាគីនីមួយៗជូនដំណឹងជាមុនទៅតុលាការ និងភាគីម្ខាងទៀតអំពីចំណុចដែលខ្លួនមិនសុខចិត្ត និងបានធ្វើសេចក្តីថ្លែងការណ៍នៅកាលបរិច្ឆេទបន្ទាប់។ ការបញ្ជូនឯកសារភស្តុតាងនេះ មានគោលបំណងធ្វើឲ្យតុលាការ និងភាគីទាំងសងខាង អាចសម្រេចបាននូវការជម្រះក្តីមួយប្រកបដោយប្រសិទ្ធិភាពនៅកាលបរិច្ឆេទដែលកំណត់។ ក្នុងឯកសារនោះផងដែរ អ្វីដែលត្រូវសរសេរមានដូចជា មធ្យោបាយតទល់ ឬការពារខ្លួន និងសេចក្តីថ្លែងការណ៍ ចំពោះមធ្យោបាយតទល់ ឬការពារខ្លួនរបស់ភាគីម្ខាងទៀតដែលលិខិតនោះភាគច្រើនត្រូវមាន មេធាវី តំណាងក្នុងការពិនិត្យ និងស្នើសុំ ព្រមទាំងមានវត្តមានក្នុងនីតិវិធីត្រៀមទៀតផង។ កាលបរិច្ឆេទនៃនីតិវិធីត្រៀមទាញហេតុផលផ្ទាល់មាត់ ត្រូវបានធ្វើដោយចៅក្រម និងក្រឡាបញ្ជីយ៉ាងយូរ ៣០ថ្ងៃ ក្រោយពីបណ្តឹងនោះបានដាក់ ក្រោយពីពេលដំណើរការនីតិវិធីនេះ ក្រឡាបញ្ជី ធ្វើកំណត់ហេតុមួយហៅថា កំណត់ហេតុនៃនីតិវិធីទាញហេតុផលផ្ទាល់មាត់ ដោយរាយរ៉ាប់ពីចម្លើយរបស់ភាគី និងការទាមទាររបស់ភាគីដើមបណ្តឹងជាដើម។ នៅពេលកំណត់ហេតុនេះត្រូវបានធ្វើ ភាគីអាចដាក់សេចក្តីថ្លែងការណ៍តបវិញបាន ពិសេសគឺភាគីខាងចុងចម្លើយ ដែលអាចដាក់ការថ្លែងការណ៍តបមកវិញ ដើម្បីមោឃភាពការទាមទាររបស់ដើមចោទ ឬស្នើសុំបន្ថែមភស្តុតាងជាដើម។ នៅក្នុងនីតិវិធីត្រៀមទាញហេតុផលផ្ទាល់មាត់ មេធាវីរបស់ភាគីអាចដាក់ភស្តុតាងបន្ថែមលើករណីរបស់ខ្លួនបាន ក្នុងរយៈពេលកំណត់។

## ៣.៤ ការទាញហេតុផលផ្ទាល់មាត់ និងការបញ្ចប់នីតិវិធីទាញហេតុផលផ្ទាល់មាត់

**<u>ការទាញហេតុផលផ្ទាល់មាត់:</u>** ការទាញហេតុផលផ្ទាល់មាត់ គឺជាទម្រង់នៃការជម្រះក្តី ដែលក្នុងនោះសកម្មភាពរបស់តុលាការ និង សកម្មភាពរបស់ភាគី ចំពោះការជម្រះក្តីនោះ ត្រូវធ្វើឡើងតាមរយៈការធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ និង ការស្តាប់សេចក្តីថ្លែងការណ៍នោះនៅសាលសវនាការដែលបើកចំហជាសាធារណៈនៅកាលបរិច្ឆេទដែលភាគីអាចមានវត្តមាន។ គោលបំណងនៃការបង្កើតប្រព័ន្ធនេះគឺ ដើម្បីលុបបំបាត់នូវការជម្រះក្តី

សម្ងាត់ ដែលពុំមានយុត្តិធម៌ ធានានូវគោលការណ៍ចំពោះមុខ និងផ្តល់ឱកាសឲ្យភាគីទាំងសងខាង អាចធ្វើសេចក្តីថ្លែងការណ៍អំពីការអះអាងរបស់ពួកគេដោយយុត្តិធម៌ ស្មើភាព និងផ្តល់ឱកាសឲ្យភាគីអាចតវ៉ាចំពោះការអះអាងរបស់ភាគីម្ខាងទៀត។ អ្វីដែលសំខាន់នោះគឺធានាឲ្យបានថា តុលាការ ដែលចេញសាលក្រមពិតជាបានស្តាប់ការអះអាងរបស់ភាគីដោយផ្ទាល់ ដើម្បីសម្រួលដល់ការស្វែងរកការពិត។

នៅក្នុងការជម្រះក្តីក្នុងការទាញហេតុផល ជាបឋម ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀម ដោយបញ្ជាក់ឲ្យបានច្បាស់ពីអង្គហេតុដែលជាចំណុចវិវាទ។ បន្ទាប់មក ភាគីអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួនថ្មីដែលត្រូវដាក់ក្នុងពេលសមរម្យ បើមិនដូច្នោះ ត្រូវលើកចោលៈ

- ពាក់ព័ន្ធទៅនឹងបញ្ហាដែលតុលាការត្រូវធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ
- មិនធ្វើឲ្យមានភាពយឺតយ៉ាវខ្លាំងដល់នីតិវិធី ដូចជាឯកសារដែលភាគីដាក់តាមខ្លួន ឬសាក្សីដែលនាំមកតុលាការ
- ភាគីបានធ្វើសេចក្តីបញ្ជាក់ដំបូងថា ការមិនអាចដាក់ភស្តុតាងនៅមុខការបញ្ចប់នីតិវិធីត្រៀមមិនមែនកើតចេញពីកំហុសធ្ងន់ធ្ងរ។
- ក្នុងការទាញហេតុផលផ្ទាល់មាត់ គឺមានភាពតែមួយ ដោយពុំមានការបែងចែកជា ដំណាក់កាលពិសេសទេ និងការកំណត់អំពីដំណាក់កាលទៅតាមប្រភេទនៃមធ្យោបាយតទល់ ឬ ការពារខ្លួនដែរ។ ចំណោកឯការពុះបំបែក ជាដំណាក់កាលៗ ទៅតាមកាលបរិច្ឆេទនៃនីតិវិធីដែរ តែត្រូវបានចាត់ទុកថាជាការទាញហេតុផលដោយផ្ទាល់មាត់ទាំងមូលតែម្តង។

នៅដំណាក់កាលបន្ទាប់ គឺការបំបែក និងការបញ្ចូលរឿងក្តី អាចធ្វើដោយដីកាសម្រេចបាន។ ករណីបញ្ចូលរឿងក្តីដែលមានភាគីខុសគ្នា តុលាការត្រូវសាកសួរសាក្សីនោះដាក់កំហិត។

**<u>ការបញ្ចប់ការទាញហេតុផលៈ</u>** បន្ទាប់ពីពិនិត្យភស្តុតាងហើយ តុលាការ ត្រូវមានតួនាទីចេញសាលក្រមទៅលើភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវ ចំពោះការទាមទាររបស់ដើមចោទ។ តុលាការ អាចអនុញ្ញាតឲ្យភាគីលើកនូវមតិចុងក្រោយរបស់ខ្លួន ពាក់ព័ន្ធនឹងភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការទាមទាររបស់ដើមចោទបាន។ បើយល់ថាចាំបាច់ តុលាការ អាចបើកឲ្យមានការទាញហេតុផលសាជាថ្មី នៅមុនពេលចេញសាលក្រមចុងក្រោយ។ តែបើក្រោយពិនិត្យភស្តុតាង តុលាការ យល់ថាអង្គសំខាន់មួយបានកើតឡើង ហើយមិនត្រូវបានបញ្ចេញតុលាការអាចធ្វើនីតិវិធីត្រៀមម្តងទៀតបាន។

## ផ្នែកទី៣៖ សវនាការ ការជំនុំជម្រះ និងការចេញសេចក្ដីសម្រេច

នៅដំណាក់កាលជំនុំជម្រះ មន្ត្រីនគរបាលយុត្តិធម៌មានតួនាទីក្នុងការសម្រួលដល់នីតិវិធីតុលាការ ដូចជា៖ ការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ការអមជនជាប់ចោទនៅក្នុងនីតិវិធីចូលបង្ហាញខ្លួនភ្លាម ការរក្សាទុកជនជាប់ចោទមុនចូលបង្ហាញខ្លួននៅមុខតុលាការ ការនាំខ្លួនជនជាប់ចោទទៅបង្ហាញខ្លួនតាមរយៈដីកាបញ្ជូន ឬសាលដីកាបញ្ជូន ការបង្ខំសាក្សីឲ្យចូលបង្ហាញខ្លួន ការធ្វើជាសាក្សីរបស់មន្ត្រីនគរបាលយុត្តិធម៌នៅមុខសវនាការ ការធានាសណ្ដាប់ធ្នាប់នៃសវនាការ ការជូនដំណឹងអំពីដីកាសម្រេចរបស់តុលាការ ការទទួល និងបញ្ជូនពាក្យបណ្ដឹងទាស់ចំពោះសាលក្រម ឬសាលដីកាកំបាំងមុខ។

### ១. តួអង្គនៃសវនាការ

តួអង្គសំខាន់ៗក្នុងសវនាការ ជំនុំជម្រះរួមមាន ចៅក្រមជំនុំជម្រះ ព្រះរាជអាជ្ញា ក្រឡាបញ្ជី មេធាវី គូភាគីនៃបណ្ដឹង និង សាក្សី ដែលជាតួអង្គសំខាន់សម្រាប់ឲ្យដំណើរការនីតិវិធីព្រហ្មទណ្ឌតាំងពីដំណាក់កាលស៊ើបអង្កេត រហូតដល់ដំណាក់កាលជំនុំជម្រះ អាចប្រព្រឹត្តទៅបានរលូនក្នុងការស្វែងរកយុត្តិធម៌ និងការពិត។

### ១.១ ចៅក្រមជំនុំជម្រះ

ចៅក្រមជំនុំជម្រះ មានភារកិច្ចចម្បងក្នុងការដឹកនាំនីតិវិធីសវនាការ និងការសម្រេចសេចក្ដីលើជនជាប់ចោទ បន្ទាប់ពីខ្លួនទទួលបានបណ្ដឹងតាមរយៈដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ដីកាបញ្ជូនទៅតុលាការជំនុំជម្រះដោយផ្ទាល់របស់ព្រះរាជអាជ្ញា ឬ កំណត់ហេតុស្ដីពីការចូលបង្ហាញខ្លួនភ្លាមដែលធ្វើដោយព្រះរាជអាជ្ញា។

### ១.២ ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា ជាអ្នកដឹកនាំ និង សម្របសម្រួលដល់នគរបាលយុត្តិធម៌។ ព្រះរាជអាជ្ញាមានតួនាទីចំនួន ០៤ (បួន) គឺ ការចោទប្រកាន់ ការធ្វើសេចក្ដីសន្និដ្ឋានឲ្យតុលាការ ការធានារ៉ាបរងការអនុវត្ត និងការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន។ នៅពេលដែលតួនាទីទាំង៤ ត្រូវបានអនុវត្តជនជាប់ចោទដែលពាក់ព័ន្ធនឹងសំណុំរឿងនោះនឹងត្រូវបានយកមកពិនិត្យដោយចៅក្រមជំនុំជម្រះ។

នៅក្នុងអង្គសវនាការព្រហ្មទណ្ឌ ព្រះរាជអាជ្ញា ពុំអាចអវត្តមានបានឡើយ ព្រះរាជអាជ្ញា គឺជាអ្នកធ្វើការសន្និដ្ឋានបើក-បិទ សាកសួរជនជាប់ចោទ និងជាអ្នកស្នើសុំឱ្យតុលាការដែលមានចៅក្រមជំនុំជម្រះ ធ្វើការពិចារណាលើសកម្មភាពដែលបានជនជាប់ចោទបានប្រព្រឹត្តទៅតាមបទប្បញ្ញត្តិនៃនីតិវិធីព្រហ្មទណ្ឌ និង ច្បាប់ជាធរមាន។ ព្រះរាជអាជ្ញា មានសិទ្ធិក្នុងការធ្វើសេចក្ដីសន្និដ្ឋានរបស់ខ្លួនទៅចៅក្រមជំនុំជម្រះ ក្នុងករណីព្រះរាជអាជ្ញា មិនពេញចិត្តនឹងការសម្រេចរបស់ចៅក្រមប្រឹក្សា ព្រះរាជអាជ្ញា មានសិទ្ធិប្ដឹងឧទ្ធរណ៍បាន។

ព្រះរាជអាជ្ញា ជាម្ចាស់នៃបណ្តឹងអាជ្ញា ដូចនេះ ព្រះរាជអាជ្ញា ពុំតម្រូវឱ្យមានវត្តមាននៅក្នុងសវនាការរឿងរដ្ឋប្បវេណីឡើយ។

## ១.៣ ក្រឡាបញ្ជី

ក្រឡាបញ្ជី ជាមន្ត្រីរាជការក្របខណ្ឌក្រសួងយុត្តិធម៌ ដែលមានតួនាទីជាជំនួយរបស់ព្រះរាជអាជ្ញា និងចៅក្រមនៅគ្រប់ដំណាក់កាល។ ក្រឡាបញ្ជី ពុំអាចអវត្តមាននៅគ្រប់ដំណាក់កាលទាំងអស់ ពោលគឺចាប់ផ្តើមពីដំណាក់កាលអយ្យការ ដល់ដំណាក់កាលជំនុំជម្រះ។ ការងាររបស់ក្រឡាបញ្ជីទៅតាមដំណាក់កាល មានដូចជា៖

- **ដំណាក់កាលអយ្យការ៖** ក្រឡាបញ្ជី ជាអ្នកធ្វើកត់ត្រារាល់ព័ត៌មានតាមរយៈការសួរ ឬស្តាប់ចម្លើយរបស់ជនជាប់សង្ស័យ ឬជនល្មើស ឬដើមបណ្តឹង ឬសាក្សី ក្នុងកំណត់ហេតុដែលមានការដឹកនាំធ្វើកំណត់ហេតុដោយព្រះរាជអាជ្ញា។ ទម្រង់កំណត់ហេតុសម្រាប់ទិដ្ឋភាពនៃការអនុវត្ត គឺមានការចុះហត្ថលេខារបស់ក្រឡាបញ្ជីអមតំណាងអយ្យការ។
- **ដំណាក់កាលចៅក្រមស៊ើប៖** ក្រឡាបញ្ជី ជាអ្នកអមចៅក្រមស៊ើបសួរជានិច្ច ដើម្បីជួយសម្រួលការងាររបស់ចៅក្រមស៊ើបសួរ ប៉ុន្តែក្នុងករណីណាក៏ដោយ ក្រឡាបញ្ជី មិនអាចបំពេញកិច្ចដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរបានទេ។ ក្រឡាបញ្ជី ជាអ្នករក្សាទុកសំណុំរឿងស៊ើបសួរដែលចៅក្រមស៊ើបសួររបស់ខ្លួនធ្វើចំណាត់ការ។ កាលណាសំណុំរឿងបាត់ ក្រឡាបញ្ជីជាអ្នកទទួលខុសត្រូវដោយអាចប្រឈមនឹងវិន័យរដ្ឋបាលពីក្រសួងយុត្តិធម៌។ ក្រឡាបញ្ជី ជាអ្នកបញ្ជាក់ភាពត្រឹមត្រូវលើលិខិតចម្លងដោយដាក់ថា «ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម» ដើម្បីជាប្រយោជន៍សម្រាប់សំណុំរឿងបង្ការទុក ឬដើម្បីប្រើប្រាស់នៅពេលបាត់លិខិតច្បាប់ដើម។ គ្រប់លិខិតនៃសំណុំរឿង ត្រូវតែបង់លេខដោយក្រឡាបញ្ជីតាមលំដាប់នៃកាលប្បវត្តិ។ សំណុំរឿង និងសំណុំលិខិតដែលបង្ការទុកត្រូវតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៅមន្ទីរចៅក្រមស៊ើបសួរ ឬ នៅក្នុងបន្ទប់ណាមួយនៃតុលាការដែលមានលក្ខខណ្ឌសន្តិសុខគ្រប់គ្រាន់។ ក្រឡាបញ្ជី ក៏ជាអ្នកថតចម្លងសំណុំរឿងឲ្យទៅមេធាវីបន្ទាប់ពីមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ដោយមេធាវីជាអ្នកបង់សោហ៊ុយថតចម្លង។
- **ដំណាក់កាលជំនុំជម្រះ** ក្រឡាបញ្ជី ជាអ្នកកត់ត្រានូវកំណត់ហេតុសវនាការចាប់តាំងពីពេលមុនសវនាការ រហូតដល់បញ្ចប់។ ក្រឡាបញ្ជី ត្រូវពិនិត្យមើលអំពីវត្តមានរបស់ភាគីពាក់ព័ន្ធនៅពេលមុនសវនាការ អានកំណត់ហេតុនានា ដើម្បីឲ្យអ្នកចូលរួមសវនាការបានដឹងអង្គហេតុ និងកត់ត្រារាល់សំនួរ-ចម្លើយនាពេលសវនាការរហូតដល់បញ្ចប់។

នៅក្នុងរឿងរដ្ឋប្បវេណី ក្រឡាបញ្ជី ទទួលបន្ទុកក្នុងការធ្វើកំណត់ហេតុ នៅគ្រប់ដំណាក់កាល ពិសេសគឺនៅដំណាក់កាលត្រៀមទាញហេតុផលផ្ទាល់មាត់ និងនីតិវិធីទាញហេតុផលផ្ទាល់មាត់។

## ១.៤ មេធាវី

មេធាវី ជាអ្នកវិជ្ជាជីវៈឯករាជ្យ និងសេរី ដែលចូលរួមបម្រើវិស័យយុត្តិធម៌ តាមរយៈបទបញ្ញត្តិច្បាប់ជាធរមាន។ ក្នុងករណីដែលមេធាវីជាអ្នកការពារសិទ្ធិឲ្យជនល្មើស មេធាវីមានតួនាទីចូលរួមពិនិត្យមើលអំពីការទទួលស្គាល់ និង ប្រើប្រាស់សិទ្ធិសម្រាប់ជនល្មើសពីសំណាក់អាជ្ញាធរសមត្ថកិច្ចតាមដំណាក់កាលនីតិវិធី។ មេធាវីមានសិទ្ធិដឹងរាល់ការសម្រេចរបស់ចៅក្រមស៊ើបសួរលើជនត្រូវចោទតាមរយៈការជូនដំណឹង។ រីឯដំណាក់កាល

ជំនុំជម្រះ មេធាវីមានភារកិច្ចការពារសិទ្ធិឲ្យជនជាប់ចោទ សម្រាប់ការពិនិត្យមើលអំពីការដឹងនាំនីតិវិធីសវនាការរបចៅក្រមជំនុំជម្រះ និងធ្វើការតវ៉ាភ្លាមៗសម្រាប់ការដឹកនាំមិនត្រឹមត្រូវតាមច្បាប់កំណត់។

មេធាវី ជាអ្នកបំពេញកាតព្វកិច្ចមធ្យោបាយតាមផ្លូវច្បាប់ឲ្យកូនក្តីរបស់ខ្លួនដើម្បីប្រើប្រាស់សិទ្ធិដែលច្បាប់បានប្រគល់ជូនភាគីនៃបណ្តឹងជាអតិបរមាដែលអាចធ្វើទៅបាន។ ដូច្នេះ មេធាវី មានភារកិច្ចធ្វើយ៉ាងណាឲ្យកូនក្តីរបស់ខ្លួនទទួលបានសិទ្ធិជំនុំជម្រះក្តីដោយយុត្តិធម៌។

នៅក្នុងសំណុំរឿងរដ្ឋប្បវេណី មេធាវី មានតួនាទីចំបងក្នុងការតំណាងដោយអាណត្តិសម្រាប់កូនក្តីខ្លួន មេធាវី ត្រូវតាមដានរាល់នីតិវិធីដែលបានអនុវត្តដើម្បីស្វែងរកវិធីដោះស្រាយ និងតទល់ជាមួយភាគីម្ខាងទៀត។

## ១.៥ គូភាគីនៃបណ្តឹង

នៅក្នុងបណ្តឹងអាជ្ញា ភាគីនៃបណ្តឹងគឺអយ្យការ និងជនជាប់ចោទ ឬ ជនត្រូវចោទ។ នៅក្នុងបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណី ចំណែកឯភាគីម្ខាងទៀតជាជនជាប់ចោទ ឬ សន្តតិជនរបស់ជនជាប់ចោទ ឬក៏អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។

## ១.៦ សាក្សី

សាក្សី ជាបុគ្គលដែលស្ថិតនៅក្រៅអង្គហេតុដែលជាកម្មវត្ថុនៃការចោទប្រកាន់ និង មានតួនាទីក្នុងការផ្តល់ពត៌មានដែលជាប្រយោជន៍ដល់ការបង្ហាញការពិតនៅគ្រប់ដំណាក់កាលនីតិវិធី។ នៅដំណាក់កាលស៊ើបអង្កេត សាក្សី ត្រូវចូលខ្លួនមកបំភ្លឺតាមការកោះហៅរបស់មន្ត្រីនគរបាលយុត្តិធម៌ ឬព្រះរាជអាជ្ញា។ ប៉ុន្តែប្រសិន បើសាក្សីមិនព្រមចូលខ្លួនតាមការកោះហៅដែលមន្ត្រីនគរបាលយុត្តិធម៌យល់ឃើញថាជននោះមានវត្តមាន នៅទីកន្លែងកើតហេតុនោះ មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការនាំខ្លួនជននោះដើម្បីធ្វើការសាកសួរបាន។ នៅក្នុងដំណាក់កាលស៊ើបសួរ សាក្សី ត្រូវធ្វើសម្បថតាមប្រពៃណី និងជំនឿស្របតាមសាសនារបស់ជននោះ មុននឹងចៅក្រមស៊ើបសួរស្តាប់ចម្លើយសាក្សី។ ប្រសិនបើសាក្សីបដិសេធមិនបង្ហាញខ្លួនតាមការកោះហៅទេ ចៅក្រមស៊ើបសួរនឹងសុំឲ្យកងកម្លាំងសាធារណៈបង្ខំសាក្សីឲ្យចូលមកបង្ហាញខ្លួនដោយចេញបញ្ជាឲ្យចូលបង្ហាញខ្លួន។ នៅក្នុងដំណាក់កាលសវនាការ សាក្សីមានភារកិច្ចដូចគ្នានៅដំណាក់កាលស៊ើបសួរដែរ គឺត្រូវចូលបង្ហាញខ្លួននៅសវនាការ ដើម្បីបំភ្លឺអង្គហេតុតទល់នៅចំពោះមុខភាគីនៃសំណុំរឿងក្នុងការបង្ហាញការពិតដែលខ្លួនបានដឹង។

## ២. ការជំនុំជម្រះ ឬវិនិច្ឆ័យអង្គសេចក្តី

ដំណាក់កាលជំនុំជម្រះ ជាដំណាក់កាលដ៏សំខាន់មួយ បន្ទាប់ពីដំណាក់កាលស៊ើបសួរកន្លងបានបញ្ចប់ទៅ។ នៅក្នុងការជំនុំជម្រះ តុលាការមានសមត្ថកិច្ចក្នុងការជំនុំជម្រះក្នុងរឿងក្តីព្រហ្មទណ្ឌគឺ៖ តុលាការនៃទីកន្លែងបទល្មើស តុលាការនាលំនៅដ្ឋានរបស់ជនជាប់ចោទ ឬតុលាការនាទីកន្លែងចាប់ខ្លួនជនជាប់ចោទ។ ក្នុងករណី

ជនជាប់ចោទ ឬតុលាការពីរ ឬច្រើនស្ថិតក្នុងមណ្ឌលនៃសាលាឧទ្ធរណ៍តែមួយបានទទួលពាក្យប្ដឹងលើរឿងក្ដីតែមួយដូចគ្នា ប្រធានសាលាឧទ្ធរណ៍ ចាត់តាំងតុលាការដែលនឹងត្រូវទទួលបន្ទុកលើសំណុំរឿង។ វិវាទសមត្ថកិច្ចដែនដីរវាងតុលាការច្រើនដែលមានថ្នាក់ស្មើគ្នា ត្រូវសម្រេចដោយប្រធានតុលាការជាន់ខ្ពស់។

នៅក្នុងការជំនុំជម្រះបទល្មើសព្រហ្មទណ្ឌ សាលាដំបូងសម្រេចជាក្រុមសមូហភាព ដែលមានចៅក្រមបីរូបចំពោះបទឧក្រិដ្ឋ ព្រមទាំងបទមជ្ឈឹម និងបទលហុដែលជាប់ទាក់ទង។ ប៉ុន្តែបើជាការជំនុំជម្រះបទល្មើសមជ្ឈិម និងបទលហុ សាលាដំបូង សម្រេចជាចៅក្រមទោល។[៣៤] តុលាការសម្រេចសេចក្ដីតែទៅលើអំពើទាំងឡាយណាដែលមានបង្ហាញនៅក្នុងសាលដីកាបញ្ជូន ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬកំណត់ហេតុនៃការបង្ហាញខ្លួនភ្លាម។

តុលាការ ពុំអាចសម្រេចសេចក្ដីទៅលើអង្គហេតុផ្សេងពីនេះបានឡើយ។ ប្រសិនបើចៅក្រមទោលយល់ថា អង្គហេតុដែលត្រូវបានប្ដឹងជាបទល្មើសឧក្រិដ្ឋ តុលាការត្រូវបង្វិលសំណុំរឿងជូនព្រះរាជអាជ្ញា ដើម្បីបើកការស៊ើបសួរ។ ប៉ុន្តែប្រសិនបើចៅក្រមជាមូហភាពយល់ឃើញថា អង្គហេតុដែលត្រូវបានប្ដឹងជាបទមជ្ឈឹម ឬលហុតុលាការនោះនៅតែមានសមត្ថកិច្ច ដើម្បីជម្រះសេចក្ដីដដែល។

- **នីតិវិធីមុនពេលជំនុំជម្រះ**

នីតិវិធីមុនពេលសវនាការជំនុំជម្រះ គឺប្រធានតុលាការជាអ្នកកំណត់កាលបរិច្ឆេទនៃសវនាការ លើកលែងតែករណីនៃនីតិវិធីចូលបង្ហាញខ្លួនភ្លាម។ ក្នុងការកំណត់កាលបរិច្ឆេទនេះ ប្រធានតុលាការត្រូវគោរព តាមរយៈពេលដែលមានចែងក្នុងមាត្រា៤៥៧ និងមាត្រា៤៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ តាមបញ្ញត្តិនៃមាត្រាខាងលើ និងថ្ងៃកំណត់ឲ្យចូលបង្ហាញខ្លួននៅមុខតុលាការត្រូវកំណត់ដូចតទៅៈ

- ១៥ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃតុលាការជាន់ដំបូង
- ២០ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងមួយផ្សេងទៀតនៃដែនដីជាតិ
- ២ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា
- ៣ខែ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងមួយផ្សេងទៀត។

ប៉ុន្តែក្នុងករណីជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី អ្នកជំនាញ អ្នកបកប្រែអ្នកទទួលខុសត្រូវរដ្ឋប្បវេណីធ្វើដោយព្រះរាជអាជ្ញា។[៣៥] ក្នុងករណីដែលតុលាការទទួលបណ្ដឹងដោយដីកាបញ្ជូន ឬសាលដីកាបញ្ជូន ត្រូវភ្ជាប់ជាមួយនឹងដីកាកោះហៅ ដើម្បីប្រគល់ឲ្យជនជាប់ចោទ។ ប្រសិនបើមានមេធាវី ព្រះរាជអាជ្ញាក៏ត្រូវធ្វើការកោះហៅមេធាវីផងដែរ។ មេធាវី អាចពិនិត្យមើលសំណុំរឿងនៅការិយាល័យក្រឡាបញ្ជីនៃតុលាការ នៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី។

- **នីតិវិធីនៃការសម្រេចមុនអង្គសេចក្ដី**

ក្រោយពីបានទទួលសំណុំរឿងដើម្បីជំនុំជម្រះដល់អង្គសេចក្ដី ក្រមនីតិវិធីព្រហ្មទណ្ឌ អនុញ្ញាតឲ្យជនជាប់ចោទ និង មេធាវីជនជាប់ចោទ អាចដាក់ពាក្យសុំឲ្យដោះលែងឲ្យនៅក្រៅឃុំបានតាមមាត្រា៣០៧។ ជនជាប់ចោទ អាចសុំដោយផ្ទាល់មាត់នាពេលសវនាការ ឬ ធ្វើតាមលិខិតជាលាយលក្ខណ៍អក្សរ។ បើពាក្យសុំត្រូវធ្វើដោយផ្ទាល់មាត់នាពេលសវនាការក្រឡាបញ្ជីនៃសវនាការត្រូវកត់ការស្នើសុំនោះទៅក្នុងកំណត់ហេតុ។ តុលាការត្រូវសម្រេចពីបញ្ហានេះក្រោយពីបានស្ដាប់ពីជនជាប់ចោទ មេធាវី និងព្រះរាជអាជ្ញា។ ការសម្រេចត្រូវធ្វើឡើងជាសាលក្រមក្នុងរយៈពេល ១០ថ្ងៃ ក្រោយពីការសុំដោយផ្ទាល់មាត់ឬ ក្រោយពីទទួលពាក្យសុំដែលធ្វើជាលាយលក្ខណ៍អក្សរ។ ការសម្រេចឱ្យនៅក្រៅឃុំដោយតុលាការ ត្រូវប្រព្រឹត្តទៅតាមមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌត្រង់ចំណុចមូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន នៅដំណាក់កាលចៅក្រមស៊ើបសួរ។

តុលាការ អាចចេញសាលក្រមបង្គាប់ឲ្យដោះលែងជនជាប់ចោទឲ្យមានសេរីភាពវិញបាន តែជនជាប់ចោទត្រូវរក្សាទុកនៅក្នុងពន្ធនាគារ រហូតដល់ផុតរយៈពេលសម្រាប់ប្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា លើកលែងតែព្រះរាជអាជ្ញាយល់ព្រមឲ្យដោះលែងភ្លាមជាលាយលក្ខណ៍អក្សរ។ រឿងឃុំខ្លួន រយៈពេលប្ដឹងឧទ្ធរណ៍មានចែងនៅមាត្រា ៣៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖

- ៤៨ម៉ោងសម្រាប់ព្រះរាជអាជ្ញា គិតពីថ្ងៃដែលតុលាការសម្រេចពីការឃុំខ្លួន
- ៤ថ្ងៃសម្រាប់ពិរុទ្ធជន គិតពីថ្ងៃដែលតុការសម្រេចពីការឃុំខ្លួន។

ប្រសិនបើពុំមានបណ្ដឹងសុំទេ តុលាការក៏អាចបង្គាប់ឲ្យដោះលែងជនជាប់ចោទឲ្យមានសេរីភាពវិញដែរ ដោយយោងតាមមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ នីតិវិធីនាពេលសវនាការ គឺពុំមានលក្ខណៈខុសគ្នាពីនីតិវិធីនៃសវនាការលើអង្គសេចក្ដីទេ។ នីតិវិធីនេះក៏ត្រូវបានយកមកអនុវត្តផងដែរ ក្នុងករណីដែលជនជាប់ចោទត្រូវបានចាប់ខ្លួនបានតាមដីកាបង្គាប់របស់ចៅក្រមស៊ើបសួរ ប៉ុន្តែសំណុំរឿងកំពុងតែស្ថិតក្រោមចំណាត់ការរបស់ចៅក្រមជំនុំជម្រះ។ ក្នុងករណីនេះ ចៅក្រមជំនុំជម្រះត្រូវសម្រេចអំពីការឃុំខ្លួនបណ្ដោះអាសន្ន ឬសម្រេចមិនឃុំខ្លួនជនជាប់ចោទតាមសាលក្រម។ ក្រមនីតិវិធីព្រហ្មទណ្ឌពុំបានបញ្ញត្តិពីបញ្ហានេះទេ ក៏ប៉ុន្តែដោយហេតុថាសំណុំរឿងព្រហ្មទណ្ឌស្ថិតក្នុងដំណាក់កាលជំនុំជម្រះ ចៅក្រមជំនុំជម្រះពុំអាចបញ្ជូនសំណុំរឿងឲ្យទៅចៅក្រមស៊ើបសួរវិញបានទេ ហើយសេចក្ដីសម្រេចរបស់ចៅក្រមជំនុំជម្រះ ក៏មិនអាចជាដីកាសម្រេចបានដែរ គឺមានតែសាលក្រមប៉ុណ្ណោះ។

- **នីតិវិធីនៃការបង្ហាញខ្លួន**

ក្នុងករណីនេះ សាលាដំបូង ទទួលបណ្តឹងតាមកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម។ ជនជាប់ចោទត្រូវឃុំគ្រងដោយការពាររហូតដល់ពេលចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការ។ ការបង្ហាញខ្លួននេះត្រូវប្រព្រឹត្តទៅនៅថ្ងៃនោះតែម្តង។

នៅពេលបង្ហាញខ្លួនតុលាការត្រូវធ្វើចំណាត់ការដូចជា៖

- ផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជនជាប់ចោទ
- ពិនិត្យមើលរបាយការណ៍សង្ខេបរឿងហេតុដែលបានចោទប្រកាន់
- ត្រូវប្រាប់ជនជាប់ចោទពី រយៈពេលដើម្បីសាមីខ្លួនរៀបចំការពារខ្លួន។ ប្រសិនបើជនជាប់ចោទសុំរយៈពេល ឬ ប្រសិនបើតុលាការយល់ឃើញថារឿងនោះមិនទាន់អាចជំនុំជម្រះនោះ ត្រូវលើកទៅសវនាការក្រោយទៀត។ ក្នុងករណីនេះ តុលាការអាចសម្រេចឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្នតាមសាលក្រមដែលមានសំអាងហេតុ និងចេញដីកាបង្គាប់ឲ្យឃុំខ្លួន។
- តុលាការត្រូវសម្រេចលើអង្គសេចក្តី និងប្រកាសសាលក្រមលើអង្គសេចក្តីក្នុងពេលមិនអាចលើសពី២សប្តាហ៍ គិតចាប់ពីថ្ងៃនៃការចូលទៅបង្ហាញខ្លួននៅមុខតុលាការ។ ការឃុំខ្លួនបណ្តោះអាសន្នត្រូវបញ្ចប់ដោយពេញលក្ខណៈច្បាប់ ក្រោយពីការផុតរយៈពេល ២សប្តាហ៍។
- ប្រសិនបើ តុលាការយល់ឃើញថា នីតិវិធីពុំត្រឹមត្រូវតាមលក្ខខណ្ឌនៃមាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីបើកការស៊ើបសួរ។ ក្នុងករណីនេះ ជនជាប់ចោទត្រូវតែនាំទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរនៅថ្ងៃនោះតែម្តង បើពុំនោះទេ ជនជាប់ចោទត្រូវតែដោះលែងឲ្យមានសេរីភាពឯកឯង។

នីតិវិធីនាពេលសវនាការផ្សេងទៀត និងសវនាការនៃរឿងអង្គសេចក្តី និងនីតិវិធីនៃការបង្ហាញខ្លួនភ្លាមនេះគឺមានលក្ខណៈមិនខុសពីគ្នាពីនីតិវិធីនៃសវនាការរឿងអង្គសេចក្តីធម្មតាទេ។

## ២.១ កិច្ចដែលត្រូវប្រព្រឹត្តក្នុងពេលសវនាការ

មុននឹងចាប់ផ្តើមសវនាការ ក្រឡាបញ្ជី ផ្ទៀងផ្ទាត់ពីវត្តមានរបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ដើម្បីរាយការណ៍ជូនតុលាការ។ នៅពេលសវនាការ សមាសភាពជំនុំជម្រះមាន ចៅក្រមម្នាក់ ឬបីនាក់ដែលសម្រេចជាសមូហភាពតំណាងដោយអយ្យការមួយរូប និងក្រឡាបញ្ជីសវនាការមួយរូប។

[៣៤] មាត្រា២៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[៣៥] មាត្រា២៨៤-២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

មុខងារជាចៅក្រម និងមុខងារជាព្រះរាជអាជ្ញាមានវិសមិតភាពនឹងគ្នាយ៉ាងដាច់ខាត ប្រសិនបើចៅក្រមណាម្នាក់ បានបំពេញមុខងារក្នុងឋានៈជាព្រះរាជអាជ្ញា ជាព្រះរាជអាជ្ញារង ឬ ជាចៅក្រមស៊ើបសួរលើសំណុំរឿងណាមួយ ហើយចៅក្រមនេះពុំអាចចូលរួមក្នុងការជំនុំជម្រះបានទេ។ បើពុំដូចច្នេះទេ សាលក្រមត្រូវទុកជាមោឃៈ។[៣៦] សវនាការត្រូវធ្វើឡើងជាសាធារណៈ លើកលែងតែតុលាការយល់ឃើញថាសាធារណៈភាពបង្កឲ្យមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ កិត្តិយសរបស់ភាគី ឬដល់ទំនៀមទម្លាប់ និងតាមរយៈការស្នើសុំរបស់ភាគី។ *ខ៣. សវនាការលើបទល្មើសរំលោភសេពសន្ថវៈ។*

ប្រសិនបើជនជាប់ចោទមិនអាចធ្វើការបង្ហាញខ្លួននាពេលសវនាការទេ តុលាការ ពិនិត្យទៅលើស្ថានភាពនៃរឿងក្តី ហើយអាចជ្រើសរើសសម្រេចតាមវិធីបីយ៉ាង៖

- ប្រសិនជាមូលហេតុដោយសារស្ថានភាពសុខភាព ឬដោយសារមូលហេតុធ្ងន់ធ្ងរ ប្រធានសវនាការអាចបង្គាប់ឲ្យសួរជនជាប់ចោទនៅទីកន្លែងដែលជននោះអាចនៅបានដោយកំណត់កាលបរិច្ឆេទនៃការសួរចម្លើយ។ ការសួរចម្លើយត្រូវធ្វើដោយប្រធានតុលាការ នៅចំពោះមុខព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមេធាវីរបស់ជនជាប់ចោទ លើកលែងតែជនជាប់ចោទបោះបង់ចោលយ៉ាងជាក់លាក់នូវមេធាវីខ្លួន។
- ប្រសិនបើជនជាប់ចោទពីបទឧក្រិដ្ឋ ឬបទមជ្ឈិម តុលាការអាចបង្គាប់ឲ្យបង្អង់រឿងក្តីនេះទុកសិន និងឲ្យចេញដីកាបង្គាប់ឲ្យនាំខ្លួន។
- បន្តនីតិវិធីទៅមុខទៀត ដោយចេញសាលក្រមកំបាំងមុខ ឬសាលក្រមកំបាំងមុខចាត់ទុកជាចំពោះមុខ។

ដំណើរការនាពេលសវនាការជំនុំជម្រះអាចប្រព្រឹត្ត ទៅដូចតទៅ៖

**១. <u>ការពិភាក្សាការដេញដោល</u>**

- ក្រឡាបញ្ជី ហៅឈ្មោះជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី អ្នកជំនាញ ព្រមទាំងផ្ទៀងផ្ទាត់អត្តសញ្ញាណ។ ក្រឡាបញ្ជី ត្រូវសរសេរកំណត់ហេតុសវនាការដោយរៀបរាប់ពីដំណើរការប្រព្រឹត្តទៅនៃសវនាការ និងសំណួរចម្លើយដល់ជនពាក់ព័ន្ធនៅក្នុងសវនាការ។ កំណត់ហេតុនេះត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងចុះទិដ្ឋាការក្រោយពីការផ្ទៀងផ្ទាត់ដោយប្រធានសវនាការក្នុងរយៈពេល១០ថ្ងៃ ក្រោយថ្ងៃប្រកាសសាលក្រម។
- ចំពោះប្រធានសវនាការត្រូវប្រាប់ដល់ជនជាប់ចោទឲ្យបានដឹងអំពីអំពើដែលគេចោទប្រកាន់លើខ្លួន។ ព្រមទាំង ធ្វើការសួរចម្លើយជនជាប់ចោទទាំងដាក់បន្ទុក និងដោះបន្ទុក។

- ចំពោះព្រះរាជអាជ្ញា មេធាវី និងភាគីអាចត្រូវបានអនុញ្ញាតឲ្យលើកសំណួរដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ក្រៅពីសំណួររបស់តំណាងអយ្យការ និងមេធាវី សំណួរផ្សេងទៀតតម្រូវឲ្យសួរតាមរយៈប្រធានសវនាការ។ ជាកិច្ចបន្ត តុលាការអាចធ្វើការស្តាប់ចម្លើយរបស់អ្នកប្តឹងបរិហារបានដែរ ដើម្បីយកពត៌មាន។
- ចំពោះសាក្សីមុន នឹងឆ្លើយសំណួរត្រូវតែស្បថស្របតាមសាសនា ឬ ជំនឿរបស់ខ្លួន។ ក្រោយពីប្រធានសវនាការ បានស្តាប់នូវចម្លើយរបស់សាក្សី ព្រះរាជអាជ្ញា មេធាវី និងភាគីអាចត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងការសួរសំណួរដល់សាក្សី។ ក្រៅពីនេះ ភាគីអាចសុំឲ្យតុលាការស្តាប់ចម្លើយ ក្នុងឋានៈជាសាក្សីនូវបុគ្គលដែលមានវត្តមាននៅក្នុងបន្ទប់ ប៉ុន្តែមិនបានមានការកោះហៅឲ្យត្រឹមត្រូវ។ ការស្តាប់ចម្លើយរបស់សាក្សីនេះត្រូវមានការយល់ព្រមពីប្រធានសវនាការទើបបាន។ ប្រសិនបើ ពុំបានចូលមកបង្ហាញខ្លួននៅមុខតុលាការតាមការកោះហៅ តុលាការអាចប្រើកម្លាំងសាធារណៈដើម្បីបង្ខំឲ្យសាក្សីឲ្យចូលបង្ហាញខ្លួន។
- ប្រសិនណាបើជនពាក់ព័ន្ធជាជនគថ្លង់ ក្រឡាបញ្ជី សរសេរសំណួរហើយឲ្យសាមីខ្លួនអាននិងឆ្លើយជាលាយលក្ខណ៍អក្សរ។ ករណីមិនចេះអាន ត្រូវរកអ្នកមកបកប្រែ ដោយត្រូវស្បថតាមសាសនា និងជំនឿរបស់ខ្លួនថាជួយតុលាការ និងបកប្រែចម្លើយដោយភាពស្មោះត្រង់។[៣៧] យ៉ាងណាមិញ អ្នកបកប្រែពុំអាចជ្រើសរើសក្នុងចំណោមចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ គូភាគី ឬសាក្សីទេ។
- រីឯជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចធ្វើជាសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ។

## ២. <u>សិទ្ធិនិយាយបន្តបន្ទាប់</u>

ប្រធានសវនាការ ប្រគល់សិទ្ធិឲ្យនិយាយជាបន្តបន្ទាប់ដល់ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនជាប់ចោទដើម្បីធ្វើការកត់សម្គាល់ខ្លីៗ។ មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីធ្វើសេចក្តីសន្និដ្ឋានការពារ។ ព្រះរាជអាជ្ញាដើម្បីធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ រួមទាំងមេធាវីរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី មេធាវីរបស់ជនជាប់ចោទ ដើម្បីធ្វើសេចក្តីសន្និដ្ឋានការពារ។ ការនិយាយនេះអាចត្រូវបានឆ្លើយតបដោយភាគីម្ខាងទៀត បានតែជនជាប់ចោទ និងមេធាវីត្រូវនិយាយក្រោយគេបង្អស់ជានិច្ច។ តុលាការ ថយខ្លួនចូលទៅក្នុងបន្ទប់ពិភាក្សាដើម្បីសម្រេច។ ចាប់ពីពេលនេះទៅគ្មានបណ្តឹងសុំណាមួយត្រូវដាក់ជូនតុលាការបានឡើយ។ ការថយខ្លួនទៅពិភាក្សារបស់ចៅក្រមប្រឹក្សាបត្រូវបានធ្វើឡើងដើម្បីឱ្យសមាជិកក្រុមប្រឹក្សាអាចជំនុំជម្រះគ្នាលើករណីសំណុំរឿងខាងលើបន្ទាប់ពីបានស្តាប់នូវការសន្និដ្ឋានរបស់ចៅក្រម និង មេធាវីគូភាគី ដើមបណ្តឹង និងចុងចោទព្រមទាំងសាក្សីផង។ សេចក្តីសម្រេចជាសាមូហភាពរបស់ក្រុមប្រឹក្សាជំនុំជម្រះ នឹងត្រូវកំណត់ជាសេចក្តីសម្រេចរបស់តុលាការដែលស្តែងចេញនៅពេលប្រកាស និងលើអត្ថបទនៃ **សាលក្រម** ឬ **សាលដីកា**។

## ២.១ ការប្រជុំសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ

ការជំនុំជម្រះរឿងក្តី ឬការសម្រេចសេចក្តីរបស់សាលាដំបូងរាជធានី-ខេត្ត អាចធ្វើឡើងដោយចៅក្រមទោល (ម្នាក់) ឬដោយក្រុមប្រឹក្សាជំនុំជម្រះ (ចៅក្រម បី រូប) ដោយមានក្រឡាបញ្ជីជាអ្នកកត់ត្រា ចូលរួមដោយតំណាងអយ្យការ និងមេធាវីតំណាង ឬការពារសិទ្ធិឲ្យភាគី ដោយអនុលោមតាមបទបញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី នីតិវិធីព្រហ្មទណ្ឌ ឬបទបញ្ញត្តិស្តីពីនីតិវិធីផ្សេងទៀត។

ចំពោះសាលាឧទ្ធរណ៍ ដែលជាសាលាជំនុំជម្រះទីពីរ ដែលមានកាតព្វកិច្ចជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ និងបណ្តឹងជំទាស់ពីសាលាជម្រះក្តីជាន់ទាប។ សាលាឧទ្ធរណ៍ធ្វើការជំនុំជម្រះ ដែលមានចៅក្រម០៣រូប រួមមានប្រធាន០១រូប និងសមាជិក០២រូប និងមានការចូលរួមដោយតំណាងមហាអយ្យការនិងមេធាវីតំណាង ឬការពារសិទ្ធិឲ្យភាគី ដោយអនុលោមតាមបទបញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី នីតិវិធីព្រហ្មទណ្ឌ ឬបទប្បញ្ញត្តិនានា ស្តីពីនីតិវិធីផ្សេងទៀត។

ដោយឡែកសម្រាប់រឿងក្តីដែលត្រូវបានតុលាការកំពូលសម្រេចបង្វិលមកវិញ នោះ សាលាឧទ្ធរណ៍ ត្រូវធ្វើការជំនុំជម្រះម្តងទៀត ដោយមានក្រុមប្រឹក្សាជំនុំជម្រះ ជាចៅក្រមចំនួន ៥រូប ហើយចៅក្រមចំនួន ៥រូប ហើយចៅក្រមចំនួន៤រូបទៀតសុទ្ធតែជាចៅក្រមដែលមិនបានចូលរួមជំនុំជម្រះកាលពីលើកមុន។ សាលាឧទ្ធរណ៍ ធ្វើការសម្រេចក្តីដោយពិនិត្យទៅលើទាំងអង្គហេតុ និងអង្គច្បាប់។ ឆ្លងកាត់នីតិវិធីជំនុំជម្រះ សាលាឧទ្ធរណ៍ ត្រូវចេញសេចក្តីសម្រេចចុងក្រោយរបស់ខ្លួនដែលហៅថា **សាលដីកា** ។

តុលាការកំពូល គឺជាសាលាជម្រះក្តីជាន់ខ្ពស់និងចុងក្រោយបង្អស់។ សេចក្តីសម្រេចរបស់តុលាការកំពូលគឺជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។ តុលាការកំពូល មានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងសាទុក្ខ ដែលមានចៅក្រមចំនួន ៥ រូប រួមមានប្រធាន ១ រូប និងចៅក្រមប្រឹក្សាចំនួន ៤ រូប ដោយពិនិត្យ និង សម្រេចទៅលើតែអង្គច្បាប់ប៉ុណ្ណោះ។ ក្នុងករណីមានបណ្តឹងសាទុក្ខលើកទី២ តុលាការកំពូលធ្វើការជំនុំជម្រះដោយមើលទៅលើ អង្គហេតុ និងអង្គច្បាប់ ដោយមានចៅក្រមចំនួន ០៩ រូប ក្នុងនោះមានប្រធាន ១ រូប និងចៅក្រមប្រឹក្សា ៨ រូប ដែលការជំនុំជម្រះនេះហៅថា សភាពេញអង្គ ឬ ការជំនុំជម្រះរួមក្រុម។ សេចក្តីសម្រេចចុងក្រោយរបស់តុលាការកំពូល ហៅថា **សាលដីកា** ដែលជាសេចក្តីសម្រេចបិទផ្លូវតវ៉ា និងមានលក្ខណៈស្ថាពរ។

## ៣. ការចេញសេចក្តីសម្រេច

## ៣.១ ការចេញសាលក្រមរបស់តុលាការជាន់ទាប

សិទ្ធិនៃការសម្រេចក្តី ដែលជាអំណាចរបស់តុលាការ ហើយត្រូវបានប្រគល់ឲ្យស្ថាប័នតុលាការដោយរដ្ឋធម្មនុញ្ញនិងកំពុងត្រូវបានដំណើរការនាពេលបច្ចុប្បន្នដោយតុលាការដែលមានស្រាប់ត្រូវបានទទួលស្គាល់និង

ត្រូវបានបញ្ញត្តិក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។ ដូចនេះ សិទ្ធិនៃការសម្រេចសេចក្ដីរបស់តុលាការ នៅតែមានអានុភាពគ្របដណ្ដប់លើបុគ្គលគ្រប់រូបដែលស្ថិតក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ទោះបីបុគ្គលនោះមានជាតិសាសន៍សញ្ជាតិអ្វីក៏ដោយ លើកលែងតែបុគ្គលមួយចំនួន ដែលតាមបទដ្ឋានអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជា បានចូលរួមធ្វើការលើកលែង មិនដាក់អោយស្ថិតនៅក្រោមអំណាចនៃការសម្រេចរបស់តុលាការកម្ពុជា។

ការសម្រេចសេចក្ដី ជាសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការ ដោយមូលហេតុនៃផលប្រយោជន៍សាធារណៈដែលកំណត់ដោយច្បាប់មានលក្ខណៈដាច់ខាត ក្នុងការអនុវត្តសិទ្ធិនៃការសម្រេចសេចក្ដី។ ជាគោលការណ៍ទូទៅ សមត្ថកិច្ចផ្ដាច់មុខ ជាសមត្ថកិច្ចតាមភារកិច្ច ដែលច្បាប់បានប្រគល់ឲ្យតុលាការណាមួយជាកំណត់ ដូចជាបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី[៣៨] ជាសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការក្នុងការដែលបានចេញសាលក្រម សាលដីកាដែលជាកម្មវត្ថុនៃការជំនុំជម្រះសារជាថ្មីជាសមត្ថកិច្ចនៃតុលាការពាក់ពន្ធ័នឹងការអនុវត្តដោយបង្ខំសមត្ថកិច្ចនៃតុលាការពាក់ព័ន្ធនឹងការចាត់ចែងរក្សាការពារជាអាទ៍។

សមត្ថកិច្ចតុលាការ នៃការអនុវត្តសិទ្ធិក្នុងការសម្រេចសេចក្ដី សិទ្ធិអំណាចទាំងនេះត្រូវបានប្រគល់ឲ្យទៅតុលាការគ្រប់ជាន់ថ្នាក់ ពោលគឺតុលាការកំពូល សាលាឧទ្ធរណ៍ និងសាលាដំបូង។ តុលាការកំពូល មានតែមួយគត់នៅទូទាំងប្រទេស ប៉ុន្តែសាលាឧទ្ធរណ៍ (**នាពេលអនាគត**) និងសាលាដំបូងអាចមានច្រើន ដូចនេះ ការកំណត់ថា តើតុលាការណាមួយដែលទទួលបន្ទុកអនុវត្តសិទ្ធិនៃការសម្រេចសេចក្ដី នោះជាការកំណត់អំពីសមត្ថកិច្ចរបស់តុលាការ។ ដូចនេះ តុលាការដែលមានសមត្ថកិច្ច គឺតុលាការដែលអាចទទួលដោយស្របច្បាប់នូវពាក្យបណ្ដឹងវិនិច្ឆ័យរឿងក្ដី ហើយចេញសាលក្រម ឬសាលដីកាបាន។

### ៣.២ ការជំទាស់ចំពោះសេចក្ដីសម្រេចរបស់តុលាការជាន់ទាប

តុលាការជំនាញនីមួយៗរបស់សាលាដំបូង ចេញសេចក្ដីសម្រេចរបស់ខ្លួនប្រកបដោយស្វ័យភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងនាមជាសាលាដំបូងដែលតុលាការជំនាញនោះស្ថិតនៅ។[៣៩]សេចក្ដីសម្រេចរបស់តុលាការជាន់ទាបត្រូវបានគេហៅថា **សាលក្រម** ។ សាលក្រម គឺជាសេចក្ដីសម្រេច ដែលតុលាការធ្វើលិខិតសាលក្រមដែលមានលក្ខណៈគ្រប់គ្រាន់ទៅតាមទម្រង់ដែលច្បាប់បានកំណត់ ហើយបង្កើតឱ្យមានអានុភាពដោយសារការប្រកាសដោយផ្អែកលើលិខិតសាលក្រមនេះ។ ការប្រកាសសាលក្រម ត្រូវធ្វើឡើងជាសាធារណៈ និងប្រកាសដោយចៅក្រមជម្រះនៃសំណុំរឿងនោះ ផ្នែកនៃសេចក្ដីសម្រេច ត្រូវអានដោយសំឡេងខ្លាំងៗ ដោយប្រធាននៃអង្គសវនាការ។[៤០]

[៣៦] មាត្រា២៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[៣៧] មាត្រា៣៣១នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

ចំពោះការប្រកាសអំពីពិរុទ្ធភាព តុលាការត្រូវពិនិត្យមើលៈ

- តើអំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ
- ជនជាប់ចោទបានប្រព្រឹត្តអំពើដែលចោទប្រកាន់លើខ្លួន ឬទេ?

ប្រសិនបើពិនិត្យឃើញថា មានពិរុទ្ធភាពលើជនជាប់ចោទ តុលាការប្រកាសផ្តន្ទាទោសតាមច្បាប់បញ្ញត្តិ។ ដោយឡែក ប្រសិនបើតុលាការ យល់ឃើញថា អំពើនោះមិនមែនជាបទល្មើសទេ ឬក៏ជនជាប់ចោទគ្មានកំហុសទេនោះ ជនជាប់ចោទត្រូវបានរួចខ្លួនពីបទចោទ។[៩១]

សាលក្រមត្រូវបានបែងចែកជា ៣ ប្រភេទៈ

- **សាលក្រមចំពោះមុខៈ** ប្រសិនបើជនជាប់ចោទចូលខ្លួននៅពេលសវនាការនោះ សាលក្រមជនសាលក្រមចំពោះមុខជនជាប់ចោទ។ សាលក្រមនៅតែជាសាលក្រមចំពោះមុខដដែល ទោះបីជាជនជាប់ចោទចាកចេញពីបន្ទប់សវនាការក៏ដោយ។ ប្រសិនបើជនជាប់ចោទ មិចអាចចូលខ្លួនបង្ហាញនៅចំពោះមុខតុលាការដោមូលហេតុស្ថានភាពសុខភាព ឬដោយមូលហេតុធ្ងន់ធ្ងរ ហើយតុលាការបានធ្វើការសួរសម្លើយជនជាប់ចោទនៅកន្លែងដែលជននោះនៅ សាលក្រមក៏ជាសាលក្រមចំពោះមុខជនជាប់ចោទដែរ។ សាលក្រមចំពោះមុខជនជាប់ចោទ មិនត្រូវឲ្យដំណឹងដល់ជននោះទេ។ ក្នុងករណីដែលសាលក្រមប្រកាសដោយមានវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ឬអ្នកតំណាងដោយត្រឹមត្រូវ សាលក្រមនេះជាសាលក្រមចំពោះមុខទេ។
- **សាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខៈ** ប្រសិនបើជនជាប់ចោទមិនចូលបង្ហាញខ្លួននៅពេលសវនាការទេ ប៉ុន្តែសាមីខ្លួនបានដឹងអំពីដីកាបញ្ជូនខ្លួនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងពីការកោះហៅហើយនោះសាលក្រមត្រូវចាត់ទុកថា ជាសាលក្រមចំពោះមុខជនជាប់ចោទ។ សាលក្រមនេះ ត្រូវឲ្យដំណឹងដល់ជនជាប់ចោទ។[៩២]
- **សាលក្រមកំបាំងមុខៈ** ប្រសិនបើជនជាប់ចោទ មិនចូលបង្ហាញខ្លួនពេលសវនាការទេហើយ ប្រសិនបើគ្មានភស្តុតាងបង្ហាញឲ្យឃើញថាសាមីខ្លួន បានដឹងពីការបញ្ជូនទៅជម្រះឬបានដឹងអំពីការកោះហៅនោះទេ សាលក្រម ត្រូវប្រកាសដោយកំបាំងមុខជនជាប់ចាទ។ សាលក្រមកំបាំងមុខត្រូវឲ្យដំណឹងដល់ជនជាប់ចោទ។ ក្នុងករណីដែលសាលក្រមប្រកាស ដោយពុំមានវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ឬអ្នកតំណាងដោយត្រឹមត្រូវ សាលក្រមនេះជាសាលក្រមកំបាំងមុខ។[៩៣]

## ៣.៣ ការចេញសេចក្ដីសម្រេចរបស់តុលាការជាន់ខ្ពស់

សាលក្រមព្រហ្មទណ្ឌ អាចត្រូវប្ដឹងទាស់ និង ប្ដឹងឧទ្ធរណ៍ដោយភាគីបាន។ ហេតុនេះក្រោយពីសាលក្រមត្រូវបានប្រកាស ភាគីនៅក្នុងរឿងក្ដីព្រហ្មទណ្ឌ អាចប្ដឹងទាស់បានក្នុងករណីដែលសាលក្រមនោះត្រូវបានសម្រេចដោយកំបាំងមុខខ្លួន។ បណ្ដឹងដែលភាគីអាចធ្វើទាស់នឹងសេចក្ដីសាលក្រមរបស់តុលាការជាន់ទាបមាន៖

- **បណ្ដឹងទាស់៖** ជនដែលអាចប្ដឹងទាស់បាន គឺពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី និង អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ បណ្ដឹងទាស់ ត្រូវធ្វើដោយពាក្យបណ្ដឹងជាលាយលក្ខណ៍អក្សរនៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម។ ក្នុងករណីប្ដឹងទាស់ដោយពិរុទ្ធជន ព្រះរាជអាជ្ញា អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬនៅចំពោះមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ដែលបានទទួលពាក្យបណ្ដឹងទាស់របស់ពិរុទ្ធជនបញ្ជូនបណ្ដឹងទាស់នោះទៅក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម។[៤៤]

បណ្ដឹងទាស់ត្រូវធ្វើក្នុងរយៈពេល ១៥ ថ្ងៃផ្ដើមគិតពីថ្ងៃឲ្យដំណឹងអំពីសាលក្រម បានប្រគល់ឲ្យសាមីខ្លួនដោយផ្ទាល់ដៃ ឬថ្ងៃដែលសាមីខ្លួនបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះមិនបានប្រគល់ឲ្យដល់សាមីខ្លួនដោយផ្ទាល់ដៃទេ។

- **បណ្ដឹងឧទ្ធរណ៍៖** ជនដែលអាចប្ដឹងឧទ្ធរណ៍បាន គឺ ព្រះរាជអាជ្ញានៃតុលាការជាន់ដំបូង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ បណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី និង អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម។

ព្រះរាជអាជ្ញានៃសាលាជាន់ដំបូង និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងរយៈពេល១ខែគិតចាប់ពីពេលប្រកាសសាលក្រម បើសាលក្រមនោះជាសាលក្រមចំពោះមុខ ឬគិតពីពេលទទួលជាសាលក្រមចាត់ទុកថាសាលក្រមដំណឹងចំពោះមុខ។[៤៥]

## ៣.៣ ការចេញសាលដីការបស់តុលាការជាន់ខ្ពស់

ចំពោះសាលាជម្រះក្ដីជាន់ខ្ពស់ ត្រូវបានបែងចែកជាពីរ គឺសាលាឧទ្ធរណ៍ និងតុលាការកំពូល។ សាលាឧទ្ធរណ៍ គឺជាសាលាជម្រះក្ដីថ្នាក់ទីពីរ ដែលជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ និងបណ្ដឹងជំទាស់លើសេចក្ដីសម្រេចរបស់តុលាការជាន់ទាប។ សាលាឧទ្ធរណ៍ធ្វើការសម្រេចសេចក្ដីដោយពិនិត្យមើលទាំងអង្គហេតុ និងអង្គច្បាប់។ ឆ្លងកាត់នីតិវិធីជំនុំជម្រះ សាលាឧទ្ធរណ៍ ត្រូវចេញសេចក្ដីសម្រេចចុងក្រោយរបស់ខ្លួន ដែលហៅថា **សាលដីកា**

[៣៨-៣៩] មាត្រា២៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី និងមាត្រា១៤ កថាខណ្ឌទី៣ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ

[៤០ -៤១] មាត្រា៥០ និងមាត្រា៣៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

ភាគីដែលមិនពេញចិត្តនឹងសេចក្ដីសម្រេចដែលមានក្នុងសាលដីការបស់សាលាឧទ្ធរណ៍ អាចប្ដឹងសាទុក្ខទៅតុលាការកំពូលតាមកំណត់ច្បាប់។ តុលាការកំពូល គឺជាសាលាជម្រះក្ដីជាន់ខ្ពស់ និងចុងក្រោយបង្អស់។ សេចក្ដីសម្រេចរបស់តុលាការកំពូល គឺជាសេចក្ដីសម្រេចបិទផ្លូវតវ៉ា។ តុលាការកំពូលមានតែមួយគត់ និងមានទីតាំងនៅរាជធានីភ្នំពេញ។ សមាសភាពតុលាការកំពូលរួមមាន ប្រធាន អនុប្រធាន ចៅក្រម ក្រឡាបញ្ជី មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ។ តុលាការកំពូលមានការបែងចែកជាសភាជំនាញ និងមានស្ថាប័នមហាអយ្យការនៅអមដូចសាលាឧទ្ធរណ៍ផងដែរ។ លាការកំពូលមានសមត្ថកិច្ចជំនុំជម្រះលើបណ្ដឹងសាទុក្ខដែលមានចៅក្រមចំនួន ៥រូប រួមមានប្រធាន ១ រូប និងចៅក្រមប្រឹក្សាចំនួន ៤ រូប ដោយពិនិត្យ និងសម្រេចទៅលើតែអង្គច្បាប់ប៉ុណ្ណោះ។ ក្នុងករណីមានបណ្ដឹងសាទុក្ខលើកទី២ តុលាការកំពូល ធ្វើការជំនុំជម្រះដោយពិនិត្យទាំងអង្គហេតុ និងអង្គច្បាប់ ដោយមានចៅក្រមចំនួន ៩ រូប ក្នុងនោះមានប្រធាន ១ រូប និងចៅក្រមប្រឹក្សា ៨ រូប ដែលការជំនុំជម្រះនេះហៅថា សភាពេញអង្គ ឬ ការជំនុំជម្រះរួមក្រុម។ សេចក្ដីសម្រេចចុងក្រោយរបស់ តុលាការកំពូលហៅថា "**សាលដីកា**" ដែលជាសេចក្ដីសម្រេចបិទផ្លូវតវ៉ា និងមានលក្ខណៈស្ថាពរ ។

ទោះបីយ៉ាងណាក៏ដោយ ច្បាប់បានបើកផ្លូវឲ្យមានការប្ដឹងជំនុំជម្រះសាជាថ្មី ឬ ជំនុំជម្រះឡើងវិញចំពោះសេចក្ដីសម្រេចស្ថាពរផងដែរ ដោយត្រូវបំពេញតាមលក្ខខណ្ឌដែលមានកំណត់ដោយច្បាប់។ នីតិវិធីនៃការប្ដឹងជំនុំជម្រះសារជាថ្មីត្រូវកំណត់ដោយច្បាប់។

## ៣.៤ ការជំទាស់ចំពោះសេចក្ដីសម្រេចរបស់តុលាការជាន់ខ្ពស់

ក្នុងករណីដែលភាគីណាមួយយល់ឃើញថា សេចក្ដីសម្រេចដែលចេញដោយតុលាការជាន់ទាបណាមួយធ្វើការសម្រេចខុស គឺ ភាគីនោះអាចប្ដឹងមកកាន់មូលដ្ឋាននៃតុលាការជាន់ខ្ពស់ ដោយត្រូវបំពេញបែបបទនៃពាក្យបណ្ដឹងស្របតាមនីតិវិធី និងត្រូវបញ្ជាក់ច្បាស់ពីប្រភេទនៃពាក្យបណ្ដឹង។ តាមរយៈនេះគឺភាគីត្រូវធ្វើបណ្ដឹងឧបាស្រ័យទៅកាន់តុលាការជាន់ខ្ពស់។

បណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គឺជាវិធីធ្វើឧបាស្រ័យទាមទារដោយភាគីទៅតុលាការជាន់ខ្ពស់ឱ្យលុបចោល ឬផ្លាស់ប្ដូរនូវសេចក្ដីសម្រេច (សាលក្រម សាលដីកា ឬដីកាសម្រេច) ដែលចេញដោយតុលាការថ្នាក់ក្រោមនៅមុនពេលដែលសេចក្ដីសម្រេចនោះចូលជាស្ថាពរ។[៤៣] បណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់អាចធ្វើទៅបាន តែមុនពេលដែលសេចក្ដីសម្រេចនោះចូលជាស្ថាពរតែប៉ុណ្ណោះ។

បណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ មាន ៣ ប្រភេទគឺ៖

[៤២] មាត្រា៣៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[៤៣] មាត្រា៣៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

- **បណ្តឹងឧទ្ធរណ៍៖** បណ្តឹងឧទ្ធរណ៍គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ចំពោះសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១ របស់សាលាដំបូង។ បណ្តឹងឧទ្ធរណ៍ អាចនឹងធ្វើឡើងបានតែចំពោះសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី ១ របស់សាលាដំបូងតែប៉ុណ្ណោះ យោងតាមមាត្រា២៥៩ នៃកថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ចំពោះសាលក្រម (មាត្រា១៨១) ដែលបាត់បង់នូវផលប្រយោជន៍ដោយសារតែសាលក្រមនៃការជំនុំជម្រះលើកទី១ មានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍។ ការណ៍ដែលបាត់បង់នូវផលប្រយោជន៍នោះ ត្រូវហៅថា មានផលប្រយោជន៍ក្នុងការប្តឹងឧបាស្រ័យ។ ជាគោលការណ៍ បើយកខ្លឹមសារនៃសាលក្រមដែលដើមចោទ ឬ ចុងចម្លើយនៃការជំនុំជម្រះលើកទី១ ដែលប្តឹងឧទ្ធរណ៍ បានទាមទារឱ្យតុលាការចេញនៅក្នុងការជំនុំជម្រះលើកទី១ មកប្រៀបធៀបជាមួយនឹងសាលក្រមនៃការជំនុំជម្រះលើកទី១ ហើយក្នុងករណីដែលសាលក្រមនោះ មានទំហំតូចជាងការទាមទាររបស់ភាគីនោះ ទើបផលប្រយោជន៍ក្នុងការប្តឹងឧបាស្រ័យ ត្រូវបានទទួលស្គាល់។

បណ្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ ខែ ដោយគិតពីថ្ងៃដែលបានទទួលនូវការបញ្ជូននៃលិខិតសាលក្រម នៃការជំនុំជម្រះលើកទី ១ ឬ ពីថ្ងៃដែលដីកាសម្រេចច្រានចោល ឬ លើកចោល។ [៤៧]

ប្រសិនបើអំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍កន្លងហួស ភាគីដែលមានសិទ្ធិប្តឹងឧទ្ធរណ៍បាត់បង់សិទ្ធិនោះ។ ហេតុដូច្នេះ ប្រសិនបើពាក្យបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ ក្រោយអំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍កន្លងហួសបណ្តឹងឧទ្ធរណ៍នោះ នឹងត្រូវបានលើកចោលដោយសាលដីកា ដោយសារបណ្តឹងឧទ្ធរណ៍នោះមានលក្ខណៈផ្ទុយនឹងច្បាប់ (មាត្រា ២៦៨) ម្យ៉ាងទៀត ក្រោយពេលសាលក្រមនៃការជំនុំជម្រះលើកទី ១ ត្រូវបានប្រកាស ទោះបីជាមិនបានទទួលការបញ្ជូនសាលក្រមក៏ដោយ ក៏ភាគីអាចប្តឹងឧទ្ធរណ៍ដោយស្របច្បាប់បានដែរ (មាត្រា ២៦៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២)។ ពេលដែលបានទទួលពាក្យបណ្តឹងឧទ្ធរណ៍ហើយ តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍នោះ ហើយប្រសិនបើពិនិត្យទៅរកឃើញថា មានចំណុចខ្វះខាត តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវបង្គាប់ឱ្យភាគីធ្វើការតម្រូវនូវចំណុចខ្វះខាតទាំងនោះ (មាត្រា ២៦៦ កថាខណ្ឌទី ១)។ បើទោះជាមានការបង្គាប់ឱ្យកែតម្រូវក៏ដោយ តែដើមបណ្តឹងឧទ្ធរណ៍មិនព្រមកែតម្រូវទេ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវលើកចោលពាក្យបណ្តឹងឧទ្ធរណ៍នោះ ដោយដីកាសម្រេច (មាត្រា ២៦៦ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២)។ ប្រសិនបើពាក្យបណ្តឹងឧទ្ធរណ៍ត្រឹមត្រូវតាមទម្រង់ច្បាប់ ក្រឡាបញ្ជី ត្រូវបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍នោះទៅឱ្យចុងបណ្តឹងឧទ្ធរណ៍ (មាត្រា ២៦៧ កថាខណ្ឌទី ១)។

- **បណ្តឹងសាទុក្ខ៖** បណ្តឹងសាទុក្ខគឺជាបណ្តឹងឧបាស្រ័យទៅតុលាការកំពូល ចំពោះសាលក្រម ឬ សាលដីកាចុងក្រោយដែលទាមទារឱ្យវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃសាលក្រម ឬ សាលដីកាចុងក្រោយ

ចំពោះការអនុវត្តច្បាប់ប៉ុណ្ណោះ។ ជាគោលការណ៍ បណ្ដឹងសាទុក្ខ អាចធ្វើបានចំពោះសាលដីកាចុងក្រោយនៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ដោយយោងតាមមាត្រា ២៨៣ កថាខណ្ឌទី១ វាក្យខណ្ឌទី១។ ការជំនុំជម្រះលើបណ្ដឹងសាទុក្ខ គឺជាការជំនុំជម្រះលើអង្គច្បាប់ ដែលតុលាការកំពូល វិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃសាលក្រម ឬសាលដីកាដើមចុងក្រោយ ក្នុងនាមជាតុលាការនៃបណ្ដឹងសាទុក្ខហេតុដូច្នេះការជំនុំជម្រះមានលក្ខណៈខុសគ្នាពីការជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍។ នៅក្នុងការជំនុំជម្រះបណ្ដឹងសាទុក្ខតុលាការពិនិត្យមើលជាថ្មីម្ដងទៀតទៅលើសាលក្រម ឬសាលដីកាដើម ដោយផ្អែកទៅលើធនធានដែលត្រូវបានប្រើប្រាស់សម្រាប់វិនិច្ឆ័យនៅក្នុងសាលក្រមឬសាលដីកាដើមនោះ។ តុលាការនៃបណ្ដឹងសាទុក្ខ មិនធ្វើការទទួលស្គាល់អង្គហេតុឡើងវិញទេ គឺគ្រាន់តែវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវក្នុងការអនុវត្តច្បាប់ចំពោះអង្គហេតុដោយផ្អែកលើការទទួលស្គាល់នូវអង្គហេតុដោយតុលាការដើម។

ដើម្បីឲ្យបណ្ដឹងសាទុក្ខមានអានុភាព ដើមបណ្ដឹងសាទុក្ខត្រូវតែ អះអាងមូលហេតុនៃបណ្ដឹងសាទុក្ខថាមានភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញច្បាប់ ឬបទដ្ឋានគតិយុត្តដែលជះឥទ្ធិពលដល់សាលក្រម ឬ សាលដីកា យោងតាមមាត្រា២៨៤ មានន័យថា ដើម្បីប្រើប្រព័ន្ធនៃបណ្ដឹងសាទុក្ខ មិនគ្រាន់តែមានផលប្រយោជន៍ក្នុងការប្ដឹងឧបាស្រ័យ (ផលប្រយោជន៍ក្នុងការប្ដឹងសាទុក្ខ) ចំពោះសាលក្រម ឬ សាលដីកាដើមប៉ុណ្ណោះទេ គឺត្រូវអះអាងផងដែរនូវភាពផ្ទុយនឹងច្បាប់ ឬបទដ្ឋានគតិយុត្តផ្សេងទៀត ជាមូលហេតុនៃបណ្ដឹងសាទុក្ខ (ហេតុដូច្នេះ ភាគីដែលឈ្នះក្ដីទាំងស្រុងនៅការជំនុំជម្រះដើម គ្មានផលប្រយោជន៍ក្នុងការប្ដឹងសាទុក្ខ ហើយបណ្ដឹងសាទុក្ខបែបនេះនឹងត្រូវបានលើកចោលជាដាច់ខាត ដោយសារបណ្ដឹងសាទុក្ខនោះមានលក្ខណៈផ្ទុយនឹងច្បាប់)។

មូលហេតុដាច់ខាតនៃបណ្ដឹងសាទុក្ខគឺ៖

- ភាពផ្ទុយច្បាប់ក្នុងការចាត់តាំងតុលាការដែលចេញសាលដីកា ឬ សាលក្រម យោងតាមមាត្រា ២៨៥ នៃកថាខណ្ឌទី ១ ចំណុច ក។
- ការចូលរួមក្នុងការចេញសាលដីកា ឬសាលក្រមរបស់ចៅក្រមដែលមិនត្រូវបានអនុញ្ញាតឱ្យចូលរួម(ចំណុចខ)
- ភាពខុសគ្នាសមត្ថកិច្ចផ្ដាច់មុខ (ចំណុច គ)
- ការខ្វះសិទ្ធិតំណាង ជាអាទិ៍ (ចំណុច ឃ)
- ភាពផ្ទុយនឹងបញ្ញត្តិស្ដីពីការបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ (ចំណុច ង)®
- និង ការខ្វះសំអាងហេតុ ឬ ភាពផ្ទុយគ្នារវាងសំអាងហេតុ និង សេចក្ដីសម្រេចបញ្ចប់កនៃសាលដីកា ឬ សាលក្រម ។(ចំណុច ច)

ដើមបណ្ដឹងសាទុក្ខ ត្រូវដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខ (សារណា) ជូនទៅតុលាការនៃបណ្ដឹងសាទុក្ខក្នុងអំឡុងពេល ៣០ ថ្ងៃ បន្ទាប់បីបានទទួលការបញ្ជូននូវលិខិតទទួលពាក្យបណ្ដឹងសាទុក្ខ ប្រសិនបើខ្លួន មិនបានសរសេរអំពីមូលហេតុនោះ នៅក្នុងពាក្យបណ្ដឹងសាទុក្ខទេ (មាត្រា ២៨៩ កថាខណ្ឌទី១)។ តុលាការនៃបណ្ដឹងសាទុក្ខ ត្រូវវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃសាលដីកាដើម ឬ សាលក្រមដើមត្រឹមតែកម្រិតនៃឧបាស្រ័យប៉ុណ្ណោះ ដោយផ្អែកលើមូលហេតុនៃបណ្ដឹងសាទុក្ខដែលត្រូវបានដាក់ដោយស្របនឹងច្បាប់ (មាត្រា ២៩៥)។ ក្នុងករណីដែលទទួលស្គាល់ថា មានមូលហេតុត្រឹមត្រូវសម្រាប់ធ្វើបណ្ដឹងសាទុក្ខ តុលាការត្រូវបដិសេធចោលនូវសាលក្រម ឬ សាលដីកាដើម (មាត្រា ២៩៩ កថាខណ្ឌទី ១)។ ការបដិសេធចោល មានន័យថា តុលាការនៃការជំនុំជម្រះលើអង្គច្បាប់ លុបចោលនូវសាលដីកាដើម ឬ សាលក្រមដើម។ តុលាការនៃបណ្ដឹងសាទុក្ខត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ នៅពេលដែលបដិសេធចោលនូវសាលដីកាដើម ឬសាលក្រមដើម (ការបកស្រាយបញ្ច្រាស់នៃមាត្រា ២៩៤)។

- **បណ្ដឹងជំទាស់៖** បណ្ដឹងជំទាស់គឺជាប្រព័ន្ធនៃបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលឯករាជ្យ និងសង្ខេបអាចធ្វើឡើងចំពោះដីកាសម្រេច ដែលជាសេចក្ដីសម្រេចដែល**មិនមែនជាសាលក្រម ឬ សាលដីកា**។ បណ្ដឹងជំទាស់ ត្រូវធ្វើក្នុងអំឡុងពេលមួយសប្ដាហ៍ ដោយរាប់គិតចាប់ពីថ្ងៃដែលបានទទួលដំណឹងអំពីដីកាសម្រេច (មាត្រា៣០៣ កថាខណ្ឌ១) ក្នុងពាក្យបណ្ដឹងជំទាស់គួរតែចុះអំពីមូលហេតុច្បាស់លាស់នៃការសុំលុបចោល ឬផ្លាស់ប្ដូរនូវដីកាសម្រេចដើម ក៏ប៉ុន្តែ ប្រសិនបើមិនសរសេរអំពីមូលហេតុទាំងនោះ ក៏បណ្ដឹងជំទាស់នោះមិនបែរជាគ្មានសុពលភាពដែរ។ ដីកាសម្រេច មានភាពខុសគ្នាពីសាលក្រម ឬសាលដីកា គឺជាគោលការណ៍ដីកាសម្រេច នឹង បង្កើតនូវអានុភាពចាំបាច់ដើម្បីសម្រេចនូវខ្លឹមសារនៃការសម្រេចសេចក្ដីដូចជាអានុភាពអនុវត្តនិងអានុភាពបង្កើតទំនាក់ទំនងគតិយុត្តជាដើម ដោយការជូនដំណឹងដែលគេអាចទទួលស្គាល់បានថាសមរម្យមួយតែប៉ុណ្ណោះ (មាត្រា២៣១ កថាខណ្ឌទី១) ក៏ប៉ុន្តែពេលដែលមានបណ្ដឹងជំទាស់អានុភាពនៃដីកាសម្រេចដើមដែលបានកើតឡើងម្ដងរួចហើយ ត្រូវបានបង្អាក់ (១ កថាខណ្ឌទី ៣០៥ មាត្រា)។

**ឧទាហរណ៍** *ប្រសិនបើបណ្ដឹងជំទាស់ត្រូវបានដាក់ចំពោះដីកាសម្រេចបង្គាប់ឱ្យផ្ដល់ឯកសារ (មាត្រា ១៥២ កថាខណ្ឌទី ៣) ភាគី ឬ តតិយជនដែលត្រូវបានបង្គាប់នោះ មិនចាំបាច់ផ្ដល់ឯកសារដែលតុលាការបង្គាប់ឱ្យផ្ដល់ឡើយ។ ជាទូទៅ ដីកាសម្រេចដែលអាចប្ដឹងជំទាស់ ប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគី និង មានភាពចាំបាច់ក្នុងការចូលជាស្ថាពរឱ្យបានឆាប់រហ័ស ហេតុដូច្នេះ អានុភាពនៃដីកាសម្រេចដើម ត្រូវផ្អាក ដោយមានការដាក់បណ្ដឹងជំទាស់តែប៉ុណ្ណោះ។*

នីតិវិធីនៃការជំនុំជម្រះបណ្តឹងជំទាស់ត្រូវបញ្ចប់ដោយដីកាសម្រេច តុលាការ អាចសម្រេចដោយឆន្ទានុសិទ្ធិបានថា តើត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬអត់ (មាត្រា៣០៦ កថាខណ្ឌទី១ និងមាត្រា១១៤ កថាខណ្ឌទី១ វាក្យខណ្ឌទី២)។ ក្នុងករណីដែលមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ទេ តុលាការនៃបណ្តឹងជំទាស់ អាចសួរម្ចាស់បណ្តឹងជំទាស់ ឬបុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងផលប្រយោជន៍នឹងបណ្តឹងជំទាស់នោះបាន (មាត្រា ៣០៦ កថាខណ្ឌទី២)។ ក្នុងការជំនុំជម្រះបណ្តឹងជំទាស់ ភាគីអាចដាក់អង្គហេតុថ្មី និងភស្តុតាងថ្មីដូចការជំនុំជម្រះបណ្តឹងឧទ្ធរណ៍។ សេចក្តីសម្រេចចុងក្រោយនៃការជំនុំជម្រះបណ្តឹងជំទាស់ គឺជាដីកាសម្រេច (សូមមើលមាត្រា ២៥៩ កថាខណ្ឌទី៣) ហើយខ្លឹមសារនៃដីកាសម្រេចនោះ ត្រូវអនុលោមទៅតាមសាលដីកាចុងក្រោយនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ (មាត្រា៣០៤ កថាខណ្ឌទី១)។ ប៉ុន្តែចំពោះបណ្តឹងជំទាស់ចំពោះដីកាសម្រេចដែលសាលាឧទ្ធរណ៍បានធ្វើក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី១ ការវិនិច្ឆ័យ និង ខ្លឹមសារនៃសេចក្តីសម្រេចចុងក្រោយ ត្រូវអនុលោមទៅតាមករណីនៃការជំនុំជម្រះបណ្តឹងសាទុក្ខដែលជាការវិនិច្ឆ័យលើអង្គច្បាប់ (មាត្រា ៣០៤ កថាខណ្ឌទី ២)។

ចំពោះដីកាសម្រេចចុងក្រោយនៃការជំនុំជម្រះបណ្តឹងជំទាស់ ដែលតុលាការនៃបណ្តឹងជំទាស់ចេញមិនអាចប្តឹងជំទាស់ទៀតឡើយ ដោយយោងតាមមាត្រា២៥៩ កថាខណ្ឌទី៣ គឺបានន័យថាភាគីមិនអាចប្តឹងជំទាស់ ចំពោះដីកាសម្រេចចុងក្រោយអំពីបណ្តឹងជំទាស់ ដែលត្រូវបានធ្វើដោយសាលាឧទ្ធរណ៍ដែលជាតុលាការនៃបណ្តឹងជំទាស់នោះ ទៅតុលាការកំពូលថែមទៀតបានឡើយ។ ការអនុវត្តបែបនេះ គឺដើម្បីសម្រាលនូវបន្ទុករបស់តុលាការកំពូល។ យ៉ាងណាមិញ ចំពោះដីកាសម្រេចដែលសាលាឧទ្ធរណ៍បានធ្វើឡើងក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី១ អាចប្តឹងជំទាស់ទៅតុលាការកំពូលបាន បើមានបញ្ញត្តិច្បាប់អនុញ្ញាតឱ្យប្តឹងជំទាស់ចំពោះដីកាសម្រេចនោះ។ បណ្តឹងជំទាស់នេះ គឺជាបណ្តឹងជំទាស់ទៅតុលាការកំពូលដែលជាតុលាការវិនិច្ឆ័យទៅលើអង្គច្បាប់ ហើយនីតិវិធីនៃការប្តឹងជំទាស់ទៅតុលាការកំពូល ករណីនេះគឺស្រដៀងគ្នាទៅនឹងការអនុវត្តចំពោះបណ្តឹងសាទុក្ខ ចំពោះសាលដីកាចុងក្រោយរបស់សាលាឧទ្ធរណ៍ដែលចេញនៅក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី១ដោយហេតុនោះ បញ្ញត្តិស្តីពីបណ្តឹងសាទុក្ខ និង នីតិវិធីទាក់ទងទៅនឹងការជំនុំជម្រះបណ្តឹងសាទុក្ខនោះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះបណ្តឹងជំទាស់លើដីកាសម្រេចដែលសាលាឧទ្ធរណ៍បានចេញក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី១ និងនីតិវិធីដែលទាក់ទងនឹងបណ្តឹងជំទាស់ទាំងនោះ លើកលែងតែករណីដែលបញ្ញត្តិនោះមានភាពផ្ទុយទៅនឹងលក្ខណៈនៃបណ្តឹង ឬ នីតិវិធីនោះ (មាត្រា ៣០៤ កថាខណ្ឌទី ២)។ ហេតុដូច្នេះ នៅក្នុងករណីនេះ បណ្តឹងជំទាស់នេះអាចធ្វើទៅបាន ដោយយកមូលហេតុនៃភាពផ្ទុយនឹងច្បាប់ ឬ បទដ្ឋានគតិយុត្តដែលមានឥទ្ធិពលលើដីកាសម្រេចតែប៉ុណ្ណោះដោយយោងតាមាត្រា ២៨៥។

ក្នុងករណីដែលភាគីមិនសុខចិត្តនឹងដីកាសម្រេចដែលធ្វើឡើងដោយចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ ជាបឋមវាជាការសមរម្យដែលត្រូវដាក់ដីកាសម្រេចឱ្យតុលាការដែលទទួលបណ្តឹងនោះពិនិត្យមើលជាមុនសិនដែលនេះជាចំណុចខុសគ្នានឹងដីកាសម្រេចរបស់តុលាការ។ ដូច្នេះ បើភាគីដែលមិនយល់ស្របចំពោះដីកាសម្រេចរបស់ចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ អាចប្តឹងតវ៉ាទៅតុលាការដែលទទួលបណ្តឹងដែលក្នុងករណីដែលច្បាប់អនុញ្ញាតឱ្យប្តឹងជំទាស់ ប្រសិនបើដីកាសម្រេចនោះ ជាដីកាសម្រេចរបស់តុលាការដែលទទួលបណ្តឹង ហើយចំពោះដីកាសម្រេចអំពីការតវ៉ានោះតែប៉ុណ្ណោះអាចប្តឹងជំទាស់បាន (មាត្រា ៣០២ កថាខណ្ឌទី១ វាក្យខណ្ឌទី១ និងកថាខណ្ឌទី២)។ ក៏ប៉ុន្តែ ក្នុងករណីដែលតុលាការដែលទទួលបណ្តឹងជាតុលាការកំពូល ឬសាលាឧទ្ធរណ៍ ភាគីអាចប្តឹងតវ៉ាបាន លុះត្រាតែច្បាប់អនុញ្ញាតឱ្យប្តឹងជំទាស់ប្រសិនបើ ដីកាសម្រេចនោះ ជាដីកាសម្រេចរបស់សាលាដំបូង (មាត្រា ៣០២ កថាខណ្ឌទី១ វាក្យខណ្ឌទី២) ប៉ុន្តែក្នុងករណីនេះ ប្រសិនបើតុលាការដែលទទួលបណ្តឹងជាតុលាការកំពូល ចំពោះដីកាសម្រេចអំពីការតវ៉ានោះ មិនអាចប្តឹងជំទាស់បាន ដោយសារគ្មានតុលាការជាន់ខ្ពស់ជាងតុលាការកំពូល។

[៤៤] មាត្រា៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[៤៥] **ចាំង ស៊ីណាត**, សិក្ខាសាលាស្តីពី ក្រមនីតិវិធីព្រហ្មទណ្ឌ, រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១០

[៤៦] មាត្រា២៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[៤៧] មាត្រា២០៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

# ជំពូកទី៤៖
# ភាពខុសគ្នារវាងតួនាទីមេធាវី និងតួនាទីតុលាការ

បន្ទាប់ពីបានសិក្សា និងឈ្វេងយល់អំពីតួនាទីរបស់អ្នកអនុវត្តវិជ្ជាជីវៈមេធាវី និងតួនាទីរបស់តុលាការរួចមក យើងបានសង្កេតឃើញថា តួនាទីនៃវិជ្ជាជីវៈទាំងពីរនេះ មានលក្ខណៈដោយឡែកនីមួយៗ និងមានចំណុចខ្លះដែលដូចគ្នាផងដែរ។ នៅក្នុងជំពូកនេះ យើងខ្ញុំនឹងធ្វើការប្រៀបធៀបនូវភាពខុសគ្នានៃតួនាទីទាំងពីរដែលរំលេចចេញតាមរយៈច្បាប់ជាធរមាន និងគោលការណ៍នានាដែលស្ថាប័នគ្រប់គ្រងនៃវិជ្ជាជីវៈនេះ។

ដូចដែលបានរៀបរាប់លម្អិតនៅក្នុងជំពូកទី២ និងជំពូកទី៣ខាងលើ វិជ្ជាជីវៈទាំងពីរនេះ មានតួនាទីនិងចំណុចពិសេសរបស់ខ្លួនរៀងៗខ្លួន។ តើអ្វីទៅដែលជាចំណុចខុសគ្នានៃអ្នកអនុវត្តវិជ្ជាជីវៈនេះ? តើមានអ្វីដែលជាចំណុចពិសេសដែលរំលេចនូវភាពខុសគ្នាពិតប្រាកដ? ដើម្បីបកស្រាយសំណួរនេះ យើងខ្ញុំសូមធ្វើការបកស្រាយទៅចំណុចដូចតទៅ៖

## ផ្នែកទី១៖ ឯករាជ្យភាពនៃវិជ្ជាជីវៈមេធាវី

វិជ្ជាជីវៈមេធាវី គឺជាវិជ្ជាជីវៈសេរី និងឯករាជ្យ ដែលមិនស្ថិតក្រោមការអំណាចរបស់ស្ថាប័នណាទាំងអស់។ យោងតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី វិជ្ជាជីវៈមេធាវី ត្រូវកំណត់ក្នុងក្របខណ្ឌរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលជាស្ថាប័នឯករាជ្យដូចគ្នា។ ដោយសារតែវិជ្ជាជីវៈនេះ មានលក្ខណៈពិសេសនេះហើយទើបមានសំណួរមួយលើកឡើងថា តើអ្វីទៅដែលជា **ឯករាជ្យភាពនៃវិជ្ជាជីវៈមេធាវី**?

### ១. ឯករាជ្យភាពនៃវិជ្ជាជីវៈមេធាវី

ឯករាជ្យភាពនៃវិជ្ជាជីវៈមេធាវី សម្តៅទៅលើសេរីភាពរបស់អ្នកអនុវត្តវិជ្ជាជីវៈមេធាវី ក្នុងការបំពេញតួនាទី និងការងារទាក់ទងនឹងវិជ្ជាជីវៈនេះ។ ជាទូទៅ បើតាមគំនិតរបស់អ្នកអនុវត្តក្នុងវិជ្ជាជីវៈច្បាប់ដូចគ្នា មេធាវី មានឯករាជ្យភាពគឺ ដោយសារអ្នកអនុវត្តវិជ្ជាជីវៈនេះ មិនស្ថិតក្រោមក្របខណ្ឌនៃស្ថាប័នណា ក្រៅពីគណៈមេធាវី ពិសេសគឺគ្មានក្របខណ្ឌដូចវិជ្ជាជីវៈច្បាប់ដទៃ។ គំនិតនេះគ្រាន់តែជា ផ្នែកមួយនៃការអនុវត្តវិជ្ជាជីវៈមេធាវីតែប៉ុណ្ណោះ ជាការពិតនៅពេលអនុវត្តវិជ្ជាជីវៈ មេធាវី មានសេរីភាពក្នុងការធ្វើសិទ្ធិសម្រេចទទួលរឿងក្តីពីអតិថិជន និងជ្រើសរើសប្រភេទសំណុំរឿងទៀតផង មានន័យថា មេធាវីម្នាក់ អាចសម្រេចចិត្តដោយខ្លួនឯងថា ទទួលធ្វើ ឬមិនទទួលធ្វើរឿងដែលកូនក្តីបានដាក់ពឹងពាក់មកដើម្បីធ្វើជាតំណាង។

***មេធាវី គឺជាវិស្វករនៃយុត្តិធម៌សង្គម***[៤៨] ឃ្លានេះបើតាមពិនិត្យមើលទៅ មានលក្ខណៈចំលែកបន្តិចដោយសារវិជ្ជាជីវៈនេះគឺពាក់ព័ន្ធទៅលើច្បាប់ដែលជាមុខវិជ្ជាផ្នែកសង្គមទាំងស្រុង ប៉ុន្តែបើយើងសង្កេតឱ្យបានជ្រៅ

ជ្រះ ពាក្យថា **វិស្វករនៃយុត្តិធម៌សង្គម** នៅក្នុងចំណុចនេះសម្តៅទៅលើការងាររបស់មេធាវីដែលចូលរួមយ៉ាងសកម្មក្នុងការការពារ និងពង្រឹងនូវយុត្តិធម៌ក្នុងសង្គម តាមរយៈការការពារជូនជនក្រីក្រជាដើម។ ដូចនេះ យោងតាមទ្រឹស្តីខាងលើ យើងអាចសន្និតថា ឯករាជ្យភាពនៃវិជ្ជាជីវៈមេធាវី គឺស្ថិតលើការអនុវត្តវិជ្ជាជីវៈនេះតែម្តង ពោលគឺរាល់បុគ្គលដែលទទួលបានការអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈមេធាវី មានភារកិច្ចក្នុងការគោរពនូវបទបញ្ញត្តិនៃលិខិតបទដ្ឋាននានា របស់មេធាវី ព្រមទាំងមានក្រមសីលធម៌ ក្នុងការប្រកបវិជ្ជាជីវៈដើម្បីចូលរួមក្នុងការពង្រឹងវិជ្ជាជីវៈមេធាវី និងយុត្តិធម៌សង្គម។

## ២. ការធានាលើការអនុវត្តវិជ្ជាជីវៈមេធាវី

ការធានាលើការអនុវត្តវិជ្ជាជីវៈមេធាវី ជាកិច្ចដែលស្ថាប័នអនុវត្តត្រូវតែធ្វើដើម្បីធានាការអនុវត្តប្រកបដោយភាពត្រឹមត្រូវ សុចរិតភាព និងក្រមសីលធម៌។ ការធានាលើវិជ្ជាជីវៈមេធាវី ត្រូវបានដាក់ចេញជាគោលការណ៍ និងបេសកម្មរបស់គណៈមេធាវី ដែលកំណត់ដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ព្រោះមានតែស្ថាប័ននេះតែមួយគត់ដែលត្រូវបានបញ្ញត្តិដោយច្បាប់ដើម្បីទទួលបន្ទុកលើការពិនិត្យ និងធានាការអនុវត្តវិជ្ជាជីវៈរបស់សហភាគា។[៤៩]

គិតពីថ្ងៃដែល គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើត ថ្នាក់ដឹកនាំគណៈមេធាវី បានខិតខំយ៉ាងខ្លាំងក្នុងការធានានូវសីលធម៌ និងការអនុវត្តរបស់សមាជិកខ្លួន ជាក់ស្តែងប្រធានគណៈមេធាវី និងសមាជិកក្រុមប្រឹក្សាគណៈមេធាវីពីមួយអាណត្តិទៅមួយអាណត្តិបានដាក់ចេញនូវគោលការណ៍ជាច្រើន ដែលមានវិសាលភាពអនុវត្តសម្រាប់សមាជិក-សមាជិកាគណៈមេធាវីទាំងអស់។ ថ្មីៗនេះផងដែរ គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំរបស់ លោកមេធាវី **សួន វិសាល** ព្រមទាំងមានការគាំទ្រពីសមាជិកក្រុមប្រឹក្សាគណៈមេធាវី អាណត្តិទី៩ បានសម្រេចចេញនូវគោលការណ៍ថ្មីជាច្រើនរបស់គណៈមេធាវី ដូចជា៖ ការធ្វើប្រតិភូកម្មអំណាចទៅមេធាវីទូទាំងប្រទេសដើម្បីសហការក្នុងការការពារក្តីជូនជនក្រីក្រតាមរយៈការបង្កើតឱ្យមានការិយាល័យប្រតិភូគណៈមេធាវីនៅតាមសាលាដំបូងរាជធានី-ខេត្តទាំង២៤ , ការបង្កើតឱ្យមានគណៈកម្មការវិន័យជាដើម ដែលគោលការណ៍នេះសុទ្ធតែបង្កើតឡើងក្នុងន័យថែរក្សា ពង្រឹងនូវការអនុវត្តវិជ្ជាជីវៈ និងតម្លៃមេធាវីក្នុងសង្គម។

## ៣. ការដាក់វិន័យចំពោះមេធាវីដែលប្រព្រឹត្តខុសពីក្រមសីលធម៌ និងវិជ្ជាជីវៈមេធាវី

វិន័យ គឺជាបទប្បញ្ញត្តិដែលត្រូវបានកំណត់ឱ្យសមាជិកត្រូវតែអនុវត្តដោយលិខិតបទដ្ឋានមេធាវី ជាក់ស្តែងដើម្បីអនុវត្តគោលការណ៍ត្រឹមត្រូវ គណៈមេធាវី ក៏ធ្លាប់ដាក់វិន័យលើសមាជិករបស់ខ្លួនដែលប្រព្រឹត្តខុសក្នុងការប្រកបវិជ្ជាជីវៈ ដូចជាការដាក់ឈ្មោះឱ្យនៅក្រៅបញ្ជីសមាជិកគណៈមេធាវី និង ការលុបឈ្មោះចេញពីបញ្ជីសមាជិក

---

[៤៨] ការលើកឡើងរបស់លោកមេធាវី **យុង ផានិត**, សមាជិកក្រុមប្រឹក្សាគណៈមេធាវី និងជាអនុប្រធាននាយកដ្ឋានការពារក្តីជូនជនក្រីក្រនៃគណៈមេធាវី

[៤៩] មាត្រា១ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ដែលប្រកាសឱ្យប្រើថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥

គណៈមេធាវីជាដើម។ ក្នុងឆ្នាំ២០១៩ នេះ គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា តាមរយៈគំនិតផ្តួចផ្តើមរបស់លោកប្រធានគណៈមេធាវី និងការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី បានដាក់ចេញនូវគោលការណ៍នៃការបង្កើតឱ្យមាន គណៈកម្មការថ្មីមួយ គឺគណៈកម្មការវិន័យ។ គណៈកម្មការ នេះមានតួនាទីទទួលបន្ទុកតាមការកំណត់ដោយ សេចក្តីសម្រេចរបស់គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។

## ៣.១ គណៈកម្មការវិន័យនៃគណៈមេធាវី

គណៈកម្មការវិន័យនៃក្រុមប្រឹក្សាគណៈមេធាវី គឺជាគណៈកម្មការមួយដែលមានតួនាទីកំណត់នូវនីតិវិធីក្នុងការដោះស្រាយវិវាទដែលកើតចេញពីការប្រកបវិជ្ជាជីវៈមេធាវី រវាងមេធាវី ជាមួយមេធាវី និងមេធាវីជាមួយអតិថិជន។[៥០] គណៈកម្មការវិន័យនេះ ត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចលេខ២៩៤/សសគម/១៩ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩ ដែលមានសមាសភាពជាក្រុមប្រឹក្សាគណៈមេធាវី មាន ៣ ក្រុម គឺក្រុមប្រឹក្សាជំនុំជម្រះទី១ ក្រុមប្រឹក្សាជំនុំជម្រះទី២ និងក្រុមប្រឹក្សាជំនុំជម្រះទី៣ ដែលក្នុងមួយក្រុមមានសមាជិក ៣ រូប។ សមាជិកនៃក្រុមប្រឹក្សានេះកើតចេញពីការបោះឆ្នោតដោយទទួលបានសំឡេងភាគច្រើនដាច់ខាតនៃក្រុមប្រឹក្សាគណៈមេធាវីទាំងមូល។

តួនាទីរបស់គណៈកម្មការនេះ មានដូចតទៅៈ

- ដោះស្រាយវិវាទរបស់មេធាវី និងមេធាវី ឬរវាងមេធាវី និងអតិថិជន

- ទទួលបណ្តឹងពីភាគីបណ្តឹង ដែលមានការិយាល័យទទួលពាក្យបណ្តឹងនៃនាយកដ្ឋានអធិការកិច្ចជាសេនាធិការ។

- ពិនិត្យ និងស៊ើបអង្កេតលើបណ្តឹងដែលបានដាក់មក

- ជំនុំជម្រះលើបណ្តឹងដែលបានទទួលយកមកជំនុំជម្រះ

- ធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងការដោះស្រាយលើបណ្តឹងដែលបានដាក់មក

## ៣.២ ការដាក់វិន័យចំពោះមេធាវីដែលអនុវត្តខុសពីវិន័យនិងក្រមសីលធម៌

ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បានកំណត់នូវទណ្ឌកម្ម២ គឺទណ្ឌកម្មវិន័យ និងទោសប្បញ្ញត្តិចំពោះអ្នកប្រព្រឹត្តផ្ទុយនឹងវិន័យ និងក្រមសីលធម៌ក្នុងការប្រកបវិជ្ជាជីវៈមេធាវី ដូចតទៅៈ

• ទណ្ឌកម្ម ជាវិន័យ (មាត្រា៦៣ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី)

ក- ការព្រមាន

ខ- ការស្តីបន្ទោស

[៥០] ប្រការ១ នៃសេចក្តីសម្រេចលេខ ២៩៤/សសគម/១៩ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការបង្កើតគណៈកម្មការវិន័យនៃក្រុមប្រឹក្សាគណៈមេធាវី

គ- ការហាមឃាត់មិនឱ្យប្រកបវិជ្ជាជីវៈមេធាវីមួយរយៈពេលដែលមិនលើសពី ១០ឆ្នាំ

ឃ- ការលុបឈ្មោះចេញពីបញ្ជីនៃគណៈមេធាវី ឬបញ្ជីមេធាវីកម្មសិក្សា ឬការដកហូតងារកិត្តិយស

- ទោសប្បញ្ញត្តិ (មាត្រា៧៧ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី)

ក- ជនណាដែលប្រព្រឹត្តខុសពីមាត្រា ១-២-៣-៤-៥-៦-៧-១៣ និង ៥៧ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល ទៅ ៥លានរៀល។ ប្រសិនបើជាជនបរទេស ត្រូវបណ្តេញចេញពីដែនដីព្រះរាជាណាចក្រកម្ពុជា

ខ- ករណីមិនរាងចាល ត្រូវពិន័យទ្វេដង និងដាក់ពន្ធនាគាររយៈពេល ៣ ទៅ ៦ខែ។

នៅក្នុងចំណុចទោសប្បញ្ញត្តិ ក្រុមប្រឹក្សាគណៈមេធាវី អាចឈរជាដើមបណ្តឹងរដ្ឋប្បវេណីតំណាងឱ្យគណៈមេធាវីបាន។

# ផ្នែកទី២៖ ឯករាជ្យភាពនៃអំណាចតុលាការ និងការអនុវត្តតួនាទីរបស់តុលាការ

## ១. ឯករាជ្យភាពនៃអំណាចតុលាការ និងការអនុវត្តតួនាទីរបស់តុលាការ

មាត្រា១២៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ឱ្យអំណាចរបស់តុលាការជាអំណាចមួយឯករាជ្យ ដែលមានសិទ្ធិស្វ័យសម្រេចក្នុងការចេញសេចក្តីសម្រេចដែលមានលក្ខណៈយុត្តិសាស្ត្រ។

**តើអ្វីទៅជាឯករាជ្យភាពនៃតុលាការ?**

ឯករាជ្យភាពនៃតុលាការ សម្តៅទៅលើសេរីភាព និងអំណាចស្វ័យសម្រេចរបស់តុលាការក្នុងការសម្រេចសេចក្តីលើនរណាម្នាក់ដែលបានប្រព្រឹត្តខុសនឹងច្បាប់ជាធរមាន។ ដូចដែលបានបញ្ជាក់នៅក្នុងជំពូកទី៣ ស្តីពីតួនាទីតុលាការ បានបញ្ជាក់ថា តុលាការ គឺជាសាលាជម្រះក្តីដែលមានចៅក្រម ក្រឡាបញ្ជី និងមន្ត្រីជាច្រើនជាមន្ត្រីបម្រើការមានតួនាទីជំនុំជម្រះលើសំណុំរឿងដែលបានដាក់ជូន ព្រមទាំងវត្តមានរបស់តំណាងអង្គការអយ្យការដែលមានព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង និងក្រឡាបញ្ជី ដែលមានតួនាទីផ្តាច់មុខលើបណ្តឹងអាជ្ញានៅអមជាមួយផងដែរ។ សេចក្តីសម្រេចរបស់តុលាការ គឺជាសក្ខីកម្មនៃឯករាជ្យភាពតុលាការ ព្រោះសេចក្តីសម្រេចនានារបស់ស្ថាប័នតុលាការនេះ គឺជាទម្រង់នៃការសម្រេចប្រកបដោយយុត្តិសាស្ត្រ ពិសេសគឺគោរពទៅតាមប្បញ្ញត្តិនៃនីតិវិធីច្បាប់ជាធរមាន និងគ្មានស្ថាប័ន ឬអំណាចណាអាចចូលមកកែប្រែ ទប់ស្កាត់ ឬរារាំងការអនុវត្តឡើយនៅពេលសេចក្តីសម្រេចនោះបានចូលជាស្ថាពរ លើកលែងតែមានករណីពិសេសណាដែលកំណត់ដោយច្បាប់។

ទោះជា អំណាចតុលាការ នេះមានឯករាជ្យភាពក៏ដោយ ក៏អំណាចទាំងនេះនៅបានកម្រិតដោយបទដ្ឋានគតិយុត្តកម្ពុជា ក្នុងអត្ថន័យកំណត់នូវនីតិវិធីនិងការអនុវត្តការងាររបស់អ្នកអនុវត្តវិជ្ជាជីវៈប្រកបដោយភាពត្រឹមត្រូវស្របច្បាប់ និងមានក្រមសីលធម៌ ពិសេសអាចប្រើជាគោលការណ៍ក្នុងការបង្រៀនដល់អ្នកសិក្សាវិជ្ជាជីវៈច្បាប់។

## ២. ការធានាលើការអនុវត្តវិជ្ជាជីវៈតុលាការ

ចៅក្រម និងព្រះរាជអាជ្ញា គឺជាអ្នកអនុវត្តវិជ្ជាជីវៈដែលមានតួនាទីផ្សេងគ្នា ប៉ុន្តែស្ថិតក្នុងក្របខណ្ឌនៃក្រសួងយុត្តិធម៌ និងស្ថិតក្រោមបញ្ញត្តិនៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ដែលបានប្រកាសឱ្យប្រើកាលពីថ្ងៃទី១៦ ខែកក្កដាឆ្នាំ២០១៤។ មិនខុសពីអ្នកអនុវត្តវិជ្ជាជីវៈមេធាវីដែលមាន គណៈមេធាវីជាស្ថាប័នគ្រប់គ្រង និងពិនិត្យការអនុវត្តវិជ្ជាជីវៈ ចៅក្រម និងព្រះរាជអាជ្ញា ក៏មានស្ថាប័នសម្រាប់គ្រប់គ្រងដូចគ្នាផងដែរ គឺ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងក្រសួងយុត្តិធម៌។

### ២.១ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គឺជាស្ថាប័នមួយដែលបង្កើតឡើងដំបូងដោយព្រះរាជក្រមលេខ០៩ នស/រកម/៩៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤ ប៉ុន្តែច្បាប់ត្រូវបាននិរាករណ៍ និងបង្កើតឡើងវិញដោយព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ថ្មីស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ យោងតាមបទប្បញ្ញត្តិថ្មីនេះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មាន **ព្រះមហាក្សត្រ** ជាព្រះប្រធានកិត្តិយស មានសមាជិកចំនួន១១ រូប។ [៥១]

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានតួនាទីស្នូលក្នុងការតែងតាំង ផ្លាស់ប្តូរ ផ្តាច់ពីមុខងារ ឬដាក់ឱ្យនៅក្រៅក្របខណ្ឌ ដាក់ឱ្យទំនេរ ឬលុបឈ្មោះចៅក្រមទាំងអស់។ ក្រៅពីកិច្ចការងារនេះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក៏មានតួនាទីក្នុងការពិគ្រោះយោបល់លើសេចក្តីស្នើច្បាប់ ឬ សេចក្តីព្រាងច្បាប់នានាទាក់ទងនឹងវិស័យ តុលាការផងដែរ។[៥២]

### ២.២ ក្រសួងយុត្តិធម៌

ក្រសួងយុត្តិធម៌ គឺជាស្ថាប័នមួយដែលស្ថិតនៅក្រោមអំណាចនីតិប្រតិបត្តិ មានមុខងារ និងតួនាទីក្នុងការគាក់តែង ពិនិត្យ និងធានានូវយុត្តិធម៌របស់ប្រជាពលរដ្ឋ និងការប្រព្រឹត្តទៅរបស់តុលាការ។ ក្រសួងយុត្តិធម៌ បានដើរតួយ៉ាងសំខាន់នៅក្នុងវិស័យតុលាការ នៅក្នុងចំណុចនេះមិនមែនមានន័យថា ក្រសួងយុត្តិធម៌ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល បានធ្វើការលូកដៃចូលទៅក្នុងអំណាចតុលាការដែលជាអំណាចឯករាជ្យនោះទេ តាមពិតទៅ ក្រសួងនេះ មានបេសកម្មយ៉ាងធំធេងក្នុងការបំពេញការងារជាមួយនឹតុលាការ ពិសេសគឺជួយធានាលើការអនុវត្តរបស់តុលាការ។ អនុលោមតាមអនុក្រឹត្យលេខ៤៧ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ បានកំណត់ឱ្យក្រសួងយុត្តិធម៌មានអគ្គនាយកដ្ឋានបច្ចេកទេស និងអធិការដ្ឋានកិច្ចការតុលាការ ដើម្បីចូលរួមជួយក្នុងការប្រព្រឹត្តទៅនៃតុលាការក្នុងវិស័យនេះ។ អគ្គនាយកដ្ឋាន និងនាយកដ្ឋាននីមួយៗនៃក្រសួងយុត្តិធម៌មានតួនាទីស្នូលក្នុងការពិនិត្យ និងឃ្លាំមើលការងារ និងទទួលនូវសំណូមពរផ្សេងៗពីតុលាការដើម្បីរាយការណ៍ទៅថ្នាក់លើ។

លើសពីនេះផងដែរ ក្រសួងយុត្តិធម៌ ក៏មានតួនាទីក្នុងការអន្តរាគមន៍លើការបំពេញការងាររបស់តុលាការ និងអ្នកអនុវត្តវិជ្ជាជីវៈផងដែរ។ យោងតាមអនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌ ក្រសួងយុត្តិធម៌ អាចធ្វើអធិការកិច្ចលើបណ្តឹងដែលប្តឹងដោយបុគ្គលណា ដើម្បីអន្តរាគមន៍ទៅតុលាការ ក្នុងករណីមិនប្រក្រតី ឬដោយមន្ត្រីតុលាការ បានប្រព្រឹត្តខុសវិន័យ ឬក្រមសីលធម៌ ដែលមានកំណត់ក្នុងច្បាប់ជាធរមាន។

ក្រសួងយុត្តិធម៌ ក៏មានសមត្ថកិច្ចក្នុងការបណ្តុះបណ្តាល និងជ្រើសរើសសិស្សឱ្យចូលរៀនវិជ្ជាជីវៈតុលាការផងដែរ ក្រសួងយុត្តិធម៌ មានរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការជាស្ថាប័នទទួលបន្ទុកការងារនេះផងដែរ។ សិស្សដែលបញ្ចប់ការសិក្សា នៅរាជបណ្ឌិត្យសភាខាងលើ ត្រូវបែងចែកទៅតាមតុលាការទូទាំងប្រទេស ដើម្បីធ្វើការងារអនុវត្តក្នុងវិស័យតុលាការ។

មិនត្រឹមតែការសម្រួលកិច្ចការងារទាំងនេះ ក្រសួងយុត្តិធម៌ ក៏ជាសេនាធិការដ៏ធំរបស់តុលាការគ្រប់ជាន់ថ្នាក់ ព្រមទាំងអង្គភាពចំណុះ ដូចជា៖ គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាដើមក្នុងការស្នើសុំកញ្ចប់ថវិកាប្រចាំឆ្នាំនីមួយៗទៅក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ។ យោងតាមច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈ នៅក្នុងវិស័យយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជាអាណាប័កដើមសារ ក្នុងការស្នើសុំកញ្ចប់ថវិកាប្រចាំឆ្នាំពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបែងចែកប្រើប្រាស់ក្នុងស្ថាប័នចំណុះនានា។ ក្រសួងយុត្តិធម៌ មាននាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ ជាអ្នកទទួលបន្ទុកលើការងារនេះ ដើម្បីស្នើសុំកញ្ចប់ថវិកាបានតុលាការគ្រប់ជាន់ថ្នាក់ និងអង្គភាពចំណុះត្រូវធ្វើរបាយការណ៍ទៅក្រសួងយុត្តិធម៌ ដែលតម្រូវឱ្យធ្វើឱ្យបានមុនពាក់កណ្តាលខែមិថុនារៀងរាល់ឆ្នាំ។ នៅពេលទទួលរបាយការណ៍ នាយកដ្ឋានកិច្ចការហិរញ្ញវត្ថុនៃក្រសួងយុត្តិធម៌ នឹងធ្វើពិចារណានិងដាក់សំណើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងករណីតម្រូវឱ្យមានការឡើងការពារថវិកានោះ នាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ ជាអ្នកទទួលខុសត្រូវប៉ុន្តែសាមីស្ថាប័នដែលដាក់ស្នើត្រូវមានការពន្យល់ជាមុន។ សរុបសេចក្តីមក ក្រសួងយុត្តិធម៌ គឺជា ស្ថាប័នចំបងរបស់ស្ថាប័នតុលាការគ្រប់ជាន់ថ្នាក់ ក្នុងការធ្វើទំនាក់ទំនងជាប្រព័ន្ធទៅជាមួយនឹងរាជរដ្ឋាភិបាល និងប្រជាពលរដ្ឋ ហើយក៏ជាស្ថាប័នដែលធានាលើការអនុវត្តនៃប្រព័ន្ធតុលាការផងដែរ។

### ៣. ការកំណត់ទណ្ឌកម្ម ចំពោះចៅក្រម ឬព្រះរាជអាជ្ញាដែលប្រព្រឹត្តខុសវិជ្ជាជីវៈ

វិន័យរបស់ចៅក្រម និងព្រះរាជអាជ្ញាត្រូវបានបញ្ញត្តិក្នុងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ច្បាប់នេះបានកំណត់អំពីទោសវិន័យដែលសមាជិកជាចៅក្រម និងព្រះរាជអាជ្ញា ត្រូវទទួលក្នុងករណីប្រព្រឹត្តខុសទៅនឹងវិន័យដែលកំណត់ដោយច្បាប់ ទណ្ឌកម្ម និងវិន័យចំពោះសមាជិក មានដូចតទៅ៖

មាត្រា៥៥ នៃ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា បែងចែកជា ២ថ្នាក់គឺ៖

- **ទណ្ឌកម្មថ្នាក់ទី១៖** អាចសម្រេចត្រឹមថ្នាក់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបាន

ក- ការស្តីបន្ទោសដោយផ្ទាល់មាត់

ខ- ការស្តីបន្ទោសដោយចុះក្នុងសំណុំលិខិតផ្ទាល់ខ្លួន

គ-ការផ្អាកមិនឱ្យចុះឈ្មោះក្នុងតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិមួយរយៈតែមិនត្រូវឱ្យលើសពី ២(ពីរ) ឆ្នាំទេ ឬ លុបឈ្មោះចេញពីតារាងដំឡើងថ្នាក់ ឬឋានន្តរសិក្តិករណីមានចុះឈ្មោះរួចហើយ។

- **ទណ្ឌកម្មថ្នាក់ទី២៖** ធ្វើឡើងដោយព្រះរាជក្រឹត្យ ក្រោយមានការសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ក-  ការផ្លាស់ប្តូរដោយបង្ខំ អាចតម្រូវឱ្យមានការទទួលបណ្តុះបណ្តាលបន្ថែម

ខ- ការព្យួរពីការងារមិនឱ្យមានបៀវត្ស ក្នុងរយៈពេលមិនឱ្យលើសពី ១ (មួយ) ឆ្នាំ

គ- ការបន្ថយមួយថ្នាក់ ឬច្រើនថ្នាក់ ឬបន្ថមឋានន្តរសក្តិ

ឃ- ការដាក់ឱ្យចូលនិវត្តន៍ដោយបង្ខំ

ង- ការបញ្ឈប់ពីមុខងារដោយបង្ខំ

ច- ការបណ្តេញចេញពីក្របខណ្ឌ។

[៥១] មាត្រា៤ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

[៥២] មាត្រា១៨ និងមាត្រា១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សា ពិភាក្សា និងស្រាវជ្រាវទៅលើប្រធានបទខាងលើស្តីអំពី **ភាពខុសគ្នារវាងតួនាទីមេធាវី និងតួ នាទីតុលាការ** រួចមក ធ្វើឱ្យយើងខ្ញុំបានឈ្វេងយល់ថា វិជ្ជាជីវៈច្បាប់ គឺជាវិជ្ជាជីវៈដែលមានភាពពិសេសមួយ ព្រោះវិជ្ជាជីវៈនេះ មានវិជ្ជាជីវៈតូចៗបន្ថែមទៀតទៅតាមបច្ចេកទេសដែលកំណត់ដោយច្បាប់ជាធរមាន ជាក់ស្តែង ដូចជាវិជ្ជាជីវៈចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមេធាវីជាដើម ដែលវិជ្ជាជីវៈទាំងអស់នេះ សុទ្ធតែមាន លក្ខណៈពិសេស និងលក្ខខណ្ឌបច្ចេកទេសរបស់ខ្លួន។ ប៉ុន្តែទោះយ៉ាងណាក៏ដោយ ការអនុវត្តវិជ្ជាជីវៈទាំងអស់ នេះ ត្រូវធ្វើឡើងក្នុងគោលដៅតែមួយគត់ គឺដើម្បី “**យុត្តិធម៌**” ។

ក្នុងនាមជាអ្នកអនុវត្តវិជ្ជាជីវៈច្បាប់ ត្រូវប្រកាន់ភ្ជាប់នូវគោលការណ៍នេះ ព្រោះ យុត្តិធម៌ គឺជាផ្នែកមួយដ៏ សំខាន់ក្នុងជីវិតរបស់មនុស្ស។ ដូចដែលច្បាប់បានកំណត់ទៅតាមវិជ្ជាជីវៈ ចៅក្រម គឺជាអ្នកដែលមានសិទ្ធិក្នុង ការជំនុំជម្រះលើជនដែលប្រព្រឹត្តដែលប្រព្រឹត្តបទល្មើសតាមអំពើ និងច្បាប់ជាធរមាន ព្រះរាជអាជ្ញា ជាអ្នកមាន សិទ្ធិផ្តាច់មុខលើបណ្តឹងអាជ្ញា និងការចោទប្រកាន់លើបុគ្គលដែលប្រព្រឹត្តខុសនឹងច្បាប់ព្រហ្មទណ្ឌ ក្រឡាបញ្ជី ជាអ្នកកត់ត្រា និង គ្រប់គ្រងសំណុំរឿង ចំណែកវិជ្ជាជីវៈមេធាវី ដែលជាវិជ្ជាជីវៈឯករាជ្យ មានតួនាទីជាអ្នកតំណាង ក្នុងការតវ៉ា និងការពារក្តីជូនអតិថិជន តាមរយៈភស្តុតាង ឬដោយសំអាងលើហេតុផលណាមួយដែលសមស្រប អាចឱ្យតុលាការពិចារណាជាដើម។ ដោយហេតុតែបុគ្គលដែលប្រកបវិជ្ជាជីវៈទាំងនេះ ស្ថិតនៅក្នុងក្របខណ្ឌវិជ្ជា ជីវៈច្បាប់តែមួយនេះហើយ ទើបប្រជាពលរដ្ឋមួយចំនួន យល់ច្រឡំអំពីតួនាទីរបស់អ្នកអនុវត្តវិជ្ជាជីវៈទាំងនោះ ដោយប្រជាជនមួយចំនួនគិតថា មេធាវី គឺជាអ្នកបម្រើការនៅតុលាការ ឬជាអ្នកដែលតុលាការត្រូវហៅនៅពេល ការពារក្តីតែប៉ុណ្ណោះ។ ដោយហេតុតែការមើលឃើញនូវចំណុចអវិជ្ជមាននេះ ហើយទើបយើងខ្ញុំបានធ្វើការ ពិចារណាទាញយកប្រធានបទនេះ ដើម្បីធ្វើការបកស្រាយអំពីនីតិវិធី និងដំណើរការងារផ្សេងៗទាក់ទងនឹងវិជ្ជា ជីវៈនីមួយៗក្នុងន័យរំលេចនូវភាពខុសគ្នានៃតួនាទី ភារកិច្ច នីតិវិធីនៃការចូលប្រកប និងច្បាប់នានាដែលកំណត់ អំពីក្រមសីលធម៌អ្នកអនុវត្តវិជ្ជាជីវៈនោះ។

សរុបសេចក្តីមក តួនាទី និងភារកិច្ចរបស់អ្នកអនុវត្តវិជ្ជាជីវៈទាំងអស់ ត្រូវបានកំណត់ និងបែងចែកដោយ ច្បាប់ ដូចនេះអ្នកអនុវត្តវិជ្ជាជីវៈទាំងអស់ចាំបាច់ត្រូវយល់ដឹងដែនសមត្ថកិច្ច និងអត្តិភាពនៃវិជ្ជាជីវៈរបស់ខ្លួនដើម្បី ឱ្យការប្រកបវិជ្ជាជីវៈនោះ បានប្រព្រឹត្តដោយត្រឹមត្រូវយុត្តិធម៌ និងមានប្រយោជន៍ដល់សង្គមជាតិ។

# អនុសាសន៍

ក្រោយពីបានសិក្សា និងស្វែងយល់អំពីប្រធានបទខាងលើ យើងខ្ញុំជាកុលបុត្រ កុលធីតា ជាយុវជនខ្មែរជំនាន់ក្រោយដែលជាទំពាំងស្នងឫស្សីរបស់ជាតិ និងជាអនាគតអ្នកដែលនឹងប្រឡូកក្នុងវិជ្ជាជីវៈច្បាប់នេះ យើងខ្ញុំសូមផ្តល់នូវអនុសាសន៍មួយចំនួន ក្នុងន័យពង្រឹងនូវយុត្តិធម៌សង្គម ការអនុវត្តវិជ្ជាជីវៈប្រកបដោយសីលធម៌ និងភាពត្រឹមត្រូវ ដូចតទៅ៖

- ក្រសួងយុត្តិធម៌ និងស្ថាប័នតុលាការ ក៏ដូចជាស្ថាប័នពាក់ព័ន្ធនានាគួរពន្លឿនទៅលើការសាងសង់សាខារបស់សាលាឧទ្ធរណ៍ចំនួន ២ ដែលគ្រោងនឹងសាងសង់នៅខេត្តពោធិ៍សាត់ និងខេត្តត្បូងឃ្មុំឱ្យបានឆាប់ដើម្បីឱ្យការបម្រើសេវាយុត្តិធម៌ជូនប្រជាពលរដ្ឋកាន់តែឆាប់រហ័ស ពិសេសគឺប្រកបដោយយុត្តិធម៌ស្របទៅតាមរដ្ឋធម្មនុញ្ញ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងវិស័យយុត្តិធម៌

- គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា គួរពង្រឹងបន្ថែមលើនីតិវិធីនៃការចូលប្រកបវិជ្ជាជីវៈទាំងតាមមាត្រា៣១ និងមាត្រា៣២ ព្រមទាំងធ្វើការពង្រឹងលើអ្នកដែលកំពុងប្រកបវិជ្ជាជីវៈនេះ តាមរយៈការបើកវគ្គបណ្តុះបណ្តាលបន្ថែមនានាទាំងថ្នាក់ជាតិ និងអន្តរជាតិដើម្បីឱ្យសមាជិក-សមាជិកាមេធាវីនិងមេធាវីកម្មសិក្សាទាំងអស់ កាន់តែទទួលបាននូវចំណេះដឹង និងភាពរីកចម្រើនលើផ្នែកយល់ដឹងនៃច្បាប់ ដែលកិច្ចនេះកាន់តែជំរុញឱ្យការអនុវត្តវិជ្ជាជីវៈ និងការអនុវត្តច្បាប់ក្នុងប្រទេសកាន់តែមានប្រសិទ្ធភាពផងដែរ។

- តុលាការ គួរតែបន្តពង្រឹងលើការងារបន្ថែម ពិសេសនៅដំណាក់កាលអយ្យការ ដោយព្រះរាជអាជ្ញាគួរតែធ្វើការស៊ើបអង្កេតកាន់តែស៊ីជម្រៅបន្ថែមទៅក្នុងភស្តុតាងនៃសំណុំរឿងនីមួយៗ ដោយមិនត្រូវពឹងតែលើរបាយការណ៍នគរបាលយុត្តិធម៌តែមួយមុខនិងមិនត្រូវប្រកាន់ថាជាសំណុំរឿងជនក្រីក្រ ឬសំណុំរឿងអ្នកមានធនធានឡើយ។

- តុលាការ គួរមានថវិកាស្វយ័តរបស់ខ្លួន ដើម្បីឱ្យដំណើរការងារកាន់តែរហ័ស និងតម្លាភាព។

# ឯកសារយោង


## I. លិខិតបទដ្ឋានជាតិ

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើកាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣

២. ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ដែលប្រកាសឱ្យប្រើកាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥

៣. ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

៤. ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា

៥. ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

៦. ព្រះរាជក្រមលេខ នស/រកម/០៧០៦ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធី រដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

៧. ព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

៨. ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលប្រកាសឱ្យប្រើកាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦

៩. អនុក្រឹត្យលេខ៤៧ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌

១០. បទបញ្ជាផ្ទៃក្នុងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវីកាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦

## II. លិខិតបទដ្ឋានអន្តរជាតិ

១. សេចក្តីប្រកាសជាសាកល ស្តីពីសិទ្ធិមនុស្ស ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៦

២. កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ របស់អង្គការសហប្រជាជាតិ

៣. គោលការណ៍មូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលាការ ឆ្នាំ១៩៩៤

## III. សេចក្តីសម្រេច សេចក្តីណែនាំ និងលិខិតនានា

១. សេចក្តីណែនាំលេខ១៥៥៤/គម/១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ របស់គណៈមេធាវី ស្តីពីកាតព្វកិច្ចរបស់គ្រូកម្មសិក្សានិង កម្មសិក្សាការី

២. សេចក្តីសម្រេចលេខ ២៩៤/សសគម/១៩ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការបង្កើតគណៈកម្មការវិន័យនៃក្រុមប្រឹក្សាគណៈមេធាវី

៣. ផែនការណ៍យុទ្ធសាស្ត្រ របស់គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា សម្រាប់ឆ្នាំ២០១៩-២០២០

## IV. ក្រមសីលធម៌

១. ក្រមសីលធម៌ចៅក្រម ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៧

២. ក្រមសីលធម៌មេធាវី ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២

## V. ឯកសារជាសៀវភៅ

១. មេធាវី **ប៊ុន ហុន**, វិជ្ជាជីវៈមេធាវីក្នុងសង្គមកម្ពុជា, រាជធានីភ្នំពេញ, ឆ្នាំ២០១៦

២. មេធាវី **ផៀវ ប៊ុនផង**, បច្ចេកទេសសវនាការនៃមេធាវីព្រហ្មទណ្ឌ,រាជធានីភ្នំពេញ, ២០១១

៣. មេធាវី **ផៀវ ប៊ុនផង**, បច្ចេកទេសសវនាការនៃមេធាវីរដ្ឋប្បវេណី,រាជធានីភ្នំពេញ, ២០១១

៤. **ចាំង ស៊ីណាត**, សិក្ខាសាលាស្តីពី ក្រមនីតិវិធីព្រហ្មទណ្ឌ, រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១០

៥. **សាន់ ជួយ**, នីតិព្រហ្មទណ្ឌពិសេស, រាជធានីភ្នំពេញ,២០១៨

៦. **គីម សែត**, សង្គមវិជ្ជា, រាជធានីភ្នំពេញ, ១៩៦០

៧. **ប្រវត្តិសាស្ត្រប្រទេសកម្ពុជា**, អាដេម៉ារ ឡឺក្លែរ, ប៉ារីស,១៩១៣

៨. **បណ្ឌិត ហ៊ែល ចំរើន**, មរតកយុត្តិធម៌ខ្មែរ, ភ្នំពេញ, ឆ្នាំ២០០៩,ទំព័រ ២៧០-២៨៣

៩. **ឥន្ទ ឱមសាម៉េង**, វប្បធម៌ទូទៅ, ភ្នំពេញ, ឆ្នាំ២០១២-២០១៣

## VI. គេហទំព័រ

១. គេហទំព័រ Wikipedia : សាធារណរដ្ឋប្រជាមានិតកម្ពុជា (អង្គចៅក្រម)

២. គេហទំព័រ Wikipedia : ប្រទេសខ្មែរក្រោមអាណានិគមបារាំង

៣. គេហទំព័រគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌៖ http://www.pscljr.gov.kh/

៤. បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី, ទូរទស្សន៍ Fresh News

៥. ច្បាប់៖ ស្វែងយល់ពីតួនាទីរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, គេហទំព័រ https://thmeythmey.com/

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**


**ប្រធានគណៈមេធាវី**

មេធាវី សួន វិសាល

**ក្រុមប្រឹក្សាគណៈមេធាវី**

១-មេធាវី កុយ នាម
២-មេធាវី ទេព បូផល
៣-មេធាវី ពេជ្រ សុរិយា
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ង៉ា ខូនគា
៦-មេធាវី ចេង ប៉េងហាប់
៧-មេធាវី យុង ផានិត
៨-មេធាវី ចៅ ប៊ុនហួន
៩-មេធាវី រស់ មុនិន្ទ
១០-មេធាវី កែ ចំណាន
១១-មេធាវី ខុង ចន្ថា
១២-មេធាវី ហុង គឹមសួន
១៣-មេធាវី ឱុយ សុខសូលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង សុម៉ារតន៍
១៦-មេធាវី ពិន វណ្ណៈ
១៧-មេធាវី ចំនួ វិចិត្រ
១៨-មេធាវី ព្រហ្ម វិចិត្រសុភា
១៩-មេធាវី ឈុប គុណធុល
២០-មេធាវី យឹម ថាវី
២១-មេធាវី ឌឹម ចៅសេង
២២-មេធាវី លី សុខឡាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុគន្ធ
២៧-មេធាវី គាន តារា
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ទ្រី សំរស់
៣២-មេធាវី នួន ផានិត
៣៣-មេធាវី យុត កែវសុត្ថា


លេខ ១១០៦ /គម/១៩

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩

**សូមជម្រាបជូន**

**ឯកឧត្តមសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**កម្មវត្ថុ** ÷ សំណើសុំអនុញ្ញាតឱ្យនិស្សិតចំនួន ២រូប ចុះស្រាវជ្រាវឯកសារ ។

**យោង** ÷ លិខិតលេខ ៥១១ ស.ភ.ន.វ.ស ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩ របស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម** ជ្រាបថា៖ គណៈមេធាវីអនុញ្ញាតឱ្យនិស្សិតចំនួន ០២រូប ចុះមកស្វែងយល់ពីការងារមួយចំនួនទាក់ទងនឹងប្រធានបទស្តីពី **"ភាពខុសគ្នារវាងតួនាទីមេធាវី និងតួនាទីតុលាការ"** និងស្រាវជ្រាវឯកសារនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែឯកសារសម្ងាត់ ចាប់ពីថ្ងៃទី **ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩ ដល់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩** ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម** ជ្រាប ។

សូម **ឯកឧត្តម** ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

**ត.ប. ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

**អគ្គលេខាធិការ**

**មេធាវី. ព្រហ្ម_វិចិត្រអង្គរា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

លេខ..៥១១.....ស.ភ.ន.វ.ស

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
ចូល
-លេខ: ១០៦០
-ម៉ោង: ១០:០៧
-ថ្ងៃ ខែ ឆ្នាំ: ២៩.០៤.១៩
-បញ្ជូន:

ថ្ងៃព្រហស្បតិ៍ ៦ រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៩

**សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
**គោរពជូន**
**ឯកឧត្តមប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ** ៖ សំណើសុំអនុញ្ញាតឲ្យនិស្សិតចំនួន២រូប ចុះស្រាវជ្រាវឯកសារ។
**យោង** ៖ សំណើរបស់សាមីនិស្សិតចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធានគណៈមេធាវី** មេត្តាជ្រាបថា សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបាន និងកំពុងបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។ អំឡុងពេលសិក្សាឆ្នាំបញ្ចប់ និស្សិតយើងខ្ញុំចំនួន២រូប ដូចមានបញ្ជីរាយនាមជូនភ្ជាប់មកជាមួយនេះ ត្រូវចុះស្រាវជ្រាវឯកសារ និងស្វែងយល់ពីការងារមួយចំនួនដែលទាក់ទងនឹងប្រធានបទស្តីពី **"ភាពខុសគ្នារវាងតួនាទីមេធាវី និងតួនាទីតុលាការ"** នៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩ ដល់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ ដើម្បីទទួលបានមកវិញនូវបទពិសោធន៍ការងារជាក់ស្តែង និងដើម្បីសរសេរសារណា និងការពារបញ្ចប់ការសិក្សារបស់ខ្លួន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធានគណៈមេធាវី** មេត្តាពិនិត្យលទ្ធភាពអនុញ្ញាតឲ្យនិស្សិតយើងខ្ញុំបានចុះស្រាវជ្រាវឯកសារដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធានគណៈមេធាវី** មេត្តាទទួលនូវគារវកិច្ចដ៏ស្មោះពីខ្ញុំ។

**ជ. សាកលវិទ្យាធិការ**
**សាកលវិទ្យាធិការរង**

**យិត សុវណ្ណឬទ្ធ**

Monivong Blvd, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh, Cambodia.
P.O. Box 842, Tel: (855) 23 214 703, Fax: (855) 23 214 953, E-mail: rector@rule.edu.kh, website: www.rule.edu.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**បញ្ជីរាយនាម**
**និស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី ១៩ ក្រុម L4A2**
**ឆ្នាំសិក្សា ២០១៨-២០១៩**
**ដែលត្រូវចុះស្រាវជ្រាវឯកសារ នៅ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

| ល.រ | គោត្តនាម-នាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | លេខទូរស័ព្ទ | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | អ៊ឹម ភួបម៉ារ៊ីឌី | ប្រុស | ០២-១២-១៩៩៧ | ០១១ ៥៨៥ ៧១៤<br>០៦៩ ២៦៥ ៧៩៩ | |
| ២ | ស៊ាង លីនដា | ស្រី | ០១-០៩-១៩៩៨ | ០៨៦ ២១៨ ៦៥៨ | |

ថ្ងៃពុធ ៥រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩
**ប្រធានការិយាល័យស្រាវជ្រាវ**

ញ៉ឹក-ឫទ្ធី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំអនុញ្ញាតចុះស្រាវជ្រាវឯកសារ**

យើងខ្ញុំឈ្មោះ **អ៊ឹម ភួបម៉ារ៉ុឌី** និង **ស៊ាង លីនដា** ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី១៩ ក្រុម $L_4A_2$ ឆ្នាំសិក្សា២០១៨-២០១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមគោរពជូន**

**ឯកឧត្តមសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**

**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**កម្មវត្ថុ** ៖ សំណើសុំអនុញ្ញាតចុះស្រាវជ្រាវឯកសារ។

តាមកម្មវត្ថុខាងលើ យើងខ្ញុំមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តម** មេត្តាជ្រាបថា បន្ទាប់ពីបានធ្វើការសិក្សាផ្នែកទ្រឹស្តី យើងខ្ញុំត្រូវសរសេរសារណា និងការពារបញ្ចប់ការសិក្សាដែលទាក់ទងនឹងប្រធានបទស្តីពី *"ភាពខុសគ្នារវាងតួនាទីមេធាវី និង តួនាទីតុលាការ"* ដោយត្រូវចុះស្រាវជ្រាវឯកសារ នៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩ ដល់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម** មេត្តាអនុញ្ញាតឲ្យយើងខ្ញុំបានចុះស្រាវជ្រាវឯកសារដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ថ្ងៃពុធ ៥រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩

ហត្ថលេខា

អ៊ឹម ភួបម៉ារ៉ុឌី ស៊ាង លីនដា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះសីហនុ

លេខាធិការដ្ឋានរដ្ឋបាល

## កំណត់បង្ហាញ

| | |
|---|---|
| អត្តសញ្ញាណឯកសារ | • ឈ្មោះឯកសារ: លិខិតលេខ: ៥១៦. ស.ជ.ន.ចស<br>• កម្មវត្ថុ: [illegible]<br>• ប្រភពឯកសារ: [illegible]<br>• កាលបរិច្ឆេទនៃឯកសារ: [illegible] |

មន្ត្រីទទួលបន្ទុកឯកសារ

ព្រះសីហនុ, ថ្ងៃទី០៩ ខែ៥ ឆ្នាំ២០១៩

ហត្ថលេខា និងឈ្មោះ

[illegible]

| យោបល់លោកប្រធានសាលាដំបូងខេត្ត: | យោបល់លោកប្រធានលេខាធិការដ្ឋាន: |
|---|---|
| [illegible] | [illegible] |
| ថ្ងៃទី០៩ ខែ០៥ ឆ្នាំ២០១៩<br>ហត្ថលេខា | ថ្ងៃទី៩ ខែ៥ ឆ្នាំ២០១៩<br>ហត្ថលេខា |

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ស. សាលាដំបូងខេត្តព្រះសីហនុ**
ចូល
លេខ: ២០៤៣ ស.ន
ថ្ងៃទី ០៩ ខែ ៥ ឆ្នាំ ២០១៩
ម៉ោង: ១៥:១០

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
លេខ ៥១៦ ស.ភ.ន.វ.ស

**សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**សូមគោរពជូន**

**លោកប្រធានសាលាដំបូងខេត្តព្រះសីហនុ**

**កម្មវត្ថុ** ៖ សំណើសុំអនុញ្ញាតឲ្យនិស្សិតចំនួន២រូប ចុះស្រាវជ្រាវឯកសារ។

**យោង** ៖ សំណើរបស់សាមីនិស្សិតចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបាន និងកំពុងបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។ អំឡុងពេលសិក្សាឆ្នាំបញ្ចប់ និស្សិតយើងខ្ញុំចំនួន២រូប ដូចមានបញ្ជីរាយនាមជូនភ្ជាប់មកជាមួយនេះ ត្រូវចុះស្រាវជ្រាវឯកសារ និងស្វែងយល់ពីការងារមួយចំនួនដែលទាក់ទងនឹងប្រធានបទស្តីពី **"ភាពខុសគ្នារវាងតួនាទីមេធាវី និងតួនាទីតុលាការ"** នៅសាលាដំបូងខេត្តព្រះសីហនុ ចាប់ពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩ ដល់ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ ដើម្បីទទួលបានមកវិញនូវបទពិសោធន៍ការងារជាក់ស្តែង និងដើម្បីសរសេរសារណា និងការពារបញ្ចប់ការសិក្សារបស់ខ្លួន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** មេត្តាពិនិត្យលទ្ធភាពអនុញ្ញាតឲ្យនិស្សិតយើងខ្ញុំបានចុះស្រាវជ្រាវឯកសារដោយសេចក្តីអនុគ្រោះ។

សូម **លោកប្រធាន** មេត្តាទទួលនូវគារវកិច្ចដ៏ស្មោះពីខ្ញុំ។

ថ្ងៃ សុក្រ ០៧ រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩

**ជ. សាកលវិទ្យាធិការ**
**សាកលវិទ្យាធិការរង**

**យិត_សុវុធ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## បញ្ជីរាយនាម

**និស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី ១៩ ក្រុម L4A2**

**ឆ្នាំសិក្សា ២០១៨-២០១៩**

**ដែលត្រូវចុះស្រាវជ្រាវឯកសារ នៅ សាលាដំបូងខេត្តព្រះសីហនុ**

| ល.រ | គោត្តនាម-នាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | លេខទូរស័ព្ទ | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | អ៊ឹម ភួបម៉ារ៉ីឌី | ប្រុស | ០២-១២-១៩៩៧ | ០១១ ៥៨៥ ៧១៤<br>០៦៩ ២៦៥ ៧៩៩ | |
| ២ | ស៊ាង លីនដា | ស្រី | ០១-០៩-១៩៩៨ | ០៨៦ ២១៨ ៦៥៨ | |

ថ្ងៃពុធ ៥រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩
**ប្រធានការិយាល័យស្រាវជ្រាវ**

ញឹក-វុឌ្ឍី

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យសុំអនុញ្ញាតចុះស្រាវជ្រាវឯកសារ

យើងខ្ញុំឈ្មោះ អ៊ឹម ភួបម៉ារីឌី និង ស៊ាង លីនដា ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី១៩ ក្រុម $L_4A_2$ ឆ្នាំសិក្សា២០១៨-២០១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមគោរពជូន**
**ឯកឧត្តមសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**កម្មវត្ថុ** ៖ សំណើសុំអនុញ្ញាតចុះស្រាវជ្រាវឯកសារ។

តាមកម្មវត្ថុខាងលើ យើងខ្ញុំមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តម** មេត្តាជ្រាបថា បន្ទាប់ពីបានធ្វើការសិក្សាផ្នែកទ្រឹស្តី យើងខ្ញុំត្រូវសរសេរសារណា និងការពារបញ្ចប់ការសិក្សាដែលទាក់ទងនឹងប្រធានបទស្តីពី "**ភាពខុសគ្នារវាងតួនាទីមេធាវី និង តួនាទីតុលាការ**" ដោយត្រូវចុះស្រាវជ្រាវឯកសារ នៅសាលាដំបូងខេត្តព្រះសីហនុ ចាប់ពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩ ដល់ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម** មេត្តាអនុញ្ញាតឲ្យយើងខ្ញុំបានចុះស្រាវជ្រាវឯកសារដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ថ្ងៃពុធ ៥រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩
ហត្ថលេខា

អ៊ឹម ភួបម៉ារីឌី ស៊ាង លីនដា

**គំរូពាក្យស្នើសុំមេធាវី ពីតុលាការ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការ ឬ អយ្យការអម**.................
លេខ:................................/១៩

**ប្រធានតុលាការ**........... / **ព្រះរាជអាជ្ញានៃអយ្យការអម**.....................

គោរពជូន

**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កម្មវត្ថុ៖** សំណើសុំចាត់តាំងមេធាវីដើម្បីការពារក្តីជូនជនជាប់ចោទក្រីក្រ។

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន ឯកឧត្តម មេត្តាជ្រាបថា នៅថ្ងៃទី.... ខែ..... ឆ្នាំ................វេលាម៉ោង..........នៅសាល/បន្ទប់លេខ....តុលាការ............នឹងធ្វើការជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌដូចខាងក្រោម៖

១- សំណុំរឿងលេខ ០០០០ ចុះថ្ងៃទី.....ខែ....ឆ្នាំ.........

-ជនជាប់ចោទ ................................ ភេទ...........

ជាប់ចោទពីបទ ................................................

សេចក្តីដូចមានជម្រាបក្នុងកម្មវត្ថុខាងលើ សូម ឯកឧត្តមរដ្ឋមន្ត្រី មេត្តាធ្វើការចាត់តាំងមេធាវីដើម្បីការពារក្តីជូនជនជាប់ចោទខាងលើដោយហេតុជននេះជាជនបានប្រព្រឹត្តបទល្មើសឧក្រិដ្ឋ និងគ្មានលទ្ធភាពរកមេធាវី។

សូម ឯកឧត្តមរដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ថ្ងៃ..........................ខែ.......... ឆ្នាំ....... .....ស័ក ព.ស............

តុលាការ........, ថ្ងៃទី........ខែ........ឆ្នាំ...........

**ចៅក្រម**

ត្រាមូល និងត្រាឈ្មោះរបស់ចៅក្រម

**បានឃើញ និងឯកភាព**

ថ្ងៃទី.....ខែ......ឆ្នាំ............

**ប្រធានតុលាការ**

ត្រាមូល និងត្រាឈ្មោះប្រធានតុលាការ

ចម្លងជូន៖

- គណ:មេធាវីនៃ

ព្រះរាជាណាចក្រកម្ពុជា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំមេធាវី

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ..................................អាយុ..............ឆ្នាំ មុខរបរ....................................
មានទីលំនៅ ....................................................................................................................
លេខទូរស័ព្ទទំនាក់ទំនង...............................................ត្រូវជា.................................................
....................................................................................................................................។

**សូមគោរពចូលមក**
**លោកប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ** : សំណើសុំមេធាវីចំនួនមួយរូបដើម្បីការពារក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ......................ចុះថ្ងៃទី ....................................របស់.....................................................................................។

**យោង** :លិខិតបញ្ជាក់លេខ ...............ចុះថ្ងៃទី ...........................របស់...........................................។

តបតាមកម្មវត្ថុ និង យោងខាងលើខ្ញុំបាទ/នាងខ្ញុំសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំ ត្រូវបានតុលាការ.................................................កោះហៅឱ្យចូលនៅថ្ងៃទី............................តែដោយខ្ញុំបាទ/នាងខ្ញុំ ជាប្រជាពលរដ្ឋក្រីក្រគ្មានលទ្ធភាពពឹងពាក់មេធាវីនិងមិនអាចការពារខ្លួននៅចំពោះមុខតុលាការបាន ទើបខ្ញុំបាទ/នាងខ្ញុំ ស្នើសុំការចាត់តាំងមេធាវីពីគណៈមេធាវី។

អាស្រ័យហេតុនេះ សូម **លោកប្រធាន** មេត្តាអនុញ្ញាតចាត់តាំងមេធាវីដើម្បីការពារឱ្យខ្ញុំបាទ/នាងខ្ញុំនៅតុលាការ..........................................................ដោយក្តីអនុគ្រោះ។

សូម **លោកប្រធាន** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ...................................ខែ..................ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ............ខែ............ឆ្នាំ................
**ស្នាមមេដៃស្តាំ និង ឈ្មោះ**

# គំរូលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតប្រគល់សិទ្ធិជូនអ្នកតំណាងដោយអាណត្តិ

ខ្ញុំអាណត្តិទាយកឈ្មោះ ................ ភេទ........ កើតឆ្នាំ.......... សញ្ជាតិ............ មានទំលំនៅភូមិ.......... សង្កាត់/ឃុំ.......... ខណ្ឌ/ស្រុក......... រាជធានី/ខេត្ត......... ។ទូរសព្ទទំនាក់ទំនង .................. ។

**សូមប្រគល់សិទ្ធិជូន**

លោក/លោកស្រី .............. អត្តលេខ៖ ......... ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និង ជាមេធាវីនៃ **ក្រុមមេធាវី**.........................មានការិយាល័យ..........ផ្លូវ.........សង្កាត់/ឃុំ........ខណ្ឌ/ស្រុក.......... រាជធានី/ខេត្ត.......... ទំនាក់ទំនងតាមទូរសព្ទលេខ:...................... ដើម្បីធ្វើជាមេធាវីតំណាងដោយអាណត្តិឱ្យខ្ញុំបាទ/នាងខ្ញុំសុំចូលរួមអន្តរាគមន៍តាមផ្លូវច្បាប់ដើម្បីជួយភាគីដើម/ចុងចម្លើយឈ្មោះ.................ក្នុងសំណុំរឿងរដ្ឋប្បវេណី/ព្រហ្មទណ្ឌលេខ:..........ចុះថ្ងៃទី.........ខែ.......ឆ្នាំ..........របស់សាលាដំបូង/តុលាការ.......... ។

លោក **មេធាវី** ដែលបានទទួលសិទ្ធិធ្វើជាមេធាវីតំណាងដោយអាណត្តិនេះ មានសិទ្ធិអំណាចធ្វើជំនួសនូវរាល់កិច្ចការដែលពាក់ពន្ធ័ក្នុងរឿងក្តីខាងលើគ្រប់តំណាក់កាល និង ធ្វើនូវរាល់សកម្មភាពដែលស្របទៅនឹងស្មារតីនៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

**បញ្ជាក់:** រាល់ការចំណាយលើការបង់ពន្ធ ឬ ការចំណាយផ្សេងៗពាក់ព័ន្ធទៅនឹងរឿងវិវាទជាបន្ទុករបស់ខ្ញុំជាអាណត្តិទាយក។

ថ្ងៃ..............ខែ.......... ឆ្នាំ......... ........ស័ក ព.ស. ២៥.....

ត្រូវថ្ងៃទី....... ខែ....... ឆ្នាំ.......

**ស្នាមមេដៃ**

**បានឃើញ និង យល់ព្រម**

ធ្វើជាតំណាងអោយឈ្មោះ..........

ថ្ងៃ..............ខែ.......... ឆ្នាំ......... ........ស័ក ព.ស. ២៥.....

ត្រូវថ្ងៃទី....... ខែ....... ឆ្នាំ.......

**ហត្ថលេខា និង ត្រា**

# គំរូកិច្ចព្រមព្រៀងសេវាមេធាវី

## កិច្ចព្រមព្រៀងប្រគល់ ទទួលប្រាក់សេវាមេធាវី

កិច្ចព្រមព្រៀងនេះធ្វើនៅថ្ងៃ...........ខែ......... ឆ្នាំ.......ស័ក ព.ស......... ត្រូវថ្ងៃទី...... ខែ........ ឆ្នាំ...........

**រវាង**

ខ្ញុំអាណត្តិទាយកឈ្មោះ .................. ភេទ........ អាយុ........ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅមានទំលំនៅភូមិ.......... សង្កាត់/ឃុំ.......... ខណ្ឌ/ស្រុក......... រាជធានី/ខេត្ត......... ។ ហៅថា**ភាគី**(**ក**) ។

**និង**

លោក/លោកស្រី .............. អត្តលេខ៖ ......... ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និង ជាមេធាវីនៃ **ក្រុមមេធាវី**........................មានការិយាល័យ..........ផ្លូវ.........សង្កាត់/ឃុំ........ខណ្ឌ/ស្រុក..........រាជធានី/ខេត្ត......... ទំនាក់ទំនងតាមទូរសព្ទលេខ:....................... ហៅថា **ភាគី**(**ខ**) ។

**ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោះ**

**១/** **ភាគី**(**ក**)យល់ព្រមប្រគល់សិទ្ធិហើយ **ភាគី**(**ខ**)យល់ព្រមទទួលសិទ្ធិតំណាងដោយអាណត្តិឱ្យ **ភាគី**(**ក**) ក្នុងសំណុំរឿងព្រហ្មទណ្ឌ/រដ្ឋប្បវេណីលេខ:.........ចុះថ្ងៃទី.......ខែ........ឆ្នាំ២០.......របស់សាលាដំបូង/តុលាការ........... ។

**២/** **ភាគី**(**ក**)យល់ព្រមបង់ប្រាក់កំរៃសេវាមេធាវី ......................................... ឱ្យ**ភាគី**(**ខ**)។ **ភាគី**(**ខ**) យល់ព្រមផ្តល់សេវាមេធាវីក្នុងសំណុំរឿងព្រហ្មទណ្ឌ/រដ្ឋប្បវេណីលេខ:.........ចុះថ្ងៃទី.......ខែ........ឆ្នាំ២០.......របស់សាលាដំបូង/តុលាការ...........រហូតចប់នីតិវិធីនៅសាលាដំបូង/តុលាការ........... ។

**៣/** ការបង់ប្រាក់កំរៃសេវាមេធាវីចែកចេញជា៣តំណាក់ដូចខាងក្រោម៖

តំណាក់ទី១៖ **ភាគី**(**ក**)ត្រូវបង់ប្រាក់កំរៃសេវាមេធាវី..........................ឱ្យ**ភាគី**(**ខ**)នៅពេល **ភាគី**(**ខ**)បានសិក្សា និង ផ្តល់យោបល់លើសំណុំរឿងខាងលើជាបឋម ។

តំណាក់ទី២៖ **ភាគី**(**ក**)ត្រូវបង់ប្រាក់កំរៃសេវាមេធាវី..........................**បន្ថែមទៀត**ឱ្យ**ភាគី**(**ខ**)នៅពេល **ភាគី** (**ខ**)បានរៀបចំ និង ធ្វើបណ្តឹង............... និងបណ្តឹង...........ជូន **ភាគី**(**ខ**) បានរួចរាល់ ។

តំណាក់ទី៣៖ **ភាគី**( **ក** ) ត្រូវបង់ប្រាក់កំរៃសេវាមេធាវី.........................................**បន្ថែមទៀត**ឱ្យ
**ភាគី**( **ខ** ) នៅពេល **ភាគី** ( **ខ** ) បានរៀបចំឯកសារត្រៀមរួចរាល់ (..........................)ឬ
**ភាគី** ( **ខ** ) ទទួលបានលិខិតអញ្ជើញចូលរួម........................ ។

៤/ កិច្ចព្រមព្រៀងនេះធ្វើជាភាសាខ្មែរចំនួន......ច្បាប់ ។

**ហត្ថលេខា /ស្នាមមេដៃរបស់ភាគី**

**គំរូពាក្យបណ្ដឹងព្រហ្មទណ្ឌទៅតុលាការ ឬអយ្យការ**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## <u>ពាក្យបណ្ដឹង</u>

ខ្ញុំបាទឈ្មោះ......................................ភេទ...........អាយុ........ឆ្នាំ បច្ចុប្បន្នរស់នៅភូមិ................ សង្កាត់/ឃុំ....... ខណ្ឌ/ស្រុក....... រាជធានី/ខេត្ត...................... មុខរបរ៖................ ។

លេខទូរស័ព្ទ: ..........................

**សូមគោរពជូន**

**លោកប្រធានសាលាដំបូង ឬ លោកព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង**............

**កម្មវត្ថុ៖** សូមប្ដឹងឈ្មោះ.............................................ភេទ.........អាយុ..........ឆ្នាំ មានទីលំនៅនៅភូមិ ................ សង្កាត់/ឃុំ....... ខណ្ឌ/ស្រុក....... រាជធានី/ខេត្ត...................... ។

ពីបទ៖ .................................... ។

សេចក្ដីដូចមានជម្រាបជូនខាងលើ យើងខ្ញុំសូមជម្រាបជូន **លោកប្រធានសាលាដំបូង/លោកព្រះរាជអាជ្ញា** មេត្តាជ្រាបថា កាលពីថ្ងៃទី........ខែ.........ឆ្នាំ.......... កន្លងទៅនេះវេលាម៉ោង............. ឈ្មោះ .....................បាន........................................................ ។

អាស្រ័យដូចបានគោរពជូនខាងលើ សូម **លោកប្រធានសាលាដំបូង/លោកព្រះរាជអាជ្ញា** មេត្តាជួយរកយុត្តិធម៌ជូនរូបយើងខ្ញុំ និងចាត់ការបក្សពួកតាមនីតិវិធីច្បាប់។

សូម **លោកប្រធានសាលាដំបូង/លោកព្រះរាជអាជ្ញា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ថ្ងៃ.............. ខែ........... ឆ្នាំ.......... ............ស័ក ព.ស.............

ធ្វើនៅ................. ថ្ងៃទី........... ខែ............ ឆ្នាំ.................

ស្នាមមេដៃស្ដាំ

**គំរូពាក្យបណ្តឹងរដ្ឋប្បវេណីទៅតុលាការ**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្តឹង

**ដើមបណ្តឹង៖** ឈ្មោះ.....................ភេទ.......កើតឆ្នាំ......... សញ្ជាតិ........... មានទំលំនៅភូមិ...........

សង្កាត់/ឃុំ.......... ខណ្ឌ/ស្រុក.........រាជធានី/ខេត្ត......... ។

**ចុងចម្លើយ៖** ឈ្មោះ.....................ភេទ.......កើតឆ្នាំ......... សញ្ជាតិ...........កាន់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរលេខ.........ចុះថ្ងៃទី.....ខែ....ឆ្នាំ....... មានទំលំនៅភូមិ..........សង្កាត់/ឃុំ..........ខណ្ឌ/ស្រុក.........រាជធានី/ខេត្ត......... ។ ទូរស័ព្ទលេខៈ..............................

## សូមគោរពជូន

## លោកប្រធានសាលាដំបូង.........................

**កម្មវត្ថុ៖** ប្តឹងសុំឱ្យតុលាការចេញសាលក្រម ដែលមានខ្លឹមសារដូចខាងក្រោម៖

១. បង្គាប់ឱ្យចុងចម្លើយជាកូនបំណុលសង...................................................... ។

២. បង្គាប់ឱ្យចុងចម្លើយសងសំណងចំនួន....................................................... ។

៣. ........................................................................................................ ។

**យោង៖** កិច្ចសន្យា.....................ចុះថ្ងៃទី...........ខែ...........ឆ្នាំ................. ។

សេចក្តីដូចមានជម្រាបជូនខាងលើខ្ញុំបាទ/នាងខ្ញុំ សូម **លោកប្រធាន** មេត្តាសម្រេចតាមសំណូមពររបស់ខ្ញុំបាទ/នាងខ្ញុំ ដូចមានចែងក្នុងកម្មវត្ថុខាងលើដោយក្តីអនុគ្រោះ ។

សូម **លោកប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

ថ្ងៃ.............. ខែ........... ឆ្នាំ.......... ............ស័ក ព.ស.............

ធ្វើនៅ................. ថ្ងៃទី.......... ខែ............ ឆ្នាំ.................

ស្នាមមេដៃស្តាំ